វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា

The NGO Forum on Cambodia

Working Together for Positive Change

# ការរៀនសូត្រពីប្រព័ន្ធធារាសាស្ត្រនៅកម្ពុជា: អត្ថប្រយោជន៍ និងបញ្ហាប្រឈម




ភ្នំពេញ កម្ពុជា

ខែ តុលា ឆ្នាំ ២០១១

# ការរៀនសូត្រពីប្រព័ន្ធធារាសាស្ត្រនៅកម្ពុជាៈ អត្ថប្រយោជន៍ និងបញ្ហាប្រឈម

អ្នកនិពន្ធៈ លោក ង៉ោ សុចាត
សមាគមសេដ្ឋកិច្ចកម្ពុជា(CEA)

បោះពុម្ពដោយៈ គម្រោងប្រសិទ្ធភាពជំនួយនៃកម្មវិធីបញ្ហាអភិវឌ្ឍន៍
វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា

រចនាដោយៈ លោក ភួន យូ មន្ត្រីផ្នែកព័ត៌មាន និងបោះពុម្ពផ្សាយ
វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា

សេចក្តីបញ្ជាក់ៈ ទស្សនៈសម្តែងនៅក្នុងរបាយការណ៍នេះគឺជាទស្សនៈរបស់អ្នកនិពន្ធ និងមិនតំណាងឲ្យទស្សនៈរបស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា ឬ សមាគមសេដ្ឋកិច្ចកម្ពុជាទេ។ ខ្លឹមសារនៃរបាយការណ៍នេះអាចដកស្រង់និងបោះពុម្ពឡើងវិញបាន ដោយមានការទទួលស្គាល់និងការអនុញ្ញាតពីអ្នកនិពន្ធនិងស្ថាប័នបោះពុម្ពផ្សាយតាមការចាំបាច់។

**© វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា - ខែតុលា ឆ្នាំ២០១១**

# មាតិកា

**មាតិកា** ........ i

**បញ្ជីពាក្យកាត់** ........ iii

**សេចក្តីថ្លែងអំណរគុណ** ........ iv

**សេចក្តីសង្ខេប** ........ v

**១. សាវតារ** ........ ១

**២. វិធីសាស្ត្រ** ........ ២

**៣. ការត្រួតពិនិត្យទំហំស្រោចស្រពនៃប្រព័ន្ធធារាសាស្ត្រនៅកម្ពុជា** ........ ៤

**៤. ការសង្កេតផ្ទាល់លើករណីធារាសាស្ត្រ** ........ ៩

៤.១. អត្ថប្រយោជន៍ពីប្រព័ន្ធធារាសាស្ត្រ ........ ៩

៤.២. បញ្ហាប្រឈមនៅក្នុងប្រព័ន្ធធារាសាស្ត្រ ........ ១៤

**៥. ការស្ទង់មតិតាមគ្រួសារបែបរហ័ស** ........ ១៨

៥.១. ការជ្រើសរើសសំណាក ........ ១៨

៥.២. ព័ត៌មានអំពីសំណាក ........ ១៩

៥.៣. របកគំហើញនៃការស្ទង់មតិបែបរហ័ស ........ ២១

៥.៣.១. ឥរិយាបថរបស់កសិករ និងលក្ខណៈដីស្រែ ........ ២១

៥.៣.២. ការកែលម្អផល និងបញ្ហាប្រឈម ........ ២៣

៥.៣.៣. ផលប៉ះពាល់នៃប្រព័ន្ធធារាសាស្ត្រ ........ ២៦

**៦. សេចក្តីសន្និដ្ឋាន និងទស្សនៈវិស័យអនាគត** ........ ២៧

**៧. ឯកសារយោង** ........ ៣២

**៨. ឧបសម្ព័ន្ធ** ........ ៣៣

ប្រព័ន្ធទី ១: ប្រព័ន្ធធារាសាស្ត្រត្រាំម្នាស់ [ខេត្តពោធិ៍សាត់] ........ ៣៣

ប្រព័ន្ធទី ២: ប្រព័ន្ធធារាសាស្ត្រជ្រៃជើងនិងម្រះព្រៅ [ខេត្តបាត់ដំបង] ........ ៣៥

ប្រព័ន្ធទី ៣: ប្រព័ន្ធធារាសាស្ត្រប្រឡាយលេខ ១ [ខេត្តបាត់ដំបង] ........ ៣៧

ប្រព័ន្ធទី ៤: ប្រព័ន្ធធារាសាស្ត្រពន្លៃ [ខេត្តបន្ទាយមានជ័យ] ........ ៤០

ប្រព័ន្ធទី ៥: ប្រព័ន្ធធារាសាស្ត្រទានកាំ-បន្ទាត់បោះ [ខេត្តបន្ទាយមានជ័យ] ........ ៤២

ម.ព.ឯ.ក AIDOC
Code: 158-027
Date:
Donated by:

ប្រព័ន្ធទី ៦: ប្រព័ន្ធធារាសាស្ត្រទំនប់រំដេង [ខេត្តសៀមរាប] ........ ៤៥
ប្រព័ន្ធទី ៧: ប្រព័ន្ធធារាសាស្ត្រសាមសិបកញ្ញា [ខេត្តកំពង់ធំ] ........ ៤៧
ប្រព័ន្ធទី ៨: ប្រព័ន្ធធារាសាស្ត្រស្ទឹងជីនិត [ខេត្តកំពង់ធំ] ........ ៥១
ប្រព័ន្ធទី ៩: ប្រព័ន្ធធារាសាស្ត្រប្រឡាយរួមស្រុក [ខេត្តព្រៃវែង] ........ ៥៤
ប្រព័ន្ធទី ១០: ប្រព័ន្ធធារាសាស្ត្រត្រដែត [ខេត្តស្វាយរៀង] ........ ៥៧
ប្រព័ន្ធទី ១១: ប្រព័ន្ធធារាសាស្ត្រដងខ្ទម [ខេត្តតាកែវ] ........ ៥៩
ប្រព័ន្ធទី ១២: ប្រព័ន្ធធារាសាស្ត្របន្ទាយធ្លាយ [ខេត្តតាកែវ] ........ ៦១
**ពាក្យបច្ចេកទេស** ........ ៦៤

# បញ្ជីពាក្យកាត់

| | |
|---|---|
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី |
| AFD | ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង |
| ASSDP | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម |
| CAVAC | គម្រោងអនុក្រមតម្លៃកសិកម្មកម្ពុជា |
| CEA | សមាគមសេដ្ឋកិច្ចកម្ពុជា |
| CPP | គណៈបក្សប្រជាជនកម្ពុជា |
| KHR | ប្រាក់រៀល |
| CSF | មូលនិធិឃុំ/សង្កាត់ |
| DOA | ការិយាល័យកសិកម្មស្រុក |
| ECOSORN | កម្មវិធីរបស់សហភាពអឺរ៉ុបមួយដែលមានឈ្មោះថា "គម្រោងស្តារឡើងវិញសេដ្ឋកិច្ច និងសង្គមនៅខេត្តភាគពាយព្យប្រទេសកម្ពុជា" |
| EU | សហភាពអឺរ៉ុប |
| FWUC | សហគមន៍កសិករប្រើប្រាស់ទឹក |
| HH | គ្រួសារ |
| IMF | មូលនិធិរូបិយវត្ថុអន្តរជាតិ |
| Kg | គីឡូក្រាម |
| Kg/ha | គីឡូក្រាមក្នុងមួយហិកតា |
| MAFF | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ |
| MOWRAM | ក្រសួងធនធានទឹក និងឧតុនិយម |
| MTR | ការពិនិត្យវាយតម្លៃពាក់កណ្ដាលអាណត្តិគម្រោង |
| NCDD | គណៈកម្មាធិការជាតិសម្រាប់អភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| NRM | ការគ្រប់គ្រងធនធានធម្មជាតិ |
| NSDP | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |
| O&M | ប្រតិបត្តិការនិងការថែទាំ |
| PDWRM | មន្ទីរធនធានទឹកនិងឧតុនិយមខេត្ត |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| SAW | យុទ្ធសាស្ត្រកសិកម្មនិងទឹក |
| t/ha | តោនក្នុងមួយហិកតា |
| USD | ដុល្លារសហរដ្ឋអាមេរិក |

# សេចក្តីថ្លែងអំណរគុណ

ការសិក្សានេះអាចធ្វើទៅបានដោយមានការគាំទ្រពីវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា តាមរយៈកម្មវិធីបញ្ហាអភិវឌ្ឍន៍ដែលបានផ្តល់ការគាំទ្រទាំងផ្នែកហិរញ្ញវត្ថុ ក៏ដូចជាការពិគ្រោះយោបល់ដើម្បីធ្វើអោយរបាយការណ៍នេះអាចចេញផ្សាយបាន។ ក្រោមកិច្ចសហការជាមួយសមាគមសេដ្ឋកិច្ចកម្ពុជា(CEA) លោក **ច័ន្ទ សុផល** ជាប្រធានសមាគមបានផ្តល់យោបល់ដ៏មានសារៈសំខាន់ទៅលើអភិក្រម វិធីសាស្ត្រ និងក្របខ័ណ្ឌវិភាគសំរាប់ការសិក្សានេះ។ អ្នកនិពន្ធសូមថ្លែងអំណរគុណជាអនេកដល់ **ឯកឧត្តម វេង សាខុន** រដ្ឋលេខាធិការនៃក្រសួងធនធានទឹក និងឧតុនិយម ដែលឯកឧត្តមបានផ្តល់ប្រឹក្សា និងការចង្អុលបង្ហាញដ៏មានតំលៃចំពោះគ្រោងការនៃការសិក្សានេះ។ ការសិក្សានេះទទួលបានអត្ថប្រយោជន៍ជាច្រើនពីការត្រួតពិនិត្យឡើងវិញ និងការផ្តល់យោបល់បន្ថែមពីសំណាក់លោក **ជា គីមសុង** ប្រធានកម្មវិធីបញ្ហាអភិវឌ្ឍន៍ លោក **វ៉ា សូធី** ជាអ្នកសម្របសម្រួលគំរោងថវិកាជាតិ និង លោក **តែ ដួងវឌ្ឍនា** ជាអ្នកសម្របសម្រួលគំរោងប្រសិទ្ធិភាពជំនួយនៃវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា។ សេចក្តីថ្លែងអំណរគុណនេះសូមថ្លែងបន្តជូនដល់ លោក **ជា សារ៉ុម** លោក **ភួន យូ** និងលោក **ហុក ម៉េងហ៊ាន់** នៃមជ្ឈមណ្ឌលព័ត៌មាននិងស្រាវជ្រាវរបស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា ចំពោះការរចនាដោយផ្ចិតផ្ចង់លើការបោះពុម្ពរបាយការណ៍នេះ។

អ្នកនិពន្ធសូមថ្លែងអំណរគុណដល់កញ្ញា **ថៃ សៀងមៀន** និង លោក **ឆាយ វណ្ណប៉ូលី** ជាអ្នកជំនួយការស្រាវជ្រាវនៃសមាគមសេដ្ឋកិច្ចកម្ពុជា ចំពោះការងារប្រកបដោយការយកចិត្តទុកដាក់របស់ពួកគេក្នុងការតាមដានការសម្ភាសន៍ផ្ទាល់នឹងកន្លែង ការប្រមូលទិន្នន័យ ការបញ្ចូលទិន្នន័យ និងការគាំទ្រដ៏ទៃទៀតក្នុងអំឡុងពេលសិក្សារួមមានការផ្តល់មតិយោបល់ និងការអានផ្ទៀងផ្ទាត់លើរបកគំហើញរបាយការណ៍ស្រាវជ្រាវនេះ។

ជាចុងក្រោយ អ្នកនិពន្ធសូមថ្លែងអំណរគុណដល់បុគ្គលិកនៃគម្រោងធារាសាស្ត្រដែលបានចុះទៅសិក្សារួមមាន អាជ្ញាធរខេត្ត ក្រុមប្រឹក្សាឃុំ ប្រធានភូមិ សហគមន៍ កសិករប្រើប្រាស់ទឹក និងអ្នកឆ្លើយតបសំណួរដែលជាកសិករចំពោះពេលវេលា និងកិច្ចសហប្រតិបត្តិការដែលការសិក្សាស្រាវជ្រាវនេះមិនអាចសំរេចបានទៅរួចនោះទេបើគ្មានកិច្ចសហការពីគ្រប់ភាគីពាក់ព័ន្ធទាំងនេះ។

# សេចក្តីសង្ខេប


គោលបំណងនៃការសិក្សានេះ គឺសំដៅរៀនសូត្រពីគម្រោងធារាសាស្ត្រនៅកម្ពុជា។ ការសិក្សានេះមានបេសកកម្មវាយតម្លៃសមត្ថភាពប្រព័ន្ធធារាសាស្ត្រ ផលប៉ះពាល់របស់ប្រព័ន្ធលើការផលិតស្រូវ និងស្វែងយល់ពីបញ្ហាប្រឈមនៅក្នុងវិស័យធារាសាស្ត្រ។ កិច្ចការនេះនឹងត្រូវសម្រេចបានដោយការពិនិត្យមើលឯកសារមានស្រាប់ និងដោយការចុះធ្វើការវាយតម្លៃលើប្រព័ន្ធធារាសាស្ត្រចំនួន ១២ នៅក្នុងខេត្តចំនួន ៨ នៅក្នុងតំបន់វាលរាបនៃបឹងទន្លេសាប និងទន្លេមេគង្គក្រោម។ ជាផ្នែកមួយនៃការចុះវាយតម្លៃផ្ទាល់នឹងកន្លែង ក្នុងកំឡុងខែឧសភា និងមិថុនា ប្រព័ន្ធធារាសាស្ត្រចំនួន៤ ត្រូវបានជ្រើសរើសសម្រាប់ការស្ទង់មតិបែបរហ័សជាមួយកសិករចំនួន ១៨០នាក់ ដើម្បីបង្ហាញអត្ថប្រយោជន៍នៃប្រព័ន្ធធារាសាស្ត្រលើដីកសិកម្មដែលមានប្រព័ន្ធធារាសាស្ត្រ ប្រៀបធៀបជាមួយនឹងដីកសិកម្មដែលគ្មានប្រព័ន្ធធារាសាស្ត្រ។

លទ្ធផលនៃការសិក្សាឯកសារមានស្រាប់បង្ហាញថាផ្ទៃដីស្រោចស្រពនៅកម្ពុជា គឺមានភាពមិនដូចគ្នាពីប្រភពមួយទៅប្រភពមួយ។ រាជរដ្ឋាភិបាលកម្ពុជាបានរាយការណ៍ថាផ្ទៃដីស្រោចស្រពក្នុងឆ្នាំ២០១០ គឺមានទំហំ ១,១៦ លានហិកតា ដែលស្មើនឹង ៣៣% នៃផ្ទៃដីដាំដំណាំ ឬ ៤២% នៃដីស្រែ។ តួលេខនេះតំណាងឲ្យកំណើនចំនួន ៥៧៩.០០០ហិកតាពីតួលេខក្នុងឆ្នាំ២០០៥។ កំណើនខ្ពស់នៃផ្ទៃដីមានប្រព័ន្ធធារាសាស្ត្របែបនេះ មិនត្រូវបានគាំទ្រជាក់ស្តែងដោយចំណាយមូលធនជាមធ្យមចំនួន ៣៤ លានដុល្លារក្នុងមួយឆ្នាំនោះទេ សម្រាប់ក្រសួងធនធានទឹកនិងឧតុនិយមពីឆ្នាំ ២០០៦ ដល់ឆ្នាំ ២០០៩។ ផ្ទុយទៅវិញ ធនាគារពិភពលោក (ឆ្នាំ ២០០៩) ដោយផ្អែកលើអង្កេតសង្គមកិច្ចនិងសេដ្ឋកិច្ចកម្ពុជា (CSES) ឆ្នាំ២០០៧ បានលើកឡើងថាផ្ទៃដីស្រោចស្រពនៅកម្ពុជាគឺមានចំនួនប្រហែល ២៥%នៃផ្ទៃដីកសិកម្ម។ ម្យ៉ាងទៀត ទិន្នន័យដែលបានទទួលពីទិន្នន័យឃុំ បានបង្ហាញថា ផ្ទៃដីមានប្រព័ន្ធធារាសាស្ត្រនៅកម្ពុជាគឺ មានចំនួន២១%នៃផ្ទៃដីស្រែក្នុងឆ្នាំ ២០០៨។

តាមរយៈការចុះវាយតម្លៃផ្ទាល់លើប្រព័ន្ធធារាសាស្ត្រចំនួន ១២ នៅក្នុងខេត្តចំនួនប្រាំបី គេបានរកឃើញថាផ្ទៃដីមានប្រព័ន្ធធារាសាស្ត្រគ្របដណ្តប់តែលើ ៣៣% ប៉ុណ្ណោះនៃផ្ទៃដីស្រែវស្សាសរុបនៅក្នុងឃុំចំនួន ២៤ ដែលមានលទ្ធភាពប្រើប្រព័ន្ធធារាសាស្ត្រស្តារឡើងវិញ។ ប្រការនេះបង្ហាញថា ទំហំស្រោចស្រពនៃប្រព័ន្ធធារាសាស្ត្រសម្រាប់ផ្ទៃដីស្រែវស្សាទូទាំងប្រទេសមានទំហំតិចជាង នៅពេលដែលមានឃុំជាច្រើនដែលមិនអាចទទួលការស្រោចស្រពពីប្រព័ន្ធធារាសាស្ត្រដែលបានស្តារឡើងវិញទាំងនេះ។ ការវាយតម្លៃបានបង្ហាញថែមទៀតថានៅក្នុងចំណោមដីស្រែសរុបនៅក្នុងឃុំ មានតែ ៩% ប៉ុណ្ណោះដែលកំពុងផលិតស្រូវដើមរដូវវស្សា (ខែមេសាដល់ខែសីហា) ដោយប្រើទឹកពីប្រព័ន្ធធារាសាស្ត្របំពេញបន្ថែមលើទឹកភ្លៀង និង ៣% បានធ្វើការដាំដំណាំបន្ថែមមួយមុខទៀតក្នុងរដូវប្រាំង (ខែធ្នូដល់ខែមេសា) ដែលពឹងផ្អែកទាំងស្រុងលើទឹកពីប្រព័ន្ធធារាសាស្ត្រទាំងនេះ។

ប្រព័ន្ធធារាសាស្ត្រស្តារឡើងវិញ ជាពិសេសប្រព័ន្ធដែលទទួលហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ជាធម្មតាអាចផ្គត់ផ្គង់ទឹកដើម្បីស្រោចស្រពលើផ្ទៃដីគ្រោងស្រោចស្រពទាំងមូលនៃគម្រោង[1] នៅក្នុងរដូវវស្សា ដោយមានទឹកបំពេញបន្ថែមពីទឹកភ្លៀង ប៉ុន្តែគេឃើញមានបញ្ហាប្រឈមសំខាន់ៗមួយចំនួនផ្សារភ្ជាប់នឹងប្រព័ន្ធនេះ


[1] នៅក្នុងវិស័យធារាសាស្ត្រ ពាក្យ "ផ្ទៃដីគ្រោងស្រោចស្រព-Command Area" គឺសំដៅលើផ្ទៃដីដែលត្រូវបានរៀបចំឲ្យទទួលការស្រោចស្រពពីប្រព័ន្ធធារាសាស្ត្រ។ តាមជាក់ស្តែង ជាញឹកញាប់ប្រព័ន្ធនេះមិនអាចផ្គត់ផ្គង់ទឹកគ្រប់គ្រាន់ឲ្យដល់ផ្ទៃដីគ្រោងស្រោចស្រពទាំងអស់ទេ។ មូលហេតុគឺអាចមកពីកង្វះប្រភពទឹក/ទឹកភ្លៀង និង/ឬ ការសាងសង់មិនមានលក្ខណៈពេញលេញ ។

រួមមាន លទ្ធភាពស្រោចស្រពដោយប្រើប្រាស់ទឹកពីប្រព័ន្ធធារាសាស្ត្រនៅមានកម្រិត កង្វះប្រឡាយចែកចាយទឹកបន្តពីប្រឡាយមេនិងសំណង់ស្ទាក់ទឹក និងការរៀបចំប្រព័ន្ធមិនទាន់បានល្អ។ ផ្អែកលើទិន្នន័យដែលទទួលបានពីប្រព័ន្ធចំនួនប្រាំពីរ ២៣%នៃផ្ទៃដីគ្រោងស្រោចស្រព អាចមានលទ្ធភាពប្រើទឹកពីប្រព័ន្ធធារាសាស្ត្រដែលត្រូវបានកែលម្អសម្រាប់ធ្វើស្រែដើមរដូវវស្សា (ខែមេសាដល់ខែសីហា) ដោយមានទឹកបន្ថែមពីទឹកភ្លៀង ខណៈដែលផ្ទៃដីស្រែ១៣%ផ្សេងទៀតមានលទ្ធភាពដាំដំណាំបន្ថែមមួយមុខទៀតក្នុងរដូវប្រាំង (ខែធ្នូដល់ខែមេសា) លើផ្ទៃដីស្រែវស្សា។

ប្រព័ន្ធធារាសាស្ត្រត្រូវបានសង្កេតឃើញថាបានផ្តល់អត្ថប្រយោជន៍មួយចំនួនជូនកសិករ ដែលរួមមាន ផ្តល់ទឹកបន្ថែមសម្រាប់ស្រោចស្រពស្រូវវស្សា អន្តរាគមន៍នៅពេលមានគ្រោះរាំងស្ងួត ការផលិតដំណាំបន្ថែមមួយមុខទៀតនៅដើមរដូវវស្សាឬរដូវប្រាំង ផលស្រូវកាន់តែខ្ពស់ ទីកន្លែងកំសាន្ត ប្រព័ន្ធរំដោះទឹកដើម្បីរំដោះទឹកលើសចេញពីវាលស្រែនៅពេលចាំបាច់ ការពង្រីកផលិតកម្មបន្លែ ផ្លូវសម្រាប់ការធ្វើដំណើរនិងការដឹកជញ្ជូនធាតុចូលនិងផលិតផលកសិកម្ម ការប្រើប្រាស់របស់គ្រួសារនិងសត្វ និងកំណើនមច្ឆាជាតិ។ ទោះបីជាផ្តល់អត្ថប្រយោជន៍ទាំងនេះក្តី ក៏ដំណើរការប្រព័ន្ធធារាសាស្ត្រទាំងនេះត្រូវជួបប្រទះនឹងបញ្ហាប្រឈមមួយចំនួនរួមមាន ការផ្គត់ផ្គង់ទឹកមិនគ្រប់គ្រាន់ ប្រព័ន្ធមិនមានលក្ខណៈពេញលេញ (ជាពិសេសកង្វះប្រឡាយរងទី៣ និងសំណង់ស្ទាក់ទឹក) គ្មានយន្តការឬមានយន្តការទន់ខ្សោយសម្រាប់ការគ្រប់គ្រងនិងការថែទាំប្រព័ន្ធសហគមន៍កសិករប្រើប្រាស់ទឹក (FWUC) អសកម្ម និង ផលចំណេញទាបពីការផលិតស្រូវដែលបណ្តាលមកពីគុណភាពដីមិនល្អ។

ចំពោះផលប៉ះពាល់នៃប្រព័ន្ធធារាសាស្ត្រ ការស្ទង់មតិបែបរហ័សបានរកឃើញថាប្រព័ន្ធធារាសាស្ត្រមានផលប៉ះពាល់ច្រើនលើជីវភាពរបស់ប្រជាកសិករ។ កសិករភាគច្រើនដែលបានទទួលផលប្រយោជន៍ពីប្រព័ន្ធធារាសាស្ត្របានរាយការណ៍ថា ប្រព័ន្ធធារាសាស្ត្របានធ្វើឲ្យជីវភាពរបស់ពួកគាត់ប្រសើរឡើង ជាពិសេសក្នុងចំណោមកសិករដែលអាចដាំដំណាំបន្ថែមមួយមុខទៀតនៅដើមរដូវវស្សា ឬ ក្នុងរដូវប្រាំង។ តាមការប្រៀបធៀប កសិករដែលមិនមានលទ្ធភាពប្រើឬទទួលប្រយោជន៍ពីប្រព័ន្ធធារាសាស្ត្រ ត្រូវបានរាយការណ៍ថាជីវភាពរបស់ពួកគាត់កាន់តែយ៉ាប់យ៉ឺននៅក្នុងឆ្នាំកន្លងទៅ ដែលមានភាគរយខ្ពស់ជាងកសិករដែលមានលទ្ធភាពប្រើឬទទួលប្រយោជន៍ពីប្រព័ន្ធធារាសាស្ត្រ។

ប៉ុន្តែ ការវាយតម្លៃនៅមូលដ្ឋានផ្ទាល់បានរកឃើញថា ផ្ទៃដីស្រោចស្រពជាក់ស្តែងដែលទទួលបានពីប្រព័ន្ធធារាសាស្ត្រខ្នាតធំទាំងឡាយ និងដែលត្រូវបានស្តារឡើងវិញដោយថវិការបស់រាជរដ្ឋាភិបាលកម្ពុជាគឺនៅមានកម្រិតដោយសារប្រព័ន្ធទាំងនេះមិនត្រូវបានសាងសង់ឬជួសជុលទាំងស្រុងទេ។ ជាធម្មតា ប្រឡាយរងទី៣មិនត្រូវបានសាងសង់ឬជួសជុលនោះទេ។ កិច្ចប្រឹងប្រែងនោះអាចស្តារបានតែក្បាលហុងទឹក និង/ឬប្រឡាយមេ តាមរយៈការងារសំណង់ពីរបីឆ្នាំជាប់ៗគ្នា។ យ៉ាងណាមិញនៅក្នុងករណីខ្លះ ឃុំប្រើមូលនិធិរបស់ខ្លួនដើម្បីស្តារប្រឡាយរងទី៣មួយចំនួន ដើម្បីទាញយកទឹកធារាសាស្ត្រពីប្រឡាយមេបញ្ចូលទៅក្នុងស្រែ។

បញ្ហាប្រឈមគន្លឹះមួយ ដែលធ្វើឲ្យប៉ះពាល់ដល់ដំណើរការប្រកបដោយប្រសិទ្ធភាពនៃប្រព័ន្ធធារាសាស្ត្រត្រូវបានគេសង្កេតឃើញថា គឺផ្សារភ្ជាប់ទៅនឹងកង្វះទឹកធារាសាស្ត្រ។ ចំណុចនេះគឺ បណ្តាលមកពីមូលហេតុមួយចំនួន ពោលគឺហេដ្ឋារចនាសម្ព័ន្ធមិនពេញលេញរួមមាន កង្វះប្រឡាយរងទី៣និងសំណង់ស្ទាក់ទឹក ការរៀបចំប្លង់/ការជួសជុលប្រព័ន្ធមិនបានល្អ ប្រភពទឹកមានកម្រិតដូចជា ស្ទឹងតូចឬអាងស្តុកទឹកដែលអាស្រ័យលើទឹកភ្លៀង ការដណ្តើមយកទឹកពីប្រព័ន្ធឆ្ងាយផ្សេងទៀតនៅខ្សែទឹកខាងលើ និង/ឬ ការស្ទាក់ទឹកធារាសាស្ត្រសម្រាប់ការប្រើប្រាស់ក្នុងគោលបំណងផ្សេងៗទៀត។

# ការរៀនសូត្រពីប្រព័ន្ធធារាសាស្ត្រនៅកម្ពុជា: អត្ថប្រយោជន៍ និងបញ្ហាប្រឈម

## ១. សាវតារ

ផ្ទៃដីដាំដុះនៅកម្ពុជាមានទំហំ២,៨៣លានហិកតា ក្នុងឆ្នាំ២០០៥ (២,៣៧លានហិកតា គឺដីស្រែ)។ ផ្ទៃដីស្រោចស្រពត្រូវបានប៉ាន់ប្រមាណថាមានទំហំ៥៨៨.០០០ ហិកតា ដែលស្មើនឹង២១%នៃផ្ទៃដីដាំដុះ ឬ២៥%នៃផ្ទៃដីស្រែ (រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០០៥)។ តាមរយៈយុទ្ធសាស្ត្រកសិកម្មនិងទឹក (SAW) ឆ្នាំ ២០០៦-១០ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០០៦-២០១០ រាជរដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាមិនត្រឹមតែបង្កើនផ្ទៃដីស្រោចស្រពដល់ ៦៥០.០០០ហិកតាមុនដំណាច់ឆ្នាំ២០១០ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងពង្រីកផ្ទៃដីដាំដុះដល់ ៣,៥ លានហិកតាទៀតផង ដែលនៅក្នុងនោះ ២,៥លានហិកតា គឺសម្រាប់ការផលិតស្រូវ (ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ក្រសួងធនធានទឹក និងឧតុនិយម ឆ្នាំ២០០៧ និងរាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០០៥)។ ប្រសិនបើផ្ទៃដីដាំដុះរីកជាបណ្តើរៗ កំណើននៃផ្ទៃដីស្រោចស្រពនឹងមិនប្រាកដថាមានសមាមាត្រដូចគ្នាទេ។ ប្រសិនបើផ្ទៃដីស្រោចស្រពកើនឡើង វាអាចមានលក្ខណៈយឺតជាងគិតជាភាគរយ។ ឧទាហរណ៍ ប្រសិនបើរាជរដ្ឋាភិបាលកម្ពុជាសម្រេចបានការប្តេជ្ញាបង្កើនផ្ទៃដីដាំដុះ និងផ្ទៃដីស្រោចស្រពដូចដែលត្រូវបានលើកឡើងខាងលើ ទំហំស្រោចស្រពនៃប្រព័ន្ធធារាសាស្ត្រគប្បីតំណាងឲ្យ ១៩%នៃផ្ទៃដីដាំដំណាំ ឬ២៦%នៃផ្ទៃដីស្រែក្នុងឆ្នាំ២០១០។

ក្នុងឆ្នាំ២០១០ ផ្ទៃដីស្រោចស្រពត្រូវបានរាយការណ៍ថាមានចំនួន៤២%នៃផ្ទៃដីស្រែ ដែលមានទំហំប្រហែល ១,១៦ លានហិកតា។ ប្រការនេះបង្ហាញនូវសមិទ្ធផលខ្ពស់មួយ ប្រសិនបើប្រៀបធៀបទៅនឹងចំណុចដៅកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០០៦-១០ ដែលគ្រោងសម្រេចបានផ្ទៃដីមានប្រព័ន្ធធារាសាស្ត្រ ឬប្រព័ន្ធស្រោចស្រពទំហំ ៦៥០.០០០ ហិកតាមុនដំណាច់ឆ្នាំ២០១០។

ម្យ៉ាងទៀត ចំណាយថវិកាជាតិសម្រាប់វិស័យកសិកម្ម ជាពិសេសសម្រាប់ក្រសួងធនធានទឹកនិងឧតុនិយម គឺមានកម្រិតក្នុងអំឡុងឆ្នាំ២០០៦-២០០៩។ ប្រហែល៣%នៃចំណាយថវិកាជាតិសរុបត្រូវបានបែងចែកឲ្យក្រសួងធនធានទឹកនិងឧតុនិយមក្នុងរយៈពេលនេះ (ង៉ោ និង ចាន់ ឆ្នាំ២០១០)។ ចំណាយថវិកាទាបសម្រាប់ក្រសួងធនធានទឹកនិងឧតុនិយម ត្រូវបានពន្យល់មួយផ្នែកដោយការអនុវត្តយឺតនៃប្រព័ន្ធធារាសាស្ត្រធំៗមួយចំនួនដូចជា គម្រោងវិស័យធារាសាស្ត្រភូមិភាគពាយព្យ និងគម្រោងECOSORN (វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជាឆ្នាំ២០០៩)។ តាមរយៈកិច្ចប្រឹងប្រែងវាយតម្លៃមួយ គេបានរកឃើញថាមានបញ្ហាសំខាន់ចំនួនបីដែលបណ្តាលឲ្យមានការយឺតយ៉ាវក្នុងការអនុវត្តគម្រោងរងទាំង១១ ដែលស្ថិតក្រោមគម្រោងវិស័យធារាសាស្ត្រភូមិភាគពាយព្យៈ (១) ចរិតលក្ខណៈគម្រោង ពោលគឺ ពេលវេលាដែលត្រូវការសម្រាប់អាងទន្លេ និងការសិក្សាពីលទ្ធភាពសម្រេចបាននៃការអនុវត្តន៍គម្រោង (២) នីតិវិធីលទ្ធកម្មគម្រោងដ៏ពិបាក និង (៣) កត្តាមនុស្ស ឧទាហរណ៍ ការពឹងផ្អែកលើអ្នកផ្តល់ប្រឹក្សាមកពីខាងក្រៅ និងការផ្លាស់ប្តូរបុគ្គលិកទទួលបន្ទុកនៅក្នុងក្រសួងធនធានទឹក និងឧតុនិយម (វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជាឆ្នាំ២០០៩)។

ជាមួយគោលបំណងរួមនៃការជម្រុញការកាត់បន្ថយភាពក្រីក្រនៅតំបន់ជនបទ តាមរយៈការបង្កើនចំណាយថវិកាសាធារណៈនៅតាមក្រសួងពាក់ព័ន្ធ ដូចជាក្រសួងធនធានទឹកនិងឧតុនិយមជាដើម ការសិក្សា

នេះសំដៅវាយតម្លៃបន្ថែមទៀតលើទំហំស្រោចស្រព អត្ថប្រយោជន៍ ក៏ដូចជាចំណុចខ្លាំង និងបញ្ហាប្រឈមនៃប្រព័ន្ធធារាសាស្ត្រ។ ហេតុដូច្នេះ ការសិក្សានេះមានបំណង:

១. វាយតម្លៃសមត្ថភាពធារាសាស្ត្រ និងឥទ្ធិពលរបស់វាលើការផលិតស្រូវរបស់អ្នកទទួលផលដោយផ្ទាល់(កសិករ)ទាំងក្នុងរដូវវស្សានិងក្នុងរដូវប្រាំង និង

២. យល់ដឹងអំពីជោគជ័យ និងបញ្ហាប្រឈមនានានៅក្នុងប្រព័ន្ធធារាសាស្ត្រ ដូចដែលត្រូវបានយល់ឃើញដោយអាជ្ញាធរមូលដ្ឋាន និងប្រជាជនក្នុងសហគមន៍។

អ្នកនិពន្ធមានក្តីសង្ឃឹមថាលទ្ធផលនៃការសិក្សានេះ នឹងនាំមកនូវភស្តុតាងកាន់តែជាក់ស្តែងថែមទៀតសម្រាប់ការពិភាក្សា និងការពិចារណាបន្ថែមទៀតនៅក្នុងចំណោមអ្នកធ្វើគោលនយោបាយ ប្រទេសម្ចាស់ជំនួយទ្វេភាគីនិងពហុភាគី(ដៃគូអភិវឌ្ឍន៍) អ្នកអនុវត្តឬអ្នកអភិវឌ្ឍន៍ អ្នកស្រាវជ្រាវ និងភាគីពាក់ព័ន្ធផ្សេងទៀតលើការផ្តល់ហិរញ្ញប្បទាន និងការផ្តល់គម្រោងធារាសាស្ត្រ។

## ២. វិធីសាស្ត្រ

ចំពោះទំហំស្រោចស្រពនៃប្រព័ន្ធធារាសាស្ត្រទូទាំងប្រទេស ការសិក្សាដាក់បញ្ចូលការពិនិត្យមើលប្រភពឯកសារមានស្រាប់នានា រួមមានផែនការជាតិ ផែនការនិងយុទ្ធសាស្ត្រតាមវិស័យ និងរបាយការណ៍រួមទាំងឯកសារផ្សេងទៀត។ ជាកិច្ចប្រឹងប្រែងក្នុងការធ្វើត្រីកោណវិធីដើម្បីពិនិត្យលើស្ថិតិជាតិ ការសិក្សាប្រើទិន្នន័យដែលមានពីមូលដ្ឋានទិន្នន័យឃុំជាប្រភពទិន្នន័យមួយសម្រាប់គណនាផ្ទៃដីស្រោចស្រពនៅកម្ពុជា។

ដើម្បីទទួលបានភស្តុតាងបន្ថែមទៀតពីមូលដ្ឋាន ការសិក្សានេះបានពិនិត្យលើប្រព័ន្ធធារាសាស្ត្របញ្ចប់ពេញលេញចំនួន១២ នៅក្នុងខេត្តចំនួនប្រាំបីនៅក្នុងតំបន់វាលរាបនៃបឹងទន្លេសាប និងទន្លេមេគង្គក្រោម។ ការចុះវាយតម្លៃផ្ទាល់នេះ ព្យាយាមកំណត់សក្តានុពលនិងសមត្ថភាពជាក់ស្តែងនៃប្រព័ន្ធទាំងនេះក្នុងការស្រោចស្រពទាំងក្នុងរដូវវស្សា និងរដូវប្រាំង។ ក្នុងចំណោមប្រព័ន្ធទាំង១២ ប្រព័ន្ធចំនួនបួនត្រូវបានជ្រើសរើសសម្រាប់ធ្វើការវិភាគស៊ីជម្រៅលើអត្ថប្រយោជន៍ផ្ទាល់ និងឥទ្ធិពលផ្ទាល់របស់វាលើអ្នកទទួលផល ជាពិសេស ឥទ្ធិពលលើប្រាក់ចំណូលរបស់កសិករទទួលផល។ ប្រព័ន្ធទាំងនេះ ត្រូវបានជ្រើសរើសដោយគិតគូរដល់ភាពជាតំណាងខាងទីតាំងភូមិសាស្ត្រ ម្ចាស់មូលនិធិ និង អាយុកាលនៃប្រព័ន្ធ។

រូប ២.១. ទីតាំងនៃប្រព័ន្ធធារាសាស្ត្រដែលបានចុះសិក្សា




តារាង ២.១. ទីតាំងនៃប្រព័ន្ធធារាសាស្ត្រដែលបានចុះសិក្សា

| ល.រ | ឈ្មោះនៃប្រព័ន្ធធារាសាស្ត្រ | ម្ចាស់មូលនិធិធំៗ | ឃុំ | ស្រុក | ខេត្ត |
|---|---|---|---|---|---|
| ១ | ត្រាំម្នាស់ | ADB | ត្នោតជុំ | ក្រគរ | ពោធិ៍សាត់ |
| ២ | ជ្រៃជើង និង ម្រះព្រៅ | EU | ជ្រៃ | មោងឫស្សី | បាត់ដំបង |
| ៣ | ប្រឡាយលេខ ១ | ADB | ខ្នាចរមាស រូងជ្រៃ និង បន្សាយត្រែង | ថ្មគោល និង ថ្មគោល | បាត់ដំបង |
| ៤ | ពន្លៃ | ADB | ពន្លៃ និងផ្គាំ | ភ្នំស្រុក និង ស្វាយចេក | បន្ទាយមានជ័យ |
| ៥ | ទានកាំ – បន្ទាត់បោះ | EU | ទានកាំ | ព្រះនេត្រព្រះ | បន្ទាយមានជ័យ |
| ៦ | ទំនប់រំដេង | EU | ខ្នារពោធិ៍ | សូទ្រនិគម | សៀមរាប |
| ៧ | សាមសិប កញ្ញា | RGC | ដំរីស្លាប់ | កំពង់ស្វាយ | កំពង់ធំ |
| ៨ | ស្ទឹងជីនិត | ADB | ប្រាសាទ កំពង់ថ្ម និង បឹងល្វា | សន្ទុក | កំពង់ធំ |
| ៩ | ប្រឡាយរួមស្រុក | RGC | ជាខ្លាង និង ជ្រៃ | ស្វាយអន្ទរ | ព្រៃវែង |
| ១០ | ត្រដែត | IMF | ព្រះពន្លា | កំពង់រោទិ៍ | ស្វាយរៀង |
| ១១ | ដងខ្ចម | RGC | ស្រង៉ែ និង រកាក្រៅ | ទ្រាំង និង ដូនកែវ | តាកែវ |
| ១២ | បន្ទាយធ្លាយ | EU/AusAid | ក្រពុំឈូក ព្រៃខ្លា ព្រៃយុថ្កា និងរមេញ | កោះអណ្ដែត | តាកែវ |

សម្រាប់ប្រព័ន្ធធារាសាស្ត្រនីមួយៗ ក្រុមសិក្សាមួយដែលមានសមាជិកចំនួន៨នាក់បានចុះធ្វើការសម្ភាសន៍ ១) សមាជិកក្រុមប្រឹក្សាឃុំ ២) សហគមន៍កសិករប្រើប្រាស់ទឹក ៣) បុគ្គលិកគម្រោងប្រសិនបើមាន និង៤) កសិករឈានមុខដើម្បីវាយតម្លៃសមត្ថភាពជាក់ស្តែងនៃប្រព័ន្ធនៅក្នុងរដូវប្រាំង និងប្រយោជន៍របស់វានៅក្នុងរដូវវស្សា។ ក្រុមចុះមូលដ្ឋានបានចំណាយពេលមួយឬពីរថ្ងៃដើម្បីសិក្សាប្រព័ន្ធមួយ ដោយអាស្រ័យលើទំហំរបស់ប្រព័ន្ធ។ ប៉ុន្តែ សម្រាប់ការវិភាគស៊ីជម្រៅបន្ថែម ជាពិសេសការវិភាគលើអត្ថប្រយោជន៍នៃប្រព័ន្ធធារាសាស្ត្រចំនួនបួនក្នុងចំណោមប្រព័ន្ធចំនួន១២ ត្រូវបានជ្រើសរើស ហើយកសិករប្រមាណ៤៥នាក់ក្នុងមួយប្រព័ន្ធត្រូវបានសម្ភាសន៍។ តួលេខនេះរួមមាន កសិករចំនួន១៥នាក់ ដែលប្រើទឹកពីប្រព័ន្ធធារាសាស្ត្រសម្រាប់ស្រោចស្រពស្រែប្រាំង កសិករចំនួន១៥នាក់ដែលប្រើទឹកពីប្រព័ន្ធសម្រាប់ស្រោចស្រពនៅក្នុងរដូវវស្សា និងកសិករចំនួន១៥នាក់ដែលមិនបានទទួលផលប្រយោជន៍ពីប្រព័ន្ធធារាសាស្ត្រ ដោយសារដីស្រែរបស់ពួកគាត់មិនស្ថិតនៅក្នុងផ្ទៃដីគ្រោងស្រោចស្រព។ ក្រុមចុះមូលដ្ឋានបានចំណាយពេលមួយថ្ងៃថែមទៀតដើម្បីសម្ភាសន៍កសិករចំនួន៤៥នាក់ ដែលត្រូវបានជ្រើសរើសឲ្យតំណាងឲ្យក្រុមពួកគាត់រៀងៗខ្លួន។

## ៣. ការត្រួតពិនិត្យទំហំស្រោចស្រពនៃប្រព័ន្ធធារាសាស្ត្រនៅកម្ពុជា

ជំពូកនេះសំដៅពិនិត្យមើលទំហំស្រោចស្រព នៃប្រព័ន្ធធារាសាស្ត្រនៅកម្ពុជាដោយផ្អែកលើទិន្នន័យដែលទទួលបានពីប្រភពឯកសារមានស្រាប់ ដែលរួមមានឯកសាររបស់រាជរដ្ឋាភិបាល ដូចជា ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ(NSDP) SAW និងASSDP។ សៀវភៅទិន្នន័យខេត្តដែលទទួលបានពីគេហទំព័ររបស់គណៈកម្មាធិការជាតិសម្រាប់អភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(NCDD) និងដែលផ្អែកលើមូលដ្ឋានទិន្នន័យឃុំ ក៏ត្រូវបានប្រើផងដែរជាឯកសារយោងសម្រាប់ការត្រួតពិនិត្យនេះ។

តាមរយៈការសិក្សាលើឯកសារមានស្រាប់ ស្ថិតិស្តីពីទំហំស្រោចស្រពនៃប្រព័ន្ធធារាសាស្ត្រនៅកម្ពុជាមានលក្ខណៈច្របូកច្របល់ ដោយសារជួនកាលវាត្រូវបានរាយការណ៍ជាភាគរយនៃផ្ទៃដីដាំដំណាំ ចំនែកឯក្នុងករណីផ្សេងទៀត វាត្រូវបានចាត់ទុកជាភាគរយនៃដីស្រែ។ ប្រការនេះទំនងជាត្រូវបានពន្យល់ដោយកង្វះទិន្នន័យរាយនៃផ្ទៃដីមានប្រព័ន្ធធារាសាស្ត្រ។ ឧទាហរណ៍ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិជាលំដាប់នៅតែរាយការណ៍ចំណុចខាងក្រោមៈ ដីដាំដំណាំ ផ្ទៃដីស្រោចស្រព និងផ្ទៃដីធ្វើស្រែ។ ផ្ទៃដីស្រោចស្រពដែលជាផ្នែកមួយនៃដីដាំដំណាំគប្បីមានទំហំខុសគ្នាពីផ្ទៃដីស្រោចស្រពដែលជាផ្នែកមួយនៃផ្ទៃដីធ្វើស្រែ ដោយសារដីធ្វើស្រែគ្រាន់តែជាផ្នែកមួយនៃដីដាំដំណាំប៉ុណ្ណោះ។ ប៉ុន្តែ ស្ថិតិដែលទទួលបានពីឯកសារមានស្រាប់មានភាពខ្វះខាតក្នុងការបំបែកទិន្នន័យសំរាប់ពន្យល់បន្ថែម ដែលជាហេតុមួយធ្វើឲ្យមានភាពច្របូកច្របល់។ ភាពច្របូកច្របល់នេះបន្តឲ្យមានចម្ងល់អំពីរបៀបដែលទិន្នន័យអំពីផ្ទៃដីស្រោចស្រពដែលត្រូវបានប្រមូល និងចងក្រង។

ដោយសារកង្វះស្ថិតិរាយអំពីផ្ទៃដីស្រោចស្រព ការត្រួតពិនិត្យនេះមិនបានសន្មតថាផ្ទៃដីស្រោចស្រពដែលត្រូវបានរាយកាណ៍គឺជាផ្នែកមួយនៃដីដាំដំណាំ ឬដីធ្វើស្រែនោះទេ ប៉ុន្តែចាត់ទុកវាជាស្ថិតិដែលដឹងតែមួយគត់ និងព្យាយាមសិក្សាវាពាក់ព័ន្ធនឹងទិដ្ឋភាពទាំងពីរ ពោលគឺដីដាំដំណាំ និងដីធ្វើស្រែ។ ចំពោះផ្ទៃដីធ្វើស្រែដែលមានលទ្ធភាពទទួលបានការស្រោចស្រព របាយការណ៍នេះសន្មតថាផ្ទៃដីធ្វើស្រែក្នុងរដូវប្រាំងត្រូវបានស្រោចស្រពទាំងអស់ដោយសារពុំមានភ្លៀងនៅក្នុងរដូវនេះ។ ចំណុចទាំងនេះគប្បីជួយផ្ទៀងផ្ទាត់ និងផ្តល់នូវទំហំផ្ទៃដីស្រោចស្រពនៃប្រព័ន្ធធារាសាស្ត្រនៅក្នុងវិស័យកសិកម្មកម្ពុជា។

ដូចមានបង្ហាញជូនក្នុងតារាង៣.១ ផ្ទៃដីស្រោចស្រពគឺមានទំហំ ៥៨៨.០០០ហិកតាក្នុងឆ្នាំ២០០៥ ដែលជាតួលេខចំណុចចាប់ផ្តើមសម្រាប់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០០៦-២០១០(រាជរដ្ឋាភិបាលកម្ពុជាឆ្នាំ២០០៥) ដែលតំណាងឲ្យ២១% នៃដីដាំដំណាំនៅពេលនោះ ឬ ២៥%នៃផ្ទៃដីធ្វើស្រែនៅពេលនោះ។ ដោយផ្អែកលើតួលេខនេះ រាជរដ្ឋាភិបាលកម្ពុជាមានបំណងបង្កើនទំហំស្រោចស្រពនៃប្រព័ន្ធធារាសាស្ត្រដល់ ៦៥០.០០០ហិកតា មុនដំណាច់ឆ្នាំ២០១០ ដែលគប្បីតំណាងឲ្យ១៩% និង២៦%នៃផ្ទៃដីដាំដំណាំ និងផ្ទៃដីធ្វើស្រែនៅក្នុងឆ្នាំនោះ។ ប្រការនេះមានន័យថាផ្ទៃដីស្រោចស្រព មិនគួររួមចំណែកច្រើនដល់ការប្រែប្រួលចំពោះទំហំ(លទ្ធភាព)ស្រោចស្រពនៃប្រព័ន្ធធារាសាស្ត្រគិតជាភាគរយទេ ដោយសារដីដាំដំណាំ និងផ្ទៃដីធ្វើស្រែ ក៏មុខជាកើនឡើងផងដែរ នៅក្នុងរយៈពេលនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០០៦-២០១០។

តារាង ៣.១. ការប្រែប្រួលនៃទំហំស្រោចស្រពនៃប្រព័ន្ធធារាសាស្ត្រនៅកម្ពុជា យោងតាមការរាយការណ៍នៅថ្នាក់ជាតិ

| | | មូលដ្ឋាន និងចំណុចដៅ | | វឌ្ឍនភាព | | |
|---|---|---|---|---|---|---|
| | | NSDP ២០០៦-១០ | | NSDP MTR | NSDP Update | MOWRAM |
| | ឆ្នាំ | ២០០៥ | ២០១០ | ២០០៨ | ២០០៨ | ២០១០ |
| **ដីដាំដំណាំ** | **(០០០ ហត)** | **២.៨៣៥** | **៣.៥០០** | **៣.៣០០** | **៣.២១១** | **៣.៥៤៧** |
| ស្រែ | (០០០ ហត) | ២.៣៧៤ | ២.៥០០ | ២.៦០០ | ២.៦១៥ | ២.៧៩៥ |
| ស្រូវវស្សា | (០០០ ហត) | ២.០៦២ | ២.១៦០ | ២.២៤០ | ២.២៥៥ | ២.៣៩១ |
| ស្រូវប្រាំង | (០០០ ហត) | ៣១២ | ៣៤០ | ៣៦០ | ៣៦០ | ៤០៤ |
| ផ្ទៃដីស្រោចស្រព | (០០០ ហត) | ៥៨៨ | ៦៥០ | ៨២៧ | ១.១២០ | ១.១៦៧ |
| ទំហំស្រោចស្រពក្នុងរដូវវស្សា | (០០០ ហត) | ២៧៦ | ៣១០ | ៤៦៧ | ៧៦០ | ៧៦៣ |
| ទំហំស្រោចស្រពក្នុងរដូវប្រាំង | (០០០ ហត) | ៣១២ | ៣៤០ | ៣៦០ | ៣៦០ | ៤០៤ |
| **ផ្ទៃដីស្រោចស្រព / ដីដាំដំណាំ** | **%** | **២១%** | **១៩%** | **២៥%** | **៣៥%** | **៣៣%** |
| **ផ្ទៃដីស្រោចស្រព /ដីស្រែ** | **%** | **២៥%** | **២៦%** | **៣២%** | **៤៣%** | **៤២%** |
| ទំហំស្រោចស្រពក្នុងរដូវវស្សា | % | ១៣% | ១៤% | ២១% | ៣៤% | ៣២% |
| ទំហំស្រោចស្រពក្នុងរដូវប្រាំង | % | ១០០% | ១០០% | ១០០% | ១០០% | ១០០% |

*ការគណនារបស់អ្នកនិពន្ធ*

*ប្រភព: ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ ២០០៦-១០ របាយការណ៍វាយតម្លៃពាក់កណ្តាលអាណត្តិនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០០៨ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ឆ្នាំ២០០៩-១៣ និងស្ថិតិរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។*

ពិនិត្យមើលវឌ្ឍនភាពក្នុងឆ្នាំ២០០៨ របាយការណ៍វាយតម្លៃពាក់កណ្តាលអាណត្តិនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០០៨) បានបង្ហាញថា ទំហំស្រោចស្រពនៃប្រព័ន្ធធារាសាស្ត្របានកើនឡើងដល់ ៨២៧.០០០ហិកតា (រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០០៨) ដែលស្មើនឹង២៥% និង ៣២%នៃដីដាំដំណាំនិងផ្ទៃដីធ្វើស្រែ។ កំណើននេះភាគច្រើនហាក់បីដូចជា បណ្តាលមកពីការបង្កើនទំហំស្រោចស្រពនៃប្រព័ន្ធធារាសាស្ត្រលើផ្ទៃដីស្រែវស្សា។ ថ្វីបើផ្ទៃដីស្រែក្នុងរដូវវស្សាក្នុងឆ្នាំ២០០៨ បានកើនឡើងប្រហែល៧០% ពីផ្ទៃដីធ្វើស្រែរដូវវស្សាក្នុងឆ្នាំ២០០៥ក៏ដោយ ក៏២១%នៃផ្ទៃដីស្រែវស្សាក្នុងឆ្នាំ២០០៨ ត្រូវបានស្រោចស្រពដែរ ដែលបង្ហាញថាមានកំណើន៥៦% ពីផ្ទៃដីធ្វើស្រែរដូវវស្សាក្នុងឆ្នាំ២០០៥។

ទំហំស្រោចស្រពនៃប្រព័ន្ធធារាសាស្ត្រក្នុងឆ្នាំ២០០៨ ហាក់បីដូចជាមានវិសាលភាពធំជាងនៅពេលរាយការណ៍ក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្មឆ្នាំ២០០៩-២០១៣ (រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០១០)។ ក្នុងនោះមានសេចក្តីរាយការណ៍ថាផ្ទៃដីទំហំ ១,១២ លានហិកតាត្រូវបានស្រោចស្រព ដែលមានទំហំ ៤១% ធំជាងតួលេខដែលរាយការណ៍នៅក្នុងរបាយការណ៍វាយតម្លៃពាក់កណ្តាលអាណត្តិនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិក្នុងឆ្នាំ២០០៨។ គិតជាភាគរយ ចំណុចនេះមានន័យថាទំហំស្រោចស្រពនៃប្រព័ន្ធធារាសាស្ត្រ គឺមានទំហំ៣៥%នៃផ្ទៃដីដាំដំណាំ ឬ៤៣%នៃផ្ទៃដីស្រែ ដែលនេះមានភាពខុសគ្នាខ្លាំងពីតួលេខ ២៥% និង៣២% ដែលបានរាយការណ៍នៅក្នុងរបាយការណ៍វាយម្លៃពាក់កណ្តាលអាណត្តិនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០០៨។ ភាពខុសគ្នាច្រើនបែបនេះនៃទំហំស្រោចស្រពនៃប្រព័ន្ធធារាសាស្ត្រដែលបានរាយការណ៍ក្នុងឆ្នាំ២០០៨ បង្ហាញថាស្ថិតិមានភាពមិនស្របគ្នា និងគួរមានការពិនិត្យមើលនិង/ឬការពន្យល់បន្ថែមពីក្រសួងធនធានទឹកនិងឧតុនិយម។

ក្នុងឆ្នាំ២០១០ ផ្ទៃដីស្រោចស្រពសរុបត្រូវបានរាយការណ៍ថាបានកើនឡើងថែមទៀតដល់ ១,១៦ លានហិកតា ដែលប្រហែលនឹង៣៣%និង៤២% នៃផ្ទៃដីដាំដំណាំនិងផ្ទៃដីធ្វើស្រែ។ ទំហំស្រោចស្រពនេះបែរជាមានទំហំតូចជាង ប្រសិនបើប្រៀបធៀបទៅនឹងទំហំស្រោចស្រពក្នុងឆ្នាំ២០០៨ដោយសារផ្ទៃដីដាំដំណាំនិងផ្ទៃដីស្រែបានរីកលឿនជាងនៅក្នុងរយៈពេលដូចគ្នា។ យោងតាមទំហំស្រោចស្របនៃប្រព័ន្ធធារាសាស្ត្រដែលបានរាយការណ៍ក្នុងឆ្នាំ២០១០ ផ្ទៃដីស្រែស្រូវវស្សាដែលទទួលបានការស្រោចស្រព គួរមានទំហំ ៧៦៣.០០០ហិកតា ដែលប្រហែលនឹង៣២%នៃផ្ទៃដីស្រែវស្សា (ប្រសិនបើស្រែប្រាំងទាំងអស់ត្រូវបានសន្មតថាត្រូវបានស្រោចស្រព) ខណៈដែលផ្ទៃដីស្រែនៅសល់ពឹងផ្អែកលើទឹកភ្លៀងទាំងស្រុង។

តារាង៣.១ បង្ហាញថាទំហំស្រោចស្រពនៃប្រព័ន្ធធារាសាស្ត្រទំហំ១,១៦លានហិកតា ក្នុងឆ្នាំ២០១០ បានកើនឡើងទ្វេដងពីទំហំស្រោចស្រពនៃប្រព័ន្ធធារាសាស្ត្រក្នុងឆ្នាំ២០០៥ ដែលបានបង្ហាញពីកំណើនចំនួន ៥៧៩.០០០ ហិកតា ឬ ៨០% លើសចំណុចដៅដែលបានកំណត់។ ប្រការនេះបង្ហាញនូវសមិទ្ធផលដ៏គួរឲ្យកត់សម្គាល់មួយ ប៉ុន្តែវាគួរមានអំណះអំណាងដើម្បីពន្យល់កំណើនដ៏ច្រើនបែបនេះនៃផ្ទៃដីមានប្រព័ន្ធធារាសាស្ត្រស្រោចស្រព។ ភស្តុតាងបានបង្ហាញថាផ្ទៃដីស្រោចស្រពបានកើនឡើងប្រហែល ១៩០.០០០ ហិកតា ប៉ុណ្ណោះពីឆ្នាំ២០០១ ដល់ឆ្នាំ២០០៥ (រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០១០)។ ផ្ទុយទៅវិញ ចំណាយសាធារណៈមិនទំនងជាពន្យល់ពីកំណើនទាំងស្រុងនៃផ្ទៃដីស្រោចស្រពនៅក្នុងអំឡុងពេលនេះទេ[2]។ ដោ៉និងចាន់ (ឆ្នាំ

[2] បទសម្ភាសន៍ជាមួយវិស្វករមួយរូបនៃមន្ទីរធនធានទឹកនិងឧតុនិយមខេត្ត បង្ហាញថាតម្លៃមធ្យមសម្រាប់ស្តារទ្វារទឹកមួយគឺប្រហែល ៦០០-៨០០ ដុល្លារអាមេរិកក្នុងមួយហិកតា និង ពី ១.០០០ ដល់ ២.០០០ ដុល្លារអាមេរិកក្នុងមួយហិកតាសម្រាប់ការស្តារប្រព័ន្ធទាំងស្រុងមួយ។ លើសពីនេះទៀត គម្រោងយុទ្ធសាស្ត្រគ្រប់គ្រងធារាស្ត្រមួយរបស់ចិន (Hegemonization of Irrigation Strategy Project) មានតម្លៃ ១.២០០ ដុល្លារអាមេរិកក្នុងមួយហិកតា។ តម្លៃមធ្យមសម្រាប់គម្រោងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី គឺ

២០១០)បានបង្ហាញថា ចំណាយមូលធនសរុបសម្រាប់ក្រសួងធនធានទឹកនិងឧតុនិយម (រួមទាំងហិរញ្ញប្បទាន របស់ម្ចាស់ជំនួយ) គឺប្រហែល ៣៤លានដុល្លារអាមេរិកក្នុងមួយឆ្នាំ ចាប់គិតពីឆ្នាំ២០០៦ ដល់ឆ្នាំ ២០០៩។

ផ្អែកលើអង្កេតជាតិ(អង្កេតសេដ្ឋកិច្ចសង្គមកម្ពុជាឆ្នាំ២០០៧) ធនាគារពិភពលោក(ឆ្នាំ២០០៩)បាន បង្ហាញថាភូមិមួយនៅកម្ពុជាជាមធ្យមមានដីកសិកម្មចំនួន២៤៦ហិកតា ដែលនៅក្នុងនោះ៦១ហិកតាត្រូវបាន ស្រោចស្រព។ ប្រការនេះបង្ហាញថាផ្ទៃដីស្រោចស្រពនៅកម្ពុជា គឺមានប្រហែល២៥% នៃផ្ទៃដីកសិកម្មសរុប ក្នុងឆ្នាំ២០០៧។

ធនាគារពិភពលោក (ឆ្នាំ ២០០៦) បានរាយការណ៍ថាមានតែប្រហែល ១០ភាគរយនៃផ្ទៃដីស្រែ ឬ ២៥៦.០០០ហិកតាប៉ុណ្ណោះ ដែលត្រូវបានស្រោចស្រពប្រកបដោយប្រសិទ្ធភាព ដោយសារសមត្ថភាពផ្គត់ ផ្គង់ទឹកពីប្រព័ន្ធធារាសាស្ត្រទាំងនោះជាទូទៅត្រូវបានរំខានដោយស្ថានភាពទ្រុឌទ្រោម ការគូសប្លង់ដំបូងមិន ល្អ និងការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រមិនទាន់បានគ្រប់ជ្រុងជ្រោយ។ របាយការណ៍នេះបានកត់ សម្គាល់ថែមទៀតថា ទំហំស្រោចស្រពនៃប្រព័ន្ធធារាសាស្ត្រគឺមានទំហំកាន់តែតូចក្នុងរដូវប្រាំង។ ការប៉ាន់ ប្រមាណលើទំហំស្រោចស្រពនៃប្រព័ន្ធធារាសាស្ត្រនេះ ហាក់បីដូចជាតូចជាងច្រើនប្រសិនបើប្រៀបធៀបទៅ នឹងការប៉ាន់ប្រមាណដែលត្រូវបានរាយការណ៍ដោយរាជរដ្ឋាភិបាលកម្ពុជាខាងលើ។ ប៉ុន្តែភាពខុសគ្នានេះអាច បណ្តាលមកពីការមានទស្សនៈខុសគ្នាអំពីនិយមន័យ និងរង្វាស់លើទំហំស្រោចស្រពនៃប្រព័ន្ធធារាសាស្ត្រ។

តារាង៣.២ បង្ហាញទំហំស្រោចស្រពនៃប្រព័ន្ធធារាសាស្ត្រនៅកម្ពុជា ក្នុងឆ្នាំ២០០៨ ដោយផ្អែកលើ ទិន្នន័យ ដែលមានពីសៀវភៅទិន្នន័យខេត្ត ដែលត្រូវបានដាក់នៅក្នុងវែបសាយរបស់ NCDD[3]។ តារាងនេះ បង្ហាញថាមានតែ៨%ប៉ុណ្ណោះនៃដីធ្វើស្រែក្នុងរដូវវស្សា ដែលមានប្រព័ន្ធធារាសាស្ត្រប្រើ។ ខណៈដែលផ្ទៃដី ធ្វើស្រែទាំងអស់ក្នុងរដូវប្រាំងគួរតែមានប្រព័ន្ធធារាសាស្ត្រប្រើក្តី គេឃើញផ្ទៃដីស្រោចស្រពសរុបមានប្រហែល តែ២១%នៃផ្ទៃដីធ្វើស្រែសរុបប៉ុណ្ណោះ ក្នុងឆ្នាំ២០០៨។

ក្រៅពីការបង្ហាញពីទំហំស្រោចស្រពនៃប្រព័ន្ធធារាសាស្ត្រ តារាង៣.២ក៏បង្ហាញផងដែរនូវការប្រើដី ស្រែមិនអស់លទ្ធភាពទាំងនៅក្នុងរដូវវស្សានិងរដូវប្រាំង។ ទិន្នន័យនេះបង្ហាញថា មានដីស្រែចំនួន ៣.១២៩.០០០ ហិកតា សម្រាប់ការផលិតស្រូវ (២.៧០៣.០០០ ហិកតាក្នុងរដូវវស្សា និង ៤២៦.០០០ ហិកតាក្នុងរដូវប្រាំង)។ ប៉ុន្តែ មានតែប្រហែល៨០%នៃផ្ទៃដីទាំងនេះប៉ុណ្ណោះ ដែលត្រូវបានធ្វើស្រែក្នុងឆ្នាំ ២០០៨ ខណៈដែលផ្ទៃដី២០%ដែលនៅសល់ (៥២០.០០០ហិកតាក្នុងរដូវវស្សា និង៦២.០០០ហិកតាក្នុង រដូវប្រាំង) ត្រូវបានទុកនៅទំនេរ។ ចំណុចនេះបង្ហាញពីសក្តានុពលមួយសម្រាប់ការពង្រីកផ្ទៃដីផលិតស្រូវ បន្ថែមទៀតនៅក្នុងរដូវទាំងពីរចាប់តាំងពីឆ្នាំ២០០៨។

ខ្ពស់ជាងច្រើន ដែលអាចត្រូវបានពន្យល់ដោយគុណភាពខុសគ្នា ឬ ការដាក់បញ្ចូលសមាសភាគនៃគម្រោងផ្សេងទៀត ដូចជា ការ បង្កើត សហគមន៍កសិករប្រើប្រាស់ទឹក (FWUC) និងសេវាផ្សព្វផ្សាយ។ គម្រោងវិស័យធារាសាស្ត្រភូមិភាគពាយព្យ និងប្រព័ន្ធធារា សាស្ត្រស្ទឹងជីនិត មានតម្លៃ ២.៩០០ ដុល្លារអាមេរិកក្នុងមួយហិកតា។

[3] www.ncdd.gov.kh (មើលនៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ ២០១១)។ សៀវភៅទិន្នន័យខេត្តផ្អែកលើមូលដ្ឋានទិន្នន័យឃុំ ដែលរក្សា ទុកទិន្នន័យដែលប្រមូលដោយប្រធានភូមិ និងស្មៀនឃុំរៀងរាល់ឆ្នាំនៅដំណាច់ឆ្នាំ។

តារាង ៣.២. ទំហំស្រោចស្រពនៃប្រព័ន្ធធារាសាស្ត្រនៅកម្ពុជា ឆ្នាំ ២០០៨

| | | ដីស្រែ (០០០ ហិកតា) | | | | | | |
|---|---|---|---|---|---|---|---|---|
| | | ផ្ទៃដីរដូវវស្សា | | | ផ្ទៃដីរដូវប្រាំង | | សរុប (វស្សា + ប្រាំង) | |
| លរ | ខេត្ត | មាន | ដាំដុះ | ស្រោចស្រព | មាន | ដាំដុះ* | ដាំដុះ | ស្រោចស្រព |
| ១ | បាត់ដំបង | ៣១១ | ២៧៣ | ៩% | ៨,៨ | ៦,៣ | ២៧៩ | ១១% |
| ២ | បន្ទាយមានជ័យ | ៣៤៨ | ២៤៤ | ៣% | ២,៩ | ២,៤ | ២៤៦ | ៤% |
| ៣ | កំពង់ចាម | ១៦៣ | ១៥៣ | ១២% | ៧១ | ៥៧,២ | ២១០ | ៣៦% |
| ៤ | កំពង់ឆ្នាំង | ១០៩ | ១០២ | ១៧% | ២៣,៨ | ២២ | ១២៤ | ៣២% |
| ៥ | កណ្តាល | ៤៥ | ៤១ | ២៩% | ៨៣,៥ | ៦៦,៧ | ១០៨ | ៧៣% |
| ៦ | កែប | ៣ | ៣ | ៩% | ០,១ | ០,១ | ៣ | ១៣% |
| ៧ | កោះកុង | ១១ | ៧ | ០% | ០,៤ | - | ៧ | ០% |
| ៨ | កំពង់ស្ពឺ | ២៩០ | ១០៧ | ៥% | ២,៥ | ១,១ | ១០៨ | ៦% |
| ៩ | កំពត | ១១៣ | ១១៣ | ៣% | ៤,៣ | ៣,៥ | ១១៦ | ៦% |
| ១០ | ក្រចេះ | ៣២ | ៣១ | ៩% | ១៥,២ | ១៣,៤ | ៤៤ | ៣៧% |
| ១១ | កំពង់ធំ | ១៧៩ | ១៥៨ | ៩% | ២៥ | ១៨,២ | ១៧៦ | ១៨% |
| ១២ | មណ្ឌលគិរី | ២៤ | ១៥ | ០% | ០ | - | ១៥ | ០% |
| ១៣ | ឧត្តរមានជ័យ | ១៣៩ | ៥២ | ០% | ០,១ | ០ | ៥២ | ០% |
| ១៤ | ប៉ៃលិន | ៤ | ២ | ១៤% | ១,៣ | ០,៩ | ៣ | ៣៩% |
| ១៥ | ពោធិ៍សាត់ | ៩៨ | ៧៧ | ១៤% | ៤,១ | ២,៨ | ៨០ | ១៧% |
| ១៦ | ព្រៃវែង | ២២១ | ២០៧ | ១៣% | ៧២,៩ | ៦៨ | ២៧៥ | ៣៥% |
| ១៧ | ព្រះវិហារ | ៣៦ | ៣៥ | ០% | ០,១ | ០ | ៣៥ | ០% |
| ១៨ | រតនគិរី | ៣៤ | ២៦ | ០% | ០,៣ | ០ | ២៦ | ០% |
| ១៩ | ព្រះសីហនុ | ១៥ | ១៤ | ០% | - | - | ១៤ | ០% |
| ២០ | ស្វាយរៀង | ១៥២ | ១៧៧ | ០% | ១៣,៧ | ១២,៦ | ១៨៩ | ៧% |
| ២១ | សៀមរាប | ១៩៥ | ១៧២ | ៥% | ១៦,៥ | ១៤,២ | ១៨៦ | ១២% |
| ២២ | ស្ទឹងត្រែង | ២៤ | ២១ | ០% | - | - | ២១ | ០% |
| ២៣ | តាកែវ | ១៥៧ | ១៥៥ | ៩% | ៧៩,៧ | ៧៥,២ | ២៣១ | ៣៩% |
| | សរុប | ២.៧០៣ | ២.១៨៣ | ៨% | ៤២៦ | ៣៦៥ | ២.៥៤៨ | ២១% |

* ដីដាំដុះទាំងអស់ត្រូវបានស្រោចស្រពក្នុងរដូវប្រាំង

*ប្រភព: ការគណនារបស់អ្នកនិពន្ធដោយផ្អែកលើសៀវភៅទិន្នន័យស្រុកនិងខេត្តរបស់ NCDD។*

# ៤. ការសង្កេតផ្ទាល់លើករណីធារាសាស្ត្រ

ជំពូកនេះផ្តល់សេចក្តីសង្ខេបមួយអំពីអត្ថប្រយោជន៍ និងបញ្ហាប្រឈមនានា ដែលត្រូវបានសង្កេតឃើញនៅក្នុងប្រព័ន្ធធារាសាស្ត្រដែលបានសិក្សា ហើយករណីសិក្សាដោយឡែកអំពីប្រព័ន្ធធារាសាស្ត្រទាំង ១២ នឹងត្រូវបានបង្ហាញក្នុងផ្នែកបន្ទាប់ ។

## ៤.១. អត្ថប្រយោជន៍ពីប្រព័ន្ធធារាសាស្ត្រ

នៅក្នុងប្រព័ន្ធទាំងអស់ដែលបានសិក្សា ប្រជាកសិករក៏ដូចជាអាជ្ញាធរមូលដ្ឋានបានសម្តែងការរីករាយ និងការពេញចិត្តរបស់ពួកគាត់ចំពោះអត្ថប្រយោជន៍ពីប្រព័ន្ធធារាសាស្ត្រ ដែលបានកែលម្អ។ ការសង្កេតករណីធារាសាស្ត្រនៅក្នុងប្រព័ន្ធទាំង១២ បង្ហាញថាកិច្ចប្រឹងប្រែងស្តារនីតិសម្បទាបាននាំមកនូវអត្ថប្រយោជន៍ជាច្រើនជូនកសិករ។ អត្ថប្រយោជន៍ទាំងនោះ រួមមានៈ

- ផ្ទៃដីស្រោចស្រពមានកាន់តែច្រើន (បំពេញបន្ថែមលើទឹកភ្លៀងក្នុងរដូវវស្សា)
- អន្តរាគមន៍ក្នុងពេលមានគ្រោះរាំងស្ងួត
- ផលិតដំណាំបន្ថែមនៅដើមរដូវវស្សា (មេសា-សីហា) ឬ រដូវប្រាំង(ធ្នូ-មេសា) លើផ្ទៃដីស្រែវស្សា
- ផលស្រូវមានភាពល្អប្រសើរ
- ប្រព័ន្ធរំដោះទឹកដើម្បីរំដោះទឹកលើសចេញពីវាលស្រែនៅពេលចាំបាច់
- ការផលិតបន្លែមានការកើនឡើង
- លទ្ធភាពប្រើផ្លូវលើខ្នងប្រឡាយសម្រាប់ធ្វើដំណើរនិងដឹកជញ្ជូនធាតុចូលនិងផលិតផលកសិកម្ម
- ទីកន្លែងសម្រាប់កំសាន្តនៅខាងក្រៅ
- ការប្រើប្រាស់សំរាប់គ្រួសារនិងសត្វ និង
- មច្ឆាជាតិមានការកើនឡើង។

<u>ផ្ទៃដីស្រោចស្រពធៀបនឹងផ្ទៃដីគ្រោងស្រោចស្រព:</u> តារាង៤.១ វាស់សមត្ថភាពធារាសាស្ត្រទាក់ទិននឹងផ្ទៃដីគ្រោងស្រោចស្រពរបស់ប្រព័ន្ធ។ តារាងនេះបង្ហាញតែទិន្នន័យពីប្រព័ន្ធចំនួន ៧ [4]ប៉ុណ្ណោះ។ គួរឲ្យកត់សម្គាល់ផងដែរថា ប្រព័ន្ធទាំង៧ នេះសុទ្ធតែត្រូវបានស្តារនីតិសម្បទាដោយផ្អែកលើជំនួយរបស់ដៃគូអភិវឌ្ឍន៍ពីក្រៅ រួមមានធនាគារអភិវឌ្ឍន៍អាស៊ី សហភាពអឺរ៉ុប និងមូលនិធិរូបិយវត្ថុអន្តរជាតិ។ ជាគោលការណ៍ តារាងនេះបង្ហាញថា ប្រព័ន្ធដែលបានស្តារនីតិសម្បទាទាំងអស់ អាចផ្តល់ទឹកធារាសាស្ត្រឲ្យដល់ផ្ទៃដីគ្រោងស្រោចស្រពទាំងស្រុងក្នុងរដូវវស្សាជាមួយទឹកបន្ថែមពីទឹកភ្លៀង។ ប៉ុន្តែ បទសម្ភាសន៍ជាមួយអាជ្ញាធរមូលដ្ឋាន គណៈកម្មាធិការFWUC និងអ្នកផ្តល់ព័ត៌មានគន្លឹះ បានបង្ហាញថាផ្ទៃដីគ្រោងស្រោចស្រពនឹងត្រូវស្រោចស្រពបានទាំងអស់ ប្រសិនបើៈ ១) មានភ្លៀងធ្លាក់ច្រើនដើម្បីបំពេញបន្ថែម ២) កសិករបូមទឹកបន្តចូលក្នុងស្រែដោយសារកង្វះប្រឡាយរងទី៣នៅក្នុងប្រព័ន្ធ។ នៅពេលមានគ្រោះរាំងស្ងួត បើគ្មានទឹកបន្ថែមពីទឹកភ្លៀង គេប៉ាន់ស្មានថាប្រព័ន្ធអាចបម្រើបានតែប្រហែលមួយភាគបីនៃផ្ទៃដីគ្រោងស្រោចស្រពប៉ុណ្ណោះ។ ការ

---

[4] ប្រព័ន្ធផ្សេងទៀតមិនត្រូវបានដាក់បញ្ចូលនៅក្នុងការវិភាគទេ ដោយសារផ្ទៃដីគ្រោងស្រោចស្រព ក៏ដូចជាផ្ទៃដីស្រោចស្រពនៃប្រព័ន្ធទាំងនេះមានទិន្នន័យមិនពេញលេញ និងពីព្រោះប្រព័ន្ធទាំងនេះគឺខ្នាតធំ ហើយពេលវេលានៃការសិក្សាក៏មានកម្រិត។

ផ្គត់ផ្គង់ទឹកមានកម្រិតបែបនេះ គឺបណ្តាលមកពីៈ ១) ពុំមានទឹកបន្ថែមពីទឹកភ្លៀង និង ២) មានតម្រូវការទឹកច្រើន រួមទាំងការដណ្តើមទឹកពីប្រព័ន្ធផ្សេងទៀតនៅឆ្ងាយពីខ្សែទឹកខាងលើ។

តារាង ៤.១. សមត្ថភាពធារាសាស្ត្រនៃប្រព័ន្ធដែលត្រូវបានស្តារនីតិសម្បទា

| | | | ទំហំស្រោចស្រពនៃប្រព័ន្ធធារាសាស្ត្រ (ហិកតា) | | | |
|---|---|---|---|---|---|---|
| ល.រ. | ប្រព័ន្ធធារាសាស្ត្រ | ផ្ទៃដីគ្រោងស្រោចស្រព | ទំហំស្រោចស្រពក្នុងរដូវវស្សា | ដំណាំបន្ថែមក្នុងរដូវវស្សា[5] | ដំណាំបន្ថែមក្នុងរដូវប្រាំង[6] | ផ្ទៃដីដាំដំណាំបន្ថែមសរុប |
| ១ | ត្រាំម្នាស់ | ១.២១២ | ១.២១២ | ០ | ៤៥០ | ៤៥០ |
| ២ | ជ្រៃដើង | ៥០៦ | ៥០៦ | ២៥០ | ០ | ២៥០ |
| ៣ | ប្រឡាយលេខ ១ | ១.០៦១ | ១.០៦១ | ៧២០ | ០ | ៧២០ |
| ៤ | ពន្លៃ | ៧៥០ | ៧៥០ | ០ | ៦០ | ៦០ |
| ៥ | ទានកាំ-បន្ទាត់បោះ | ២៥០ | ២៥០ | ០ | ០ | ០ |
| ៦ | ទំនប់រំដេង | ៣៦២ | ៣៦២ | ០ | ២០ | ២០ |
| ៧ | ត្រដែត | ២៤០ | ២៤០ | ៣០ | ៦០ | ៩០ |
| | សរុប | ៤.៣៨១ | ៤.៣៨១ | ១.០០០ | ៥៩០ | ១.៥៩០ |
| សមត្ថភាពធារាសាស្ត្រគិតជាភាគរយ នៃផ្ទៃដីគ្រោងស្រោចស្រព | | | ១០០% | ២៣% | ១៣% | ៣៦% |

ប្រភពៈ ការចុះប្រមូលទិន្នន័យផ្ទាល់ ( ខែ មិថុនា ឆ្នាំ ២០១១ )

ជាញឹកញាប់ ទោះបីមិនជានិច្ចកាលក្តី ការស្តារនីតិសម្បទាប្រព័ន្ធជួយឲ្យកសិករអាចដាំដំណាំបន្ថែមលើផ្ទៃដីស្រែវស្សារបស់ខ្លួន។ ទិន្នន័យពីប្រព័ន្ធទាំង៧នេះបង្ហាញថា ៣៦%នៃផ្ទៃដីគ្រោងស្រោចស្រព គឺមានលក្ខណៈអំណោយផលសម្រាប់ឲ្យកសិករដាំដំណាំបន្ថែម នៅដើមរដូវវស្សា ឬក្នុងរដូវប្រាំង។ ប៉ុន្តែ ផ្ទៃដីតែ ១៣%ប៉ុណ្ណោះត្រូវបានដាំដុះក្នុងរដូវប្រាំង នៅពេលមួយដែលការដាំដុះត្រូវពឹងផ្អែកទាំងស្រុងលើទឹកពីប្រព័ន្ធ។ ផ្ទៃដី២៣%ទៀត កំពុងផលិតស្រូវនៅដើមរដូវវស្សា ដោយទទួលបានទឹកបំពេញបន្ថែមពីទឹកភ្លៀង។

ប៉ុន្តែ ប្រព័ន្ធដែលត្រូវបានស្តារនីតិសម្បទាដោយមូលនិធិរបស់រាជរដ្ឋាភិបាលកម្ពុជា (ឧទាហរណ៍ អាងស្តុកទឹកសាមសិបកញ្ញា[7] នៅខេត្តកំពង់ធំ និងប្រឡាយរួមស្រុកនៅខេត្តព្រៃវែង) មិនអាចផ្គត់ផ្គង់ទឹកធារាសាស្ត្រឲ្យដល់ផ្ទៃដីគ្រោងស្រោចស្រពទាំងស្រុងបានទេ។ ប្រការនេះគឺដោយសារអន្តរាគមន៍អាចកែលម្អបានតែទ្វារទឹក និងប្រឡាយមេប៉ុណ្ណោះ។ ដោយសារប្រព័ន្ធទាំងនេះគឺខ្នាតធំ ការស្តារនីតិសម្បទាត្រូវបានអនុវត្តតែក្នុងរយៈពេលពីរបីឆ្នាំជាប់ៗគ្នាប៉ុណ្ណោះ ដោយផ្អែកលើមូលនិធិស្ទួចស្ទើងដែលទទួលបានពីថវិកាជាតិរបស់រាជរដ្ឋាភិបាល។ បទសម្ភាសន៍ជាមួយមន្ទីរធនធានទឹកនិងឧតុនិយម បង្ហាញថា គ្មានការផ្តល់ជូនជាប្រឡាយរងទី៣នោះទេ ដោយសារថវិកាមានកម្រិត។ ប្រព័ន្ធនេះក៏ខ្វះផងដែរនូវសំណង់ស្ពាក់ទឹក ដូច្នេះសមត្ថភាពរបស់ប្រព័ន្ធក្នុងការស្រោចស្រពដីស្រែជាក់ស្តែង នៅក្នុងផ្ទៃដីគ្រោងស្រោចស្រព នៅតែមានកម្រិត។

[5] ពីខែ មេសា ដល់ខែ សីហា លើផ្ទៃដីស្រែវស្សា។

[6] ពីខែ ធ្នូ ដល់ខែ មេសា លើផ្ទៃដីស្រែប្រាំង។

[7] សាមសិប កញ្ញា គឺជាសម្លេងជាភាសាខ្មែរដែលមានន័យថា ៣០ កញ្ញា។

<u>ផ្ទៃដីស្រោចស្រពធៀបនឹងផ្ទៃដីស្រែ:</u> **តារាង៤.២**សង្ខេបទំហំស្រោចស្រពនៃប្រព័ន្ធធារាសាស្ត្រ ដោយផ្អែកលើបទសម្ភាសន៍ជាមួយអាជ្ញាធរឃុំ (រួមមាន ក្រុមប្រឹក្សាឃុំ និងស្មៀនឃុំ) នៅក្នុងឃុំចំនួន២៤ នៅក្នុងខេត្តចំនួន៨នៅជុំវិញបឹងទន្លេសាប និងតំបន់វាលរាបនៃទន្លេមេគង្គក្រោមនៅក្នុងអំឡុងពេលចុះប្រមូលទិន្នន័យផ្ទាល់ ពីថ្ងៃទី៣១ ខែឧសភា ដល់ថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១១។ ឃុំទាំង ២៤ នេះស្ថិតនៅក្នុងប្រព័ន្ធធារាសាស្ត្រទាំង១១ ដែលត្រូវបានស្តារនៅក្នុងបណ្តាឆ្នាំថ្មីៗនេះ[៨]។ ប៉ុន្តែ វាគឺជាប្រការសំខាន់ដែលត្រូវកត់សម្គាល់ថាផ្ទៃដីស្រោចស្រពដែលត្រូវបានរាយការណ៍នៅក្នុងឃុំនីមួយៗ គឺមិនមែនមានត្រឹមតែប្រព័ន្ធទាំង១១នេះទេ ប៉ុន្តែរាប់បញ្ចូលប្រព័ន្ធទាំងអស់ដែលផ្តល់ទឹកធារាសាស្ត្រឲ្យដល់ឃុំ។ ដូច្នេះ ឃុំទាំង២៤នេះត្រូវបានផ្តោតលើ ដោយសារវាស្ថិតនៅក្នុងចំណោមឃុំ ដែលអាចទទួលបានទឹកធារាសាស្ត្រប្រើប្រាស់ច្រើន សម្រាប់ផ្ទៃដីស្រែវស្សា ទោះបីជាមិនច្រើនជាងគេក្តី។ ឃុំទាំង២៤នេះ គឺសុទ្ធតែកំពុងផលិតស្រូវវស្សា[៩]។ ហេតុដូច្នេះ ទិន្នន័យនៅក្នុងតារាងនេះ បង្ហាញពីផ្ទៃដីស្រែស្រោចស្រពក្នុងរដូវវស្សាផង និងទំហំនៃការដាំដំណាំបន្ថែមទាក់ទិននឹងផ្ទៃដីស្រែវស្សាសរុបនៅក្នុងឃុំ។

---

[៨] ប្រព័ន្ធធារាសាស្ត្របន្ទាយឆ្លាយ ដែលគឺជាប្រព័ន្ធទី១២ ស្ថិតនៅក្នុងស្រុកកោះអណ្តែត ខេត្តតាកែវ មិនត្រូវបានរាប់បញ្ចូលដោយសារប្រព័ន្ធនេះគឺសម្រាប់ការធ្វើស្រែប្រាំងសុទ្ធសាធ។

[៩] ឃុំដែលភាគច្រើនកំពុងផលិតស្រូវប្រាំង មិនត្រូវបានដាក់បញ្ចូលនៅក្នុងការវិភាគនេះទេ ដោយសារការសិក្សាសន្មត់ថាផ្ទៃដីស្រូវប្រាំងគឺសុទ្ធតែត្រូវបានស្រោចស្រពទាំងអស់ ដូច្នេះការសិក្សានេះមានបំណងពិនិត្យមើលតែផ្ទៃដីស្រោចស្រពសម្រាប់ផ្ទៃដីស្រែវស្សាប៉ុណ្ណោះ។

តារាង ៤.២. ទំហំស្រោចស្រពនៃប្រព័ន្ធធារាសាស្ត្រលើផ្ទៃដីស្រែវស្សាក្នុងឃុំដែលមានលទ្ធភាពប្រើប្រព័ន្ធធារាសាស្ត្រដែលត្រូវបានស្តារនីតិសម្បទា

| | | រដូវវស្សា (ហិកតា) | | ការដាំដំណាំបន្ថែម (ហិកតា) | | |
|---|---|---|---|---|---|---|
| ល.រ. | ឃុំ | ផ្ទៃដីដាំដុះ | ផ្ទៃដីស្រោចស្រព | ដំណាំបន្ថែមក្នុងរដូវវស្សា[10] | ដំណាំបន្ថែមក្នុងរដូវប្រាំង[11] | ផ្ទៃដីដាំដំណាំបន្ថែមសរុប |
| ១ | ត្នោតជុំ | ២.៦៤៥ | ១.២១២ | ០ | ៤៥០ | ៤៥០ |
| ២ | ជ្រៃ | ១.៧០០ | ៥០៦ | ៣៥០ | ៣០ | ៣៨០ |
| ៣ | ខ្នាចរមាស | ៤.៨៤២ | ១.០៧២ | ១.០៧២ | ០ | ១.០៧២ |
| ៤ | រូងជ្រៃ | ៤.៧៥០ | ២.៣៦០ | ២.០០០ | ០ | ២.០០០ |
| ៥ | បន្សាយត្រែង | ៣.៧៤២ | ២.០៦០ | ១.៦៥០ | ០ | ១.៦៥០ |
| ៦ | ពន្លៃ | ៥.៧៨៧ | ១.៨៨០ | ០ | ២៥០ | ២៥០ |
| ៧ | ថ្កាំ | ៥.១៤១ | ៣២ | ០ | ២០ | ២០ |
| ៨ | ទានកាំ | ៣.៣៤៩ | ១.១៧០ | ០ | ០ | ០ |
| ៩ | ខ្នារពោធិ៍ | ១.៧០០ | ៣៦២ | ០ | ២០ | ២០ |
| ១០ | ចាន់សរ | ២.២០០ | ៣៧៦ | ០ | ១២០ | ១២០ |
| ១១ | ដំរីស្លាប់ | ៤.៩៦៤ | ១.០៤១ | ០ | ២០០ | ២០០ |
| ១២ | សាន់គ | ៦.៤៧០ | ១.០០០ | ០ | ០ | ០ |
| ១៣ | រុងរឿង | ១.២០០ | ៦២៣ | ០ | ១០ | ១០ |
| ១៤ | ព្រះដំរី | ១.៦៤១ | ១.១០០ | ០ | ៣៤១ | ៣៤១ |
| ១៥ | ប្រាសាទ | ៤.៣១០ | ៣.០៤០ | ០ | ០ | ០ |
| ១៦ | កំពង់ថ្ម | ៣.១៨២ | ១.១៩៦ | ០ | ០ | ០ |
| ១៧ | បឹងល្វា | ៥១០ | ៣៨៤ | ០ | ៣២ | ៣២ |
| ១៨ | ជ្រៃ | ៣.៥៥៥ | ១.២០០ | ០ | ៦៥ | ៦៥ |
| ១៩ | ជាខ្លាង | ២.៤៤៧ | ១.៧០០ | ០ | ០ | ០ |
| ២០ | ប្រសូត្រ | ២.០១៥ | ៤០ | ០ | ០ | ០ |
| ២១ | ស្វាយតឿ | ១.២៥០ | ១៥០ | ០ | ០ | ០ |
| ២២ | ព្រះពន្លា | ១.៥០០ | ២១០ | ៣២ | ៦២ | ៩៤ |
| ២៣ | រកាក្រៅ | ១.៩២២ | ៥០០ | ១១២ | ០ | ១១២ |
| ២៤ | ស្រង៉ែ | ១.៦២៥ | ១.២០០ | ១.២០០ | ២៥០ | ១.៤៥០ |
| | **សរុប** | **៧២.៤៤៧** | **២៤.១៦៧** | **៦.៤១៦** | **១.៨៥០** | **៨.២៦៦** |
| | **ទំហំស្រោចស្រពនៃប្រព័ន្ធធារាសាស្ត្រ** | **៧២.៤៤៧** | **៣៣%** | **៩%** | **៣%** | **១១%** |

*ប្រភពៈ ការចុះប្រមូលទិន្នន័យផ្ទាល់ (ខែមិថុនា ឆ្នាំ ២០១១)*

[10] ពីខែ មេសា ដល់ខែ សីហា លើផ្ទៃដីស្រែវស្សា។

[11] ពីខែ ធ្នូ ដល់ខែ មេសា លើផ្ទៃដីស្រែប្រាំង។

តារាង៤.២បង្ហាញថា ក្នុងចំណោមផ្ទៃដីស្រែវស្សាទាំង ៧២.៤៤៧ហិកតានៅក្នុងឃុំទាំង២៤ ដែលមានលទ្ធភាពប្រើប្រព័ន្ធដែលត្រូវបានស្តារនីតិសម្បទាក្នុងបណ្តាឆ្នាំថ្មីៗនេះ មានតែ៣៣% (ឬ មួយភាគបី) ប៉ុណ្ណោះដែលត្រូវបានស្រោចស្រពជាមួយការបំពេញបន្ថែមពីទឹកភ្លៀង ខណៈដែលផ្ទៃដីស្រែវស្សានៅសល់នៅតែត្រូវពឹងលើទឹកភ្លៀងទាំងស្រុង។ ប្រការនេះមានន័យថាទំហំស្រោចស្រពនៃប្រព័ន្ធធារាសាស្ត្រហាក់បីដូចជាមានកម្រិត ទោះបីជាមានប្រព័ន្ធធារាសាស្ត្រដំណើរការនៅក្នុងតំបន់ក្តី។ និយាយតាមបែបម្យ៉ាងទៀត ចំណុចនេះមានន័យថា ទំហំស្រោចស្រពនៃប្រព័ន្ធធារាសាស្ត្រលើផ្ទៃដីស្រែវស្សាពិតជាទាបជាង៣៣% ប្រសិនបើរាប់បញ្ចូលឃុំដែលមិនមានប្រព័ន្ធធារាសាស្ត្រស្តារឡើងវិញ។

ស្ថិតិបង្ហាញថែមទៀតថាផ្ទៃដីស្រោចស្រពកំពុងរួញតូចនៅពេលផ្សេងៗគ្នាក្នុងឆ្នាំ។ ទឹកធារាសាស្ត្រអនុញ្ញាតឲ្យធ្វើស្រែបន្ថែមបានតែលើផ្ទៃដី១១%ប៉ុណ្ណោះនៃផ្ទៃដីស្រែវស្សាសរុបរបស់ឃុំ ដែលស្មើនឹងមួយភាគបីនៃសមត្ថភាពបំពេញបន្ថែមធារាសាស្ត្រក្នុងរដូវវស្សា។ ក្នុងចំណោមការធ្វើស្រែបន្ថែមទាំងនេះ ៩%អាចធ្វើបាននៅដើមរដូវវស្សា ដែលត្រូវបានបំពេញបន្ថែមផងដែរដោយទឹកភ្លៀង ហើយ៣%ផ្សេងទៀតធ្វើក្នុងរដូវប្រាំងដែលពឹងផ្អែកទាំងស្រុងលើទឹកធារាសាស្ត្រ។

កំណើនផលស្រូវត្រូវបានរាយការណ៍ដោយកសិករ និងអាជ្ញាធរមូលដ្ឋាននៅតាមគ្រប់ប្រព័ន្ធដែលបានសិក្សា។ តារាង៤.៣ សង្ខេបទស្សនៈរបស់អ្នកផ្តល់បទសម្ភាសន៍ទាំងអស់អំពីផលស្រូវ ក្រោយពេលមានប្រព័ន្ធធារាសាស្ត្រស្តារនីតិសម្បទាប្រៀបធៀបទៅនឹងបណ្តាឆ្នាំមុនពេលស្តារនីតិសម្បទាប្រព័ន្ធ។ តារាងនេះបង្ហាញថាប្រព័ន្ធធារាសាស្ត្របានកែលម្អផលស្រូវក្នុងរដូវវស្សាបានជាមធ្យម ៣៤%។ ប៉ុន្តែ វាគឺជាប្រការសំខាន់ដែលត្រូវកត់សម្គាល់ថា កំណើននេះមិនមែនបណ្តាលមកតែពីឥទ្ធិពលនៃប្រព័ន្ធធារាសាស្ត្រសុទ្ធសាធប៉ុណ្ណោះទេ ប៉ុន្តែត្រូវបានបំពេញបន្ថែមដោយកត្តាជម្រុញផ្សេងទៀតដោយសារវត្តមានប្រព័ន្ធធារាសាស្ត្រ ដូចជា ពូជល្អនិងជី ព្រមទាំងសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្មដែលត្រូវបានផ្តល់ជាផ្នែកមួយនៃគម្រោងស្តារនីតិសម្បទា។

ការទទួលបានផ្លូវតាមបណ្តោយខ្នងប្រឡាយ គឺស្ថិតនៅក្នុងចំណោមអត្ថប្រយោជន៍ធំៗនៃការកែលម្អប្រព័ន្ធធារាសាស្ត្រ។ ការវាយតម្លៃផ្ទាល់នៅមូលដ្ឋានបានរកឃើញថាការកែលម្អប្រព័ន្ធធារាសាស្ត្រ តែងតែនាំមកនូវស្ថានភាពល្អប្រសើរឡើងសម្រាប់ការធ្វើដំណើរ និងការដឹកជញ្ជូន តាមរយៈការទទួលបានផ្លូវតាមបណ្តោយខ្នងប្រឡាយ និងអាងស្តុកទឹក។ កសិករនិងអាជ្ញាធរមូលដ្ឋានពិតជាវាយតម្លៃខ្ពស់ និងអបអរចំពោះអត្ថប្រយោជន៍ដែលទទួលបានពីប្រព័ន្ធ។

ការស្តារនីតិសម្បទាប្រព័ន្ធធារាសាស្ត្រក៏ត្រូវបានសង្កេតឃើញថា បានបង្កើតគុណវិបត្តិមួយចំនួនផងដែរចំពោះប្រជាជនក្នុងសហគមន៍។ ដោយជៀសមិនរួច ការស្តារនីតិសម្បទាបានប៉ះពាល់ដីរបស់ប្រជាជន ខណៈដែលសំណងមិនត្រូវបានផ្តល់ជូនរាល់ពេលនោះឡើយ។ នៅក្នុងប្រព័ន្ធខ្លះ កសិករត្រូវបានសងជាប្រាក់សម្រាប់ដីរងផលប៉ះពាល់របស់ពួកគាត់។ នៅក្នុងប្រព័ន្ធខ្លះផ្សេងទៀត កសិករត្រូវបានស្នើសុំឲ្យបរិច្ចាគដោយស្ម័គ្រចិត្តនូវដីរងផលប៉ះពាល់របស់ខ្លួន បើមិនដូច្នោះទេ ប្រឡាយនឹងមិនអាចត្រូវបានសាងសង់ឬកែលម្អឡើយ។ នៅក្នុងជម្រើសទីពីរនេះ អាជ្ញាធរមូលដ្ឋានបំពេញតួនាទីដ៏សំខាន់មួយក្នុងការសម្របសម្រួលចរចារ និងបញ្ចុះបញ្ចូលកសិកររងផលប៉ះពាល់។ ស្ទើរតែគ្រប់ករណីទាំងអស់ កសិករបានឯកភាពបរិច្ចាគដីរបស់ខ្លួន ខណៈដែលកសិករខ្លះទៀតបានបដិសេធយ៉ាងដាច់អហង្កា។ លើសពីនេះទៀត ការកែលម្អប្រព័ន្ធជួនកាលបានបណ្តាលឲ្យមានទឹកជំនន់លើដីស្រែខ្លះ ឬបានធ្វើឲ្យមានការលំបាកកាន់តែច្រើនចំពោះកសិករ

ក្នុងការដឹកជញ្ជូនធាតុចូល និងផលិតផលកសិកម្មរបស់ខ្លួន ដោយសារពុំមានការសាងសង់ស្ពាន ឬ ការដាក់លូទឹកសម្រាប់ឆ្លងកាត់ប្រឡាយ។

តារាង ៤.៣. ទស្សនៈអំពីកំណើនផលនៃផ្ទៃដីស្រូវវស្សានៅពេលប្រើប្រព័ន្ធធារាសាស្ត្រ

| | | ផលស្រូវ (តោនក្នុងមួយហិកតា) | | | |
|---|---|---|---|---|---|
| ល.រ. | ប្រព័ន្ធធារាសាស្ត្រ | ផលមុនពេលស្តារនីតិសម្បទា | ផលក្រោយពេលស្តារនីតិសម្បទា | កំណើនផល | % កំណើនផល |
| ១ | ត្រាំម្នាស់ | ២,៥ | ៣,០ | ០,៥ | ២០% |
| ២ | ជ្រៃជើង និង ម្រះព្រៅ | ២,៥ | ៣,០ | ០,៥ | ២០% |
| ៣ | ប្រឡាយលេខ ១ | ៣,០ | ៣,៥ | ០,៥ | ១៧% |
| ៤ | ពន្លៃ | ១,៥ | ២,០ | ០,៥ | ៣៣% |
| ៥ | ទានកាំ - បន្ទាត់បោះ | ១,៥ | ១,៨ | ០,៣ | ២០% |
| ៦ | ទំនប់រំដេង | ១,៨ | ២,៣ | ០,៥ | ២៨% |
| ៧ | សាមសិបកញ្ញា | ១,៤ | ២,៤ | ១,០ | ៧១% |
| ៨ | ស្ទឹងជីនិត | ១,២ | ២,៥ | ១,៣ | ១០៨% |
| ៩ | ប្រឡាយរួមស្រុក | ១,៥ | ២,០ | ០,៥ | ៣៣% |
| ១០ | ត្រដែត | ១,០ | ១,៥ | ០,៥ | ៥០% |
| ១១ | ដងខ្ទម | ៣,២ | ៣,៧ | ០,៥ | ១៦% |
| ១២ | បន្ទាយឆ្លាយ | ២,៥ | ៤,០ | ១,៥ | ៦០% |
| | មធ្យម | ១,៩ | ២,៦ | ០,៧ | ៣៤% |

ប្រភព: ការចុះប្រមូលទិន្នន័យផ្ទាល់ (ខែមិថុនា ឆ្នាំ ២០១១)

## ៤.២. បញ្ហាប្រឈមនៅក្នុងប្រព័ន្ធធារាសាស្ត្រ

ថ្វីបើជោគជ័យនៃការកែលម្អប្រព័ន្ធធារាសាស្ត្រភាគច្រើន ត្រូវបានបង្ហាញភស្តុតាងដោយអត្ថប្រយោជន៍ទាំងឡាយ ដូចដែលបានរៀបរាប់ខាងលើក្តី ក៏មានកត្តាមួយចំនួនត្រូវបានរាយការណ៍ថាបានរួមចំណែកដល់ជោគជ័យនេះផងដែរ ឧទាហរណ៍រួមមាន ការមានទឹកជាប្រចាំពីប្រភព ការពិគ្រោះយោបល់ជាមួយអាជ្ញាធរមូលដ្ឋាននិងប្រជាជនក្នុងសហគមន៍(មុនពេលនិងពេលស្តារប្រព័ន្ធ) កម្មវិធីអប់រំអំពីការប្រើប្រាស់និងការគ្រប់គ្រងទឹកសម្រាប់កសិករទទួលផល ការផ្តល់សេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្ម និងការបង្កើតសហគមន៍កសិករប្រើប្រាស់ទឹក(FWUC)។ កត្តាទាំងនេះត្រូវបានរាយការណ៍ថាជាចំណុចខ្លាំងនៃប្រព័ន្ធស្តារនីតិសម្បទា។ ទោះជាយ៉ាងណាក្តី បញ្ហាប្រឈមធំៗមួយចំនួនត្រូវបានសង្កេតឃើញដូចខាងក្រោម:

- **ការផ្គត់ផ្គង់ទឹកមិនគ្រប់គ្រាន់:** បញ្ហាប្រឈមមួយក្នុងចំណោមបញ្ហាប្រឈមចម្បងជាងគេនៅក្នុងប្រព័ន្ធធារាសាស្ត្រ គឺការមានទឹកមិនគ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់ដល់ ផ្ទៃដីគ្រោងស្រោចស្រព (command area)នៃប្រព័ន្ធធារាសាស្ត្រ។ ការផ្គត់ផ្គង់ទឹកមិនគ្រប់គ្រាន់នេះ អាចត្រូវបានពន្យល់ដោយកត្តាចំនួនពីរ: ១) បរិមាណទឹកប្រែទៅជាមិនសូវសម្បូរដោយសារភ្លៀងតិច និង ២) តម្រូវការទឹកកាន់តែច្រើនដោយសារការស្រូបយកនៃប្រព័ន្ធធារាសាស្ត្រនានាស្ថិតនៅឆ្ងាយខាងលើខ្សែទឹក។

ក្នុងចំណោមប្រព័ន្ធទាំង១២ដែលបានចុះសិក្សា ប្រព័ន្ធចំនួន១០ គឺពឹងអាស្រ័យលើទឹកមកពីស្ទឹង និងប្រព័ន្ធចំនួន០២ផ្សេងទៀត ពឹងលើការត្រងទឹកភ្លៀងចូលទៅក្នុងអាងស្តុកទឹក។

- **ប្រព័ន្ធមិនពេញលេញ:** ប្រព័ន្ធជាច្រើនមានលក្ខណៈមិនពេញលេញ ដោយសារវាខ្វះសំណង់ស្នាក់ទឹកនិងប្រឡាយរងទី៣ ជាពិសេសប្រព័ន្ធទាំងឡាយដែលទទួលហិរញ្ញប្បទានពីរាជរដ្ឋាភិបាលកម្ពុជា។ ការវាយតម្លៃបានរកឃើញថា ប្រព័ន្ធចំនួន៦ក្នុងចំណោមប្រព័ន្ធចំនួន១២ដែលបានសិក្សាត្រូវបានសង្កេតឃើញថាមានប្រឡាយរងទី៣។ ប្រព័ន្ធចំនួន៦ផ្សេងទៀតមិនមានប្រឡាយរងទី៣នោះទេ។ ប្រព័ន្ធទាំងបីដែលត្រូវបានស្តារដោយមូលនិធិរបស់រាជរដ្ឋាភិបាល គឺមានលក្ខណៈមិនពេញលេញ ពោលគឺមានតែក្បាលហុងទឹកនិងប្រឡាយមេប៉ុណ្ណោះ ដែលត្រូវបានស្តារនីតិសម្បទា។ម្យ៉ាងទៀតក្នុងករណីជាច្រើន កសិករ អាជ្ញាធរមូលដ្ឋាន និង FWUC បានឯកភាពថាប្រព័ន្ធទាំងនេះខ្វះសំណង់ស្នាក់ទឹកសម្រាប់គ្រប់គ្រងទឹកនៅក្នុងប្រព័ន្ធ។

- **ការគ្រប់គ្រងប្រព័ន្ធ**: FWUC ត្រូវបានបង្កើតឡើងនៅគ្រប់ប្រព័ន្ធស្តារនីតិសម្បទាទាំងអស់ដែលទទួលហិរញ្ញប្បទានពីម្ចាស់ជំនួយ ដោយមានភារកិច្ចដំណើរការ គ្រប់គ្រង និងថែរក្សាប្រព័ន្ធ។ ផ្ទុយទៅវិញ ចំពោះគម្រោងស្ថិតក្នុងការសិក្សានេះ ពុំមានគម្រោងណាមួយ ដែលផ្តល់ហិរញ្ញប្បទានដោយរាជរដ្ឋាភិបាលកម្ពុជាត្រូវបានរកឃើញថា មានបង្កើតFWUCនោះទេ។ ការមិនមានFWUC ធ្វើឲ្យការសម្របសម្រួលទឹកជួបការលំបាក។ ឧទាហរណ៍ មានតែអ្នកគ្រប់គ្រងតែពីរនាក់ប៉ុណ្ណោះដែលត្រូវបានតែងតាំងដោយមន្ទីរធនធានទឹកនិងឧតុនិយមខេត្ត ឲ្យទទួលបន្ទុកលើការគ្រប់គ្រង និងត្រួតពិនិត្យទឹកនៅអាងស្តុកទឹកសាមសិបកញ្ញានៅខេត្តកំពង់ធំ។ អ្នកគ្រប់គ្រងទាំងពីរគ្រប់គ្រងតែទឹកនៅក្នុងអាងប៉ុណ្ណោះ ហើយពួកគេមិនបានប្រាប់កសិករថាពួកគេបញ្ចេញទឹកឬសម្របសម្រួលតម្រូវការទឹករបស់កសិករនៅពេលណានោះទេ។ នៅក្នុងករណីរបស់ឃុំជ្រៃ(ប្រឡាយរួមស្រុកក្នុងខេត្តព្រៃវែង) និងឃុំការក្រៅ(អាងស្តុកទឹកជងខ្ចមក្នុងខេត្តតាកែវ) កសិករបានបង្កើតក្រុមតូចមួយដោយគំនិតផ្តួចផ្តើមរបស់ពួកគាត់ដើម្បីសម្របសម្រួលការចែកចាយទឹក និងការថែរក្សាប្រព័ន្ធ។

- **កិច្ចដំណើរការរបស់** FWUC: ទោះបីជា FWUCs ត្រូវបានបង្កើតឡើងនៅក្នុងគម្រោងស្តារនីតិសម្បទាជាច្រើនដែលផ្តល់ហិរញ្ញប្បទានដោយម្ចាស់ជំនួយក្តី ក៏មិនមែនមានន័យថា FWUCs ទាំងអស់សុទ្ធតែដំណើរការយ៉ាងសកម្មនោះទេ។ ក្នុងចំណោមFWUCs ចំនួនប្រាំបួនដែលត្រូវបានបង្កើតឡើង មានតែពីរប៉ុណ្ណោះដែលអាចប្រមូលថ្លៃទឹកពីកសិករ។ FWUCs ផ្សេងទៀតអាចប្រមូលបានតែថ្លៃទឹកតិចតួចប៉ុណ្ណោះ[12]។ កិច្ចដំណើរការរបស់FWUCs ត្រូវបានសង្កេតឃើញថាមានភាពខុសគ្នាពីករណីមួយទៅករណីមួយ ដោយត្រូវបានពន្យល់ដោយ: ១) សមត្ថភាពមិនគ្រប់គ្រាន់របស់គណៈកម្មាធិការFWUC ២) កង្វះការផ្គត់ផ្គង់ទឹកធារាសាស្ត្រ ៣) ប្រព័ន្ធមិនពេញលេញ ៤) កង្វះការចូលរួមរបស់កសិករ និងភាពគ្មានឆន្ទៈរបស់ពួកគាត់ក្នុងការបង់ថ្លៃទឹក និង ៥) កង្វះគ្រឿងលើកទឹកចិត្តសម្រាប់សមាជិកគណៈកម្មាធិការ FWUC។

[12] ចំណុចនេះក៏ត្រូវបានលើកឡើងផងដែរដោយការសម្ភាសន៍ជាមួយមន្ទីរធនធានទឹកនិងឧតុនិយមខេត្តតាកែវ។ បទសម្ភាសន៍បង្ហាញថាមាន FWUC ចំនួន២៦ ក្នុងខេត្តតាកែវ (ដែលនៅក្នុងនោះ FWUC ចំនួន១១ ត្រូវបានចុះបញ្ជីជាមួយក្រសួងធនធានទឹកនិងឧតុនិយម) ហើយ FWUC ប្រហែល២០% កំពុងដំណើរការបានល្អបង្គួរ ប៉ុន្តែ FWUC ផ្សេងទៀតដំណើរការមិនបានល្អ ឬមិនដំណើរការ។

ក្នុងករណីខ្លះ គណៈកម្មាធិការFWUCមិនសកម្ម និងខ្វះការដឹកនាំល្អដើម្បីសម្របសម្រួលនិងលើកទឹកចិត្តដល់ការចូលរួមរបស់កសិករ។ ក្នុងករណីខ្លះផ្សេងទៀត FWUCមិនហ៊ានបង្ខំឲ្យអនុវត្តបទបញ្ជារបស់ខ្លួន និងប្រមូលថ្លៃទឹកនោះទេ ដោយសារប្រព័ន្ធមិនបានផ្គត់ផ្គង់ទឹកឲ្យបានគ្រប់គ្រាន់ជូនកសិករ។ ប្រព័ន្ធមិនពេញលេញគឺជាកត្តាមួយទៀតដែលធ្វើឲ្យរារាំងដល់សមត្ថភាពរបស់ FWUCs ក្នុងការប្រមូលថ្លៃទឹក។ ដោយសារកង្វះប្រឡាយរងទី៣ កសិករត្រូវចំណាយប្រាក់ច្រើនសម្រាប់បូមទឹកបញ្ចូលស្រែរបស់ខ្លួន។ ដោយសារមូលហេតុនេះ ជារឿយៗ កសិករសំដែងនូវការមិនសប្បាយចិត្តចំពោះFWUC ដែលជាហេតុធ្វើឲ្យពួកគេមិនហ៊ានទៅប្រមូលថ្លៃទឹក។ ម្យ៉ាងទៀត ប្រព័ន្ធភាគច្រើនផ្តល់ទឹកធារាសាស្ត្រសម្រាប់បំពេញបន្ថែមលើទឹកភ្លៀងក្នុងរដូវវស្សា ដូច្នេះកសិករមិនចង់បង់ថ្លៃទឹក ដោយសារពួកគាត់យល់ថាទឹកភាគច្រើន គឺបានមកពីទឹកភ្លៀង ជាពិសេសនៅពេលដែលរដូវវស្សាមានភ្លៀងច្រើន។

កិច្ចដំណើរការរបស់FWUCs ហាក់បីដូចជាពឹងផ្អែកភាគច្រើនលើប្រព័ន្ធផ្តល់គ្រឿងលើកទឹកចិត្តជូនសមាជិកគណៈកម្មាធិការFWUC។ ប្រព័ន្ធផ្តល់គ្រឿងលើកទឹកចិត្ត មានលក្ខណៈមិនច្បាស់លាស់នៅតាមប្រព័ន្ធធារាសាស្ត្រស្ថិតក្នុងការសិក្សានេះ ដែលនៅក្នុងនោះFWUCត្រូវបានបង្កើតឡើង។ ក្នុងករណីខ្លះ សមាជិកគណៈកម្មាធិការFWUCត្រូវបានរាយការណ៍ថា បានធ្វើការដោយស្ម័គ្រចិត្ត ដោយមិនបានទទួលកម្រៃអ្វីឡើយ។ ក្នុងករណីផ្សេងទៀត ពួកគាត់ត្រូវបានផ្តល់ឲ្យជាកម្រៃតិចតួច។ ប្រការនេះចោទជាសំណួរថាតើសមាជិកFWUC គួរត្រូវបានផ្តល់ឲ្យនូវកម្រៃសមរម្យដើម្បីឲ្យពួកគេបំពេញការងារឲ្យបានល្អ រឺយ៉ាងណា។ សំណួរបន្ថែមទាក់ទិននឹងប្រការដែលថាតើថ្លៃទឹកអាចកើនឡើងឬទេ និងថាតើប្រព័ន្ធអាចផ្គត់ផ្គង់ទឹកធារាសាស្ត្រឲ្យបានគ្រប់គ្រាន់ឬទេ ដើម្បីឲ្យកសិករអាចទទួលបានផលចំណេញសមស្របពីដំណាំរបស់ខ្លួន។

- **សំណង់ និងប្លង់ៈ** បញ្ហាប្រឈមនៅក្នុងប្រព័ន្ធធារាសាស្ត្រក៏ត្រូវបានសង្កេតឃើញផងដែរថា ត្រូវបានបណ្តាលមកពីការសាងសង់ និងការគូសប្លង់ប្រព័ន្ធ។ ក្នុងករណីនៃប្រឡាយលេខ១ និង ប្រព័ន្ធជ្រៃជើងនិងម្រះព្រៅ ទាំងអាជ្ញាធរនិងអ្នកភូមិសុទ្ធតែបានអះអាងថាខាងគម្រោងបានពិគ្រោះយោបល់ជាមួយពួកគាត់ ក៏ប៉ុន្តែយោបល់របស់ពួកគាត់មិនត្រូវបានរាប់បញ្ចូលនោះទេ។ ជាលទ្ធផល ការស្តារនីតិសម្បទាប្រព័ន្ធជ្រៃជើងនិងម្រះព្រៅបានធ្វើឲ្យដីស្រែទំហំ ៣០ហិកតា ត្រូវទឹកជន់លិច និងមិនអាចដាំដុះបានក្នុងរដូវវស្សា។ ផ្ទុយទៅវិញ វាតម្រូវឲ្យដីស្រែទំហំ១៣០ ហិកតា នៅខាងលើប្រព័ន្ធត្រូវស្រោចស្រពដោយម៉ាស៊ីនបូមទឹក ជាជាងលំហូរតាមទំនាញផែនដី ដែលស្ថានភាពនេះគឺជាករណីមុនពេលស្តារនីតិសម្បទា។

សម្រាប់ករណីប្រព័ន្ធធារាសាស្ត្រពន្លៃ FWUCបានអះអាងថា អ្នកម៉ៅការបន្តមិនបានសាងសង់ប្រឡាយរងទី៣មួយចំនួនស្របតាមផែនការ និងដោយសារការតាមដានលើប្រព័ន្ធមានកម្រិត អ្នកម៉ៅការនោះមិនត្រូវបានចាប់ឲ្យទទួលខុសត្រូវឡើយ។ FWUC បានបញ្ជាក់ថាថ្វីបើប្រឡាយរងទី៣ទាំងនោះ ត្រូវជួយសម្រួលទឹកដោយលំហូរតាមទំនាញផែនដីក្តី ក៏ពេលនេះប្រឡាយរងទាំងនោះហាក់ដូចជាប្រឡាយដីក ដែលកសិករចាំបាច់ត្រូវបូមទឹកបន្ថែម។ លើសពីនេះទៀត ការកែលម្អ

ប្រព័ន្ធធារាសាស្ត្របន្ទាត់បោះ បានផ្តល់អត្ថប្រយោជន៍ជូនដល់កសិករខ្នាតធំនិងមានលទ្ធភាព ជាជាងកសិករខ្នាតតូច។

- **ទំនាស់ផលប្រយោជន៍:** ការវាយតម្លៃផ្ទាល់នៅមូលដ្ឋានបានកត់សម្គាល់ថាអ្នកមានអំណាច បានបំពានប្រើអំណាចរបស់ខ្លួនក្នុងការប្រើទឹកធារាសាស្ត្រ ដើម្បីបម្រើប្រយោជន៍ផ្ទាល់ខ្លួន។ ក្នុងករណីប្រឡាយលេខ១ អ្នកភូមិបានចោទថាទឹកត្រូវបានបង្វែរទៅស្រោចស្រពស្រែនៅក្រៅប្រព័ន្ធ ដែលជាដីស្រែដ៏ធំរបស់មន្ត្រីមួយរូបនៃការិយាល័យធនធានទឹកនិងឧតុនិយមស្រុក។ ក្នុងករណីប្រព័ន្ធសាមសិបកញ្ញា អ្នកភូមិក៏បានចោទផងដែរថា អ្នកគ្រប់គ្រងប្រព័ន្ធមិនបានបញ្ចេញទឹកពីអាងស្តុកទឹកក្នុងរដូវប្រាំងទេ ប៉ុន្តែបានរក្សាទឹកទុកសម្រាប់ផ្គត់ផ្គង់ស្រែរបស់ខ្លួនឯងដែលនៅជិតអាងស្តុកទឹក។
- **ផលចំណេញទាប:** ផលចំណេញពីប្រព័ន្ធធារាសាស្ត្រអាចពន្យល់អំពីកិច្ចដំណើរការនៃ FWUC និងប្រព័ន្ធប្រមូលថ្លៃទឹក។ កសិករនៅខេត្តតាកែវសុខចិត្តបង់ថ្លៃទឹករហូតដល់ ៦៣៩.០០០រៀល (១៥៦ ដុល្លារអាមេរិក) ក្នុងមួយហិកតានៅក្នុងប្រព័ន្ធបន្ទាយធ្លាយ និង ៣០០.០០០រៀល (ប្រហែល៧០ ដុល្លារអាមេរិក) ក្នុងមួយហិកតានៅក្នុងប្រព័ន្ធដងខ្វម។ ប៉ុន្តែ ថ្លៃទឹកគឺមានតម្លៃទាបជាងច្រើននៅតាមប្រព័ន្ធផ្សេងទៀតដែលបានសិក្សា ដែលនៅក្នុងនោះ ថ្លៃទឹកអាចមានតម្លៃទាបរហូតដល់ ២០.០០០ រៀល (៥ដុល្លារអាមេរិក) ក្នុងមួយហិកតា។ ម្យ៉ាងវិញទៀត ថ្លៃទឹកថោកអាចត្រូវបានបន្ទាបដោយសារការ ផ្គត់ផ្គង់ទឹកធារាសាស្ត្រពីប្រព័ន្ធមានកម្រិត។ មួយវិញទៀត ផលចំណេញទាបពីផលិតកម្មកសិកម្មអាចរងឥទ្ធិពលមកពីដីគ្មានជីវជាតិ ការមានសត្វល្អិតចង្រៃ និងកង្វះចំណេះដឹងបច្ចេកទេសរបស់កសិករ។ ដូចដែលត្រូវបានបង្ហាញដោយករណីនៃស្ទឹងជីនិតនៅខេត្តកំពង់ធំ ដែលនៅទីនោះ ផលចំណេញទាបពីប្រព័ន្ធធារាសាស្ត្រ ត្រូវបានផ្សារភ្ជាប់ទៅនឹងដីគ្មានជីវជាតិ(ដីខ្សាច់) និងសត្វល្អិតចង្រៃ។

ជាមួយបញ្ហាប្រឈមទាំងអស់នេះនៅក្នុងការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ/ទឹក ផ្អែកលើការសង្កេតមើលប្រព័ន្ធទាំង១២ ដែលបានសិក្សានៅជុំវិញវាលទំនាបនៃបឹងទន្លេសាបនិងទន្លេមេគង្គក្រោម ទស្សនៈទានក៏ដូចជាអន្តរទំនាក់ទំនងនៅក្នុងចំណោមបញ្ហាប្រឈមទាំងនេះអាច ត្រូវបានសង្ខេបដូចមានបង្ហាញជូននៅក្នុងរូប៤.១ ខាងក្រោម។ ម្យ៉ាងទៀត រូបនេះក៏គប្បីមានតួនាទីជាក្របខ័ណ្ឌចង្អុលបង្ហាញមួយ សម្រាប់នាំផ្លូវឆ្ពោះទៅកាន់អភិបាលកិច្ចប្រព័ន្ធធារាសាស្ត្រនៅកម្ពុជាប្រកបដោយប្រសិទ្ធភាព។

រូប ៤.១: ក្របខ័ណ្ឌសម្រាប់អភិបាលកិច្ចប្រព័ន្ធធារាសាស្ត្រប្រកបដោយប្រសិទ្ធភាព




*ប្រភព: អ្នកនិពន្ធ*

## ៥. ការស្ទង់មតិតាមគ្រួសារបែបរហ័ស

ជំពូកនេះបង្ហាញពីរបកគំហើញនៃការស្ទង់មតិបែបរហ័សមួយ ដែលការសិក្សាបានធ្វើ ដោយមានគោលបំណងបង្ហាញពីផលប្រយោជន៍នៃប្រព័ន្ធធារាសាស្ត្រ ដោយសង្កេតមើលឥរិយាបថរបស់កសិករក្នុងការដាំដំណាំ នៅពេលដែលដីស្រែរបស់ពួកគាត់អាចទទួលបានការស្រោចស្រពពីប្រព័ន្ធធារាសាស្ត្រ។ ការស្ទង់មតិនេះមិនមែនសំដៅសង្ខេបអត្ថប្រយោជន៍ឬឥទ្ធិពលនៃប្រព័ន្ធធារាសាស្ត្រជារួមនោះទេ ប៉ុន្តែសំដៅសង្កេតមើល និងស្វែងយល់ពីឥទ្ធិពលនៃទឹកធារាសាស្ត្រលើផលិតកម្មកសិកម្មរបស់កសិករនៅក្នុងតំបន់ ដែលត្រូវបានជ្រើសរើសជាសំណាក។

### ៥.១. ការជ្រើសរើសសំណាក

ជាផ្នែកមួយនៃការចុះសិក្សាវាយតម្លៃបែបរហ័សដោយផ្ទាល់ ប្រព័ន្ធធារាសាស្ត្រចំនួនបួនត្រូវបានជ្រើសរើសសម្រាប់ការស្ទង់មតិបែបរហ័សមួយលើគ្រួសារកសិករ។ ប្រព័ន្ធនីមួយៗនៃប្រព័ន្ធទាំងបួនត្រូវបានជ្រើសរើសចេញពីម្ចាស់មូលនិធិផ្សេងៗគ្នា រួមមានដូចជា ធនាគារអភិវឌ្ឍន៍អាស៊ី សហភាពអឺរ៉ុប មូលនិធិរូបិយវត្ថុអន្តរជាតិ និងរាជរដ្ឋាភិបាលកម្ពុជា។ ប្រព័ន្ធដែលត្រូវបានជ្រើសរើសទាំងនេះ គឺយកតែប្រព័ន្ធទាំងឡាយ

ដែលត្រូវបានស្តារនីតិសម្បទាក្នុងបណ្តាឆ្នាំថ្មីៗនេះ និងដែលបាននិងកំពុងផ្តល់ទឹកធារាសាស្ត្រជូនកសិករ។ ជាសរុបកសិករចំនួន ១៨០គ្រួសារ[13] ត្រូវបានជ្រើសរើសសម្រាប់ការសម្ភាសន៍ផ្ទាល់ និងនៅក្នុងចំនួននោះ គ្រួសារកសិករចំនួន៤៥ត្រូវបានជ្រើសរើស រួចបែងចែកជាបីក្រុម មានចំនួន១៥គ្រួសារក្នុងមួយក្រុមដូចខាងក្រោម:

១) កសិកររដូវវស្សាពឹងលើទឹកភ្លៀង: កសិករមានដីស្រែវស្សា ដែលពឹងផ្អែកទាំងស្រុងលើទឹកភ្លៀង
២) កសិកររដូវវស្សាដែលមានដីស្រែស្រោចស្រព: កសិករមានដីស្រែវស្សាដែលត្រូវបានស្រោចស្រពដោយប្រព័ន្ធស្ថិតក្នុងការសិក្សានេះ និង
៣) កសិករដាំដំណាំបន្ថែមដែលមានដីស្រែស្រោចស្រព: កសិករមានដីស្រែវស្សាដែលត្រូវបានប្រើឡើងវិញសម្រាប់ផលិតដំណាំស្រូវជាលើកទីពីរ នៅដើមរដូវវស្សា (មេសា-សីហា) ឬរដូវប្រាំង (ធ្នូ-មេសា) ជាមួយការប្រើទឹកធារាសាស្ត្រពីប្រព័ន្ធដែលបានសិក្សា។

**តារាង ៥.១. បំណែងចែកសំណាក(ចំនួនកសិករ)**

| ម្ចាស់មូលនិធិ | ពឹងលើទឹកភ្លៀង | ស្រោចស្រពរដូវវស្សា | ស្រោចស្រពដំណាំបន្ថែម[14] | សរុប |
|---|---|---|---|---|
| រាជរដ្ឋាភិបាលកម្ពុជា | ១៥ | ១៥ | ១៥ | ៤៥ |
| មូលនិធិរូបិយវត្ថុអន្តរជាតិ | ១៥ | ១៥ | ១៥ | ៤៥ |
| ធនាគារអភិវឌ្ឍន៍អាស៊ី | ១៥ | ១៥ | ១៥ | ៤៥ |
| សហភាពអឺរ៉ុប | ១៥ | ១៥ | ១៥ | ៤៥ |
| សរុប | ៦០ | ៦០ | ៦០ | ១៨០ |

ប្រភព: ការស្ទង់មតិបែបរហ័សលើគ្រួសារកសិករ ( ខែ មិថុនា ឆ្នាំ ២០១១ )

ដូច្នេះ កសិករចំនួន៦០នាក់ពីក្រុមនីមួយៗនៃទំរង់ទទួលបានប្រយោជន៍ពីប្រព័ន្ធធារាសាស្ត្រត្រូវបានសម្ភាសន៍។ ការជ្រើសរើសកសិករទាំងនេះ ត្រូវបានធ្វើតាមរយៈការពិគ្រោះយោបល់ជាមួយប្រធានភូមិ។ នៅក្នុងបទសម្ភាសន៍ជាមួយកសិករម្នាក់ៗ អ្នកសម្ភាសន៍បានសួរអំពីព័ត៌មានទូទៅស្តីពីគ្រួសារនិងផ្ទៃដីស្រែ។ បន្ទាប់មក អ្នកសម្ភាសន៍ រួមជាមួយកសិករ បានជ្រើសរើសដីស្រែមួយដុំ ដែលស្របទៅនឹងទំរង់ទទួលបានប្រយោជន៍ពីប្រព័ន្ធធារាសាស្ត្រដែលបានកំណត់ (ដូចជា ពឹងលើទឹកភ្លៀង ស្រោចស្រពរដូវវស្សា ស្រោចស្រពរដូវដំណាំបន្ថែម) សម្រាប់ការសម្ភាសន៍ស៊ីជម្រៅបន្ថែមអំពីដីស្រែទាំងនោះ។ ដូច្នេះ របកគំហើញដែលទទួលបានពីអង្កេតនេះ ជាទូទៅ គឺមានលក្ខណៈរៀបរាប់ ឬពិភាក្សាពីចរឹតលក្ខណៈនៃដីស្រែជាជាងគ្រួសារ។

## ៥.២. ព័ត៌មានអំពីសំណាក

ក្នុងចំណោមកសិករចំនួន១៨០នាក់ ដែលបានសម្ភាសន៍ អាយុជាមធ្យមរបស់ពួកគេគឺ ៤៥ឆ្នាំ ហើយ ៤៥% គឺជានារី។ ចំពោះប្រភេទនៃគ្រួសារដែលបានសម្ភាសន៍ ១២% គឺជាគ្រួសារដែលមានស្ត្រីជាមេគ្រួសារ

[13] គ្រួសារទាំងនេះត្រូវបានជ្រើសរើសពីភូមិចំនួន ៧ នៃឃុំចំនួន ៥។
[14] ពីខែ មេសា ដល់ខែ សីហា ឬ ពីខែ ធ្នូ ដល់ខែ មេសា លើផ្ទៃដីស្រែវស្សា។

ដែលមានអាយុជាមធ្យម ៤៧ឆ្នាំ។ ៦២% នៃបទសម្ភាសន៍ត្រូវបានធ្វើដោយផ្ទាល់ជាមួយមេគ្រួសារ ៣១% ផ្សេងទៀត គឺជាបទសម្ភាសន៍ជាមួយស្វាមីឬភរិយារបស់មេគ្រួសារ ខណៈដែលបទសម្ភាសន៍ ៧% ដែលនៅសល់ត្រូវបានឆ្លើយដោយកូននិងមាតាបិតារបស់មេគ្រួសារ ដែលបានចូលរួមក្នុង និងដឹងអំពីការធ្វើកសិកម្ម។

តារាង ៥.២. ចរិតលក្ខណៈនៃសំណាក

| | ពឹងលើទឹកភ្លៀង | ស្រោចស្រពរដូវវស្សា | ស្រោចស្រពដំណាំបន្ថែម | សរុប |
|---|---|---|---|---|
| ចំនួន | ៦០ | ៦០ | ៦០ | ១៨០ |
| | យេនឌ័រ | | | |
| អ្នកឆ្លើយជាស្ត្រី | ៤៣% | ៥០% | ៤២% | ៤៥% |
| គ្រួសារដែលមានមេគ្រួសារជាស្ត្រី | ១៣% | ១៧% | ៧% | ១២% |
| | អាយុជាមធ្យម (ឆ្នាំ) | | | |
| អាយុជាមធ្យមនៃអ្នកឆ្លើយ | ៤៧ | ៤៥ | ៤៤ | ៤៥ |
| អាយុជាមធ្យមនៃមេគ្រួសារ | ៤៧ | ៤៦ | ៤៩ | ៤៧ |
| | កម្រិតវប្បធម៌នៃមេគ្រួសារ | | | |
| មិនបានរៀន | ៧% | ១៣% | ៨% | ៩% |
| បឋមសិក្សា | ៥៧% | ៥២% | ៦០% | ៥៦% |
| មធ្យមសិក្សាបឋមភូមិ | ២៨% | ២៥% | ២៥% | ២៦% |
| មធ្យមសិក្សាទុតិយភូមិ | ៣% | ៧% | ៧% | ៦% |
| ផ្សេងទៀត | ៥% | ៣% | ០% | ៣% |
| សរុប | ១០០% | ១០០% | ១០០% | ១០០% |

ប្រភព: ការស្ទង់មតិបែបរហ័សលើគ្រួសារកសិករ (ខែ មិថុនា ឆ្នាំ ២០១១ )

ភាគច្រើននៃមេគ្រួសារមានកម្រិតវប្បធម៌ទាប។ ៩%នៃពួកគាត់មិនបានទៅរៀន ៥៦%បានរៀនកម្រិតបឋមសិក្សា ២៦%បានសិក្សាកម្រិតមធ្យមសិក្សាបឋមភូមិ និង៦%ផ្សេងទៀតធ្លាប់បានសិក្សានៅកម្រិតមធ្យមសិក្សាទុតិយភូមិ។

រូប ៥.១. ប្រាក់ចំណូលប្រចាំខែជាមធ្យមក្នុងមួយគ្រួសារ(% នៃគ្រួសារ)




ប្រភព: ការស្ទង់មតិបែបរហ័សលើគ្រួសារកសិករ (ខែ មិថុនា ឆ្នាំ ២០១១)

រូប ៥.១ បង្ហាញថាគ្រួសារភាគច្រើនដែលបានសម្ភាស មិនបានរកប្រាក់ចំណូលជាមធ្យមលើសពី៧០ ដុល្លារអាមេរិក ក្នុងមួយខែនោះទេ-- ៦%មិនមានប្រាក់ចំណូលទាល់តែសោះ ៣៥% រកបានតិចជាង ៣០ ដុល្លារអាមេរិកក្នុងមួយខែ និង ៣៨%រកបានពី ៣០ ទៅ ៧០ ដុល្លារអាមេរិកក្នុងមួយខែ។ ១១%ផ្សេងទៀត រកបានពី ៧០ ទៅ ១០០ ដុល្លារអាមេរិកក្នុងមួយខែ ខណៈដែលគ្រួសារដែលនៅសល់ ១០% អាចរកប្រាក់ បានលើសពី ១០០ ដុល្លារអាមេរិកក្នុងខែនីមួយៗ។

## ៥.៣. របកគំហើញនៃការស្ទង់មតិបែបរហ័ស

### ៥.៣.១. ឥរិយាបថរបស់កសិករ និងលក្ខណៈដីស្រែ

តារាង៥.៣ បង្ហាញថាទំហំនៃដីស្រែវស្សាពឹងលើទឹកភ្លៀង ជាទូទៅគឺមានទំហំធំជាងគេជាមួយនឹង ទំហំជាមធ្យម ០,៧៦ ហិកតាក្នុងដីមួយក្បាល។ ទំហំជាមធ្យមនៃដីស្រែសម្រាប់ស្រែវស្សាដែលទទួលបាន ការស្រោចស្រពគឺ ០,៥៨ ហិកតាក្នុងដីមួយក្បាល ប្រៀបធៀបទៅនឹងទំហំ ០,៤៥ ហិកតាសម្រាប់ដីស្រែដាំ ដំណាំបន្ថែមដែលទទួលបានការស្រោចស្រព។

ការស្ទង់មតិបង្ហាញថា ការប្រើធាតុចូលកសិកម្មមានភាពខុសគ្នាច្រើននៅក្នុងក្រុមនានា។ ការប្រើពូជ ប្រពៃណីនៅតែមានកម្រិតខ្ពស់នៅក្នុងចំណោមដីស្រែពឹងលើទឹកភ្លៀង។ ពូជកែលម្អត្រូវបានសង្កេតឃើញតែ នៅក្នុង៣៧%ប៉ុណ្ណោះនៃដីប្រភេទនេះ ដែលទាបជាងច្រើនប្រសិនបើប្រៀបធៀបទៅនឹង ៤២%នៅក្នុងដីស្រែ វស្សាដែលទទួលបានការស្រោចស្រព និង៩០%នៅក្នុងផ្ទៃដីស្រោចស្រពសំរាប់ដាំដំណាំបន្ថែម។ បរិមាណ នៃគ្រាប់ពូជដែលបានប្រើក៏ខុសគ្នាច្រើនដែរ។ ឧទាហរណ៍ កសិករបានប្រើជាមធ្យម ៨០ គីឡូក្រាម ក្នុងមួយ ហិកតាសម្រាប់ដីស្រែពឹងលើទឹកភ្លៀង និង៩២គីឡូក្រាមក្នុងមួយហិកតា សម្រាប់ដីស្រែរដូវវស្សា ដែលមាន ប្រព័ន្ធធារាសាស្ត្រស្រោចស្រព។ ការប្រើគ្រាប់ពូជហាក់បីដូចជាខ្ពស់ជាងច្រើនសម្រាប់ដីស្រែសម្រាប់ដាំ ដំណាំបន្ថែម ដែលមានចំនួន ១៥០គីឡូក្រាមក្នុងមួយហិកតា។ ចម្លើយពីបទសម្ភាសន៍ជាមួយកសិករបង្ហាញ ថា គ្រាប់ពូជជាច្រើនត្រូវបានប្រើសម្រាប់ដំណាំបន្ថែមដែលទទួលបានការស្រោចស្រព ដោយសារជាធម្មតា កសិករប្រើវិធីព្រួសសម្រាប់ការដាំដំណាំបន្ថែម ខណៈដែលការស្ទូងនៅតែត្រូវបានអនុវត្តជាទូទៅសម្រាប់ស្រែ វស្សា ទាំងស្រែពឹងលើទឹកភ្លៀង និងស្រែដែលស្រោចស្រពដោយប្រព័ន្ធធារាសាស្ត្រ។

ការប្រើជីគីមីកើតមានច្រើនបំផុតនៅក្នុងដីស្រែដំណាំបន្ថែម។ ជាមធ្យម កសិករបានប្រើ២៧២ គីឡូក្រាមក្នុងមួយហិកតា ដែលខ្ពស់ជាងច្រើនបើប្រៀបធៀបទៅនឹង ១៥១គីឡូក្រាមក្នុងមួយហិកតា សម្រាប់ដីស្រែវស្សាដែលទទួលបានការស្រោចស្រព និង ១២៧ គីឡូក្រាមក្នុងមួយហិកតាសម្រាប់ដីស្រែពឹងលើទឹកភ្លៀង។ ប៉ុន្តែ គំរូនៃការប្រើជីគីមិនខុសគ្នាច្រើនទេរវាងដីស្រែពឹងលើទឹកភ្លៀង និងដីស្រែវស្សាដែលទទួលបានការស្រោចស្រព ថ្វីបើភាពបរិបូរណ៍នៃទឹកធារាសាស្ត្រទំនងជាជម្រុញឲ្យកសិករប្រើប្រាស់ជីច្រើនជាងពេលមុនក្តី។

តារាង ៥.៣. លក្ខណៈដីស្រែ (% នៃដីស្រែ)

| | | | ពឹងលើទឹកភ្លៀង | ស្រោចស្រពរដូវវស្សា | ស្រោចស្រពដំណាំបន្ថែម | សរុប |
|---|---|---|---|---|---|---|
| ល.រ | អថេរ | ចំនួន | ៦០ | ៦០ | ៦០ | ១៨០ |
| ១ | ទំហំដីស្រែជាមធ្យម | [ហិកតា] | ០,៧៦ | ០,៥៨ | ០,៤៥ | ០,៦០ |
| ២ | ពូជកែលម្អ*** | [មែន] | ៣៧% | ៤២% | ៩០% | ៥៦% |
| ៣ | ពូជ*** | [គក/ហិកតា] | ៨០ | ៩២ | ១៥០ | ១០៧ |
| ៤ | ជី *** | [គក/ហិកតា] | ១២៧ | ១៥១ | ២៧២ | ១៨៤ |
| ៥ | ជីកំប៉ុស្ត | [មែន] | ៦៣% | ៦៥% | ៥២% | ៦០% |
| ៦ | ដីស្រែរាបស្មើ | [មែន] | ៦២% | ៤៧% | ៥៣% | ៥៤% |
| ៧ | ប្រព័ន្ធរំដោះទឹក * | [មែន] | ៦០% | ៨៣% | ៨៨% | ៨១% |
| ៨ | ប្រព័ន្ធធារាសាស្ត្រលើស្រែ | [មែន] | ៥% | ៥% | ៥% | ៥% |
| ៩ | បញ្ហាសត្វល្អិតចង្រៃ** | [មែន] | ៧៧% | ៧៣% | ៩៧% | ៨២% |
| ១០ | គ្រប់គ្រងសត្វល្អិតចង្រៃ* | [មែន] | ៦៧% | ៧៥% | ៨៨% | ៧៨% |
| ១១ | គ្រប់គ្រងសត្វល្អិតចង្រៃប្រកបដោយជោគជ័យ | [មែន] | ៧៧% | ៧៦% | ៧៨% | ៧៨% |
| ១២ | បញ្ហាស្មៅ | [មែន] | ៩១% | ៧៧% | ៨៣% | ៨៤% |
| ១៣ | ដកស្មៅ | [មែន] | ៩១% | ៧៧% | ៩០% | ៨៦% |

** បង្ហាញកម្រិតយកជាបានការ (significant level) < 0,0៥ ** កម្រិតយកជាបានការ < 0,0១ *** កម្រិតយកជាបានការ < 0,00១*

ប្រភព: ការស្ទង់មតិបែបរហ័សលើគ្រួសារកសិករ ( ខែ មិថុនា ឆ្នាំ ២០១១ )

ដូចមានបង្ហាញនៅក្នុងតារាង ៥.៣ ប្រព័ន្ធធារាសាស្ត្រហាក់បីដូចជាមិនមានឥទ្ធិពលលើឥរិយាបថរបស់កសិករក្នុងការប្រើជីកំប៉ុស្ត ការពង្រាបដីឲ្យស្មើ និងការដកស្មៅនោះទេ។ ទោះបីជាយ៉ាងនេះក្តី ការប្រើជីកំប៉ុស្តត្រូវបានរកឃើញនៅក្នុងដីស្រែប្រហែល ៦០% នៃដីស្រែដែលបានធ្វើការស្ទង់មតិ ហើយ ៥៤% នៃផ្ទៃដីស្រែគឺរាបស្មើ ខណៈដែល៤៦%ផ្សេងទៀតត្រូវការការពង្រាប។ ទិន្នន័យបង្ហាញថាបញ្ហាស្មៅគឺជាបញ្ហារួមនៅតាមដីស្រែ–៨៤%នៃដីស្រែដែលបានធ្វើការស្ទង់មតិបានជួបប្រទះនឹងបញ្ហាស្មៅ។ បញ្ហាស្មៅហាក់បីដូចជាសាយភាយនៅក្នុងចំណោមដីស្រែពឹងលើទឹកភ្លៀង ប៉ុន្តែបញ្ហានេះក៏មិនមានលក្ខណៈខុសគ្នាច្រើនដែរចំពោះប្រភេទដីស្រែពីរផ្សេងទៀត។

បញ្ហាសត្វល្អិតចង្រៃក៏ត្រូវបានសង្កេតមើលឃើញជាទូទៅផងដែរ នៅតាមដីស្រែកសិកម្មគ្រប់ប្រភេទទាំងអស់ ប៉ុន្តែបញ្ហានេះហាក់បីដូចជាមានកម្រិតខ្ពស់បំផុត នៅក្នុងចំណោមស្រែដំណាំបន្ថែម-- ៩៧%នៃដីស្រែត្រូវបានរាយការណ៍ថាបានទទួលរងផលប៉ះពាល់ពីសត្វល្អិតចង្រៃ ដែលមានកម្រិតខ្ពស់ជាងច្រើន បើប្រៀបធៀបទៅនឹង ៧៥% នៃដីស្រែវស្សាដែលទទួលបានការស្រោចស្រព និង ៧៧% នៃដីស្រែពឹងលើទឹកភ្លៀង។ ជាការឆ្លើយតប គេរកឃើញថាកសិករបានខិតខំកំចាត់សត្វល្អិតចង្រៃនៅក្នុងដីស្រែរងផលប៉ះពាល់ចំនួន ៧៨% ហើយ ៧៨% នៃដីស្រែរងផលប៉ះពាល់ទាំងនេះបានទទួលជោគជ័យក្នុងការកំចាត់សត្វល្អិតចង្រៃ។

ចំនួនករណីមានប្រព័ន្ធធារាសាស្ត្រក្នុងស្រែដូចជាត្រពាំងឬអណ្តូង គឺមានតិចតួចខ្លាំងណាស់នៅក្នុងចំណោមកសិករដែលបានចូលរួមក្នុងការស្ទង់មតិនេះ។ ទោះបីជាមិនមានលទ្ធភាពទទួលបានការស្រោចស្រពពីប្រព័ន្ធធារាសាស្ត្រក្តី ៥% នៃដីស្រែពឹងលើទឹកភ្លៀងត្រូវបានរកឃើញថាមានប្រព័ន្ធធារាសាស្ត្រក្នុងស្រែ។ តួលេខនេះគឺទាបខ្លាំងណាស់ ហើយទាំងដីស្រែរដូវវស្សា និង ដីស្រែដំណាំបន្ថែមដែលមានលទ្ធភាពទទួលបានការស្រោចស្រពពីប្រព័ន្ធធារាសាស្ត្រ ត្រូវបានសង្កេតឃើញថាមានប្រព័ន្ធធារាសាស្ត្រក្នុងស្រែដែលមានសមាមាត្រដូចគ្នាផងដែរទៅនឹង ដីស្រែពឹងលើទឹកភ្លៀង។

### ៥.៣.២. ការកែលម្អផល និងបញ្ហាប្រឈម

ដូចដែលត្រូវបានបង្ហាញដោយទិន្នន័យនៃទិន្នផល ផលិតកម្មដំណាំបន្ថែមដែលទទួលការស្រោចស្រពបានផ្តល់ផលខ្ពស់ជាងគេ (២,៨៨តោនក្នុងមួយហិកតា) ដែលមានចំនួន១៧% ខ្ពស់ជាងដីស្រែវស្សាដែលទទួលបានការស្រោចស្រព និង មានចំនួន៣៦%ខ្ពស់ជាងដីស្រែរដូវវស្សាពឹងលើទឹកភ្លៀង។ ការវិភាគស្ថិតិបញ្ជាក់ថា ទិន្នផលជាមធ្យមនៃដំណាំបន្ថែមគឺខ្ពស់ជាងច្រើនប្រសិនបើប្រៀបធៀបទៅនឹងស្រែពឹងលើទឹកភ្លៀង ប៉ុន្តែទិន្នផលនេះមានលក្ខណៈមិនខុសគ្នាច្រើនទេចំពោះផលជាមធ្យមនៃដីស្រែវស្សាដែលទទួលបានការស្រោចស្រព ដោយទទួលផលបាន២,៤៧តោនក្នុងមួយហិកតា។ ទិន្នន័យនេះបង្ហាញថែមទៀតថាការមានទឹកធារាសាស្ត្រហាក់បីដូចជាបង្កើនផលប្រមាណ១៧%សម្រាប់ស្រែវស្សា ប្រសិនបើប្រៀបធៀបទៅនឹងស្រែដែលពឹងផ្អែកទាំងស្រុងលើទឹកភ្លៀង។ យ៉ាងណាមិញ ស្ថិតិរកឃើញថាផលខុសគ្នាគឺមិនសូវមានភាពគួរឲ្យកត់សំគាល់ខ្លាំងតាមតួលេខស្ថិតិឡើយ។

**រូប ៥.២. ផលស្រូវជាមធ្យមនៅក្នុងចំណោមដីស្រែ ដែលប្រើវិធីផ្សេងៗសំរាប់ការទាញយកទឹកស្រោចស្រពពីប្រព័ន្ធធារាសាស្ត្រ (តោនក្នុងមួយហិកតា)**




ប្រភព: ការស្ទង់មតិបែបរហ័សលើគ្រួសារកសិករ (ខែ មិថុនា ឆ្នាំ ២០១១)

ការរួមចំណែកនៃប្រព័ន្ធធារាសាស្ត្រដល់ការលើកកម្ពស់ផលស្រូវ គឺមានលក្ខណៈមិនច្បាស់លាស់។ នៅក្នុងការស្ទង់មតិ កសិករត្រូវបានស្នើឲ្យរាយការណ៍ថាតើទិន្នផលមានភាពល្អប្រសើរជាងមុនឬទេ ក្រោយពេលស្តារនីតិសម្បទាប្រព័ន្ធរួចហើយ។ លទ្ធផលបង្ហាញថាមិនមែនស្រែស្រោចស្រពទាំងអស់សុទ្ធតែបានទទួលកំណើនទិន្នផលនោះទេ[15] ហើយភាគរយនៃដីស្រែស្រោចស្រពដែលបានទទួលផលខ្ពស់ជាង គឺមិនខុសគ្នាពីដីស្រែពឹងលើទឹកភ្លៀងឡើយ។ ទិន្នន័យបង្ហាញថា ៦១%នៃដីស្រែដាំដំណាំបន្ថែមបានទទួលផលល្អ ប៉ុន្តែសមាមាត្រដូចគ្នានៃដីស្រែដែលពឹងលើទឹកភ្លៀងឬទទួលការស្រោចស្រពក្នុងរដូវវស្សា បានទទួលផលល្អ ៥៦%និង៥៥% ប្រសិនបើប្រៀបធៀបទៅនឹងមុនពេលស្តារនីតិសម្បទាប្រព័ន្ធធារាសាស្ត្រ។ ចំណុចនេះនាំឲ្យមានចម្ងល់ថាតើដីស្រែពឹងលើទឹកភ្លៀងនឹងនៅតែទទួលបានកំណើនទិន្នផលរឺទេ ប្រសិនបើកិច្ចប្រឹងប្រែងស្តារនីតិសម្បទាឬការស្តារនៃប្រព័ន្ធធារាសាស្ត្រអវត្តមាននៅក្នុងមូលដ្ឋាន។ ទោះជាយ៉ាងណាក្តី ចំនុចនេះបង្ហាញថាប្រព័ន្ធធារាសាស្ត្រអាចសាយភាយអត្ថប្រយោជន៍របស់វាដោយប្រយោលទៅដល់ ដីស្រែពឹងលើទឹកភ្លៀងតាមរយៈការផ្សព្វផ្សាយបច្ចេកទេសកសិកម្ម និង/ឬ កត្តាធាតុចូលដ៏ទៃទៀត ដូចជា ពូជកែលម្អ និងការប្រើជីដើម្បីឲ្យផលកសិកម្មបានកាន់តែប្រសើរឡើង។

កសិករដែលបានទទួលកំណើនផលពីស្រែដែលបានចុះធ្វើការស្ទង់មតិ ត្រូវបានស្នើសុំបន្តទៀតឲ្យបង្ហាញពីទស្សនៈរបស់ខ្លួនលើកត្តានានា ដែលរួមចំណែកដល់កំណើននៃផលស្រូវរបស់ពួកគាត់។ កសិករត្រូវបានស្នើសុំឲ្យកំណត់កត្តាមានឥទ្ធិពលផ្សេងៗ និងត្រូវបានស្នើឲ្យដាក់ពិន្ទុលើកម្រិតនៃឥទ្ធិពលនៃកត្តាដោយឡែកនីមួយៗ ផ្អែកលើទស្សនៈរបស់ពួកគាត់។ បន្ទាប់មក ទស្សនៈរបស់ពួកគាត់ត្រូវបានដាក់ពិន្ទុពី ១-៣ (១ = ឥទ្ធិពលតិចតួច ២= ឥទ្ធិពលមធ្យម និង ៣ = ឥទ្ធិពលខ្លាំង)។

លទ្ធផលបង្ហាញថា កម្រិតនៃកត្តាជះឥទ្ធិពលនាំទៅដល់ទិន្នផលល្អប្រសើរ មានភាពខុសគ្នានៅក្នុងចំណោមដីស្រែប្រភេទផ្សេងគ្នា ដែលមានលទ្ធភាពប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រខុសគ្នា។ សម្រាប់ដីស្រែដំណាំបន្ថែមដែលទទួលការស្រោចស្រព កត្តាជះឥទ្ធិពលចំបងគឺការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ/ទឹក បន្ទាប់មក គឺជីគីមី និងការកំចាត់សត្វល្អិតចង្រៃ។ ការរួមចំណែកនៃការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ/ទឹក ដែលបានរួមចំណែកដល់កំណើនទិន្នផល បានដើរតួនាទីយ៉ាងសំខាន់បំផុតសម្រាប់ដីស្រែវស្សាដែលទទួលការស្រោចស្រព ហើយការរួមចំនែកនេះក៏ត្រូវរាប់បញ្ចូលនូវកត្តាធាតុអាកាស/ភ្លៀងធ្លាក់ល្អផងដែរ។ ធាតុអាកាស/ភ្លៀងធ្លាក់ល្អត្រូវបានចាត់ទុកថាជាកត្តាជះឥទ្ធិពលចំបងមកលើកំណើនទិន្នផល នៅក្នុងចំណោមដីស្រែរដូវវស្សាពឹងលើទឹកភ្លៀង ហើយកត្តាជះឥទ្ធិពលបន្ទាប់គឺជីគីមី។ ទាំងអស់នេះបង្ហាញថា តួនាទីនៃប្រព័ន្ធធារាសាស្ត្រគឺសំខាន់បំផុតសម្រាប់ការផលិតដំណាំបន្ថែម ខណៈដែលធាតុអាកាស/ភ្លៀងធ្លាក់ល្អ ត្រូវបានចាត់ទុកថាមានតួនាទីសំខាន់មួយចំពោះដីស្រែរដូវវស្សាពឹងលើទឹកភ្លៀង ហើយទឹកធារាសាស្ត្រនិងធាតុអាកាស/ភ្លៀងធ្លាក់ល្អត្រូវបានចាត់ទុកថាជាកត្តាសំខាន់បំផុតដែលរួមចំណែកដល់ការកែលម្អទិន្នផលនៅក្នុងដីស្រែរដូវវស្សា ដែលទទួលការស្រោចស្រព។

[15] ដីស្រែដែលមិនទទួលបានកំណើនទិន្នផល អាចជាដីស្រែដែលទទួលផលប្រយោជន៍ផងដែរពីទឹកធារាសាស្ត្រ មុនពេលស្តារនីតិសម្បទា ឬ ជាដីស្រែដែលអាចរងផលប៉ះពាល់ពីសត្វល្អិតចង្រៃ ឬកត្តាផ្សេងទៀត។

តារាង ៥.៤. ទស្សនៈរបស់កសិករអំពីកត្តាជះឥទ្ធិពលមកលើទិន្នផលស្រូវ

| ល.រ | កត្តាមានឥទ្ធិពល | | ពឹងលើទឹកភ្លៀង | ស្រោចស្រពរដូវវស្សា | ស្រោចស្រពដំណាំបន្ថែម | សរុប |
|---|---|---|---|---|---|---|
| | | ចំនួន | ២៧ | ៣៣ | ១៧ | ៧៧ |
| | | | កម្រិតនៃឥទ្ធិពល* | | | |
| ១ | ការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ/ទឹក | | ១,៧ | ២,៦ | ២,៧ | ២,៦ |
| ២ | អាកាសធាតុ/ទឹកភ្លៀងល្អ | | ២,៧ | ២,៤ | ២,០ | ២,៥ |
| ៣ | ជីគីមី | | ២,៥ | ១,៩ | ២,៥ | ២,៣ |
| ៤ | ជីកំប៉ុស្ត | | ២,៤ | ២,២ | ១,០ | ២,៣ |
| ៥ | ពូជកែលម្អ | | ២,៤ | ២,០ | ២,១ | ២,២ |
| ៦ | ការកំចាត់សត្វល្អិតចង្រៃ | | ១,៨ | ១,៩ | ២,៤ | ២,០ |
| ៧ | ការកែលម្អដី | | ២,០ | ២,១ | ១,៧ | ២,០ |
| ៨ | ការដកស្មៅ | | ១,៩ | ១,៩ | ១,៨ | ១,៨ |

** កម្រិតនៃឥទ្ធិពលត្រូវបានវាស់លើរង្វាស់ ១-៣: ១ = ឥទ្ធិពលតិចតួច ២=ឥទ្ធិពលមធ្យម និង ៣=ឥទ្ធិពលខ្លាំង*

ប្រភព: ការស្ទង់មតិបែបរហ័សលើគ្រួសារកសិករ (ខែ មិថុនា ឆ្នាំ ២០១១)

កសិករដែលមិនបានទទួលកំណើនទិន្នផលចំពោះដីស្រែស្ថិតក្នុងការសិក្សានេះ ក៏ត្រូវបានស្នើផងដែរឲ្យប្រាប់ពីមូលហេតុដែលធ្វើឲ្យរាំងស្ទះដល់ការបង្កើនទិន្នផល។ ផ្អែកលើការសង្កេតនិងទស្សនៈរបស់ពួកគាត់ កសិករបានលើកពីកត្តារារាំងមួយចំនួនដល់ការបង្កើនទិន្នផលៈ

១. ទឹកជំនន់ / ភ្លៀងធ្លាក់ច្រើនពេក
២. បញ្ហាសត្វល្អិតចង្រៃ
៣. ពូជប្រពៃណី
៤. គ្រោះរាំងស្ងួត / ខ្វះទឹក
៥. ការប្រើជីតិច
៦. បច្ចេកទេសប្រពៃណី / ខ្វះបច្ចេកទេសកសិកម្ម
៧. គុណភាពដីមិនល្អ
៨. កង្វះកម្លាំងពលកម្ម / ខ្វះការថែទាំ
៩. គុណភាពដីទទួលរងសំនឹក។

នៅក្នុងចំណោមដីស្រែដែលមានលទ្ធភាពទទួលបានទឹកធារាសាស្ត្រពីប្រព័ន្ធ កសិករត្រូវបានស្នើឲ្យប្រាប់ថាតើ ពួកគាត់មានបញ្ហាជាមួយការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ/ទឹកឬទេ។ ជាចម្លើយ ២២%នៃកសិករដែលបានសម្ភាសន៍បាននិយាយថាពួកគាត់មានបញ្ហាជាមួយការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ/ទឹក។ បញ្ហាធំៗរួមមានៈ កង្វះទឹក កង្វះសំណង់ស្ទាក់ទឹកនិងប្រឡាយរងទី៣ តម្លៃទឹកថ្លៃ និងការរើសអើងលើការប្រើប្រាស់។ ដោយបានរាយការណ៍ថាមានបញ្ហាជាមួយទឹកធារាសាស្ត្រ ប្រហែល៥៥%នៃកសិករបានមានប្រសាសន៍ថា

ពួកគាត់ប្រឈមមុខនឹងកង្វះទឹក ហើយប្រហែល២៥%បានរាយការណ៍ថាប្រព័ន្ធខ្វះសំណង់ស្ទាក់ទឹក និងប្រឡាយរងទី៣ ដើម្បីបញ្ចូលទឹកទៅក្នុងវាលស្រែ។

### ៥.៣.៣. ផលប៉ះពាល់នៃប្រព័ន្ធធារាសាស្ត្រ

រូប៥.៣ និងរូប៥.៤ បង្ហាញពីផលប៉ះពាល់នៃប្រព័ន្ធធារាសាស្ត្រលើជីវភាពរបស់កសិករ។ រូប ៥.៣ គឺផ្អែកលើចម្លើយពីកសិករថា តើប្រព័ន្ធធារាសាស្ត្របានធ្វើឲ្យជីវភាពរបស់ពួកគាត់បានប្រសើរឡើងឬទេ។ ដូច្នេះ សំណួរនេះគឺអាចអនុវត្តបានតែចំពោះកសិកររដូវវស្សាដែលទទួលបានការស្រោចស្រព និង កសិករដាំដំណាំបន្ថែមដែលទទួលបានការស្រោចស្រព។ យោងតាមលទ្ធផល ៦៧%និង៧៧%នៃកសិកររដូវវស្សាដែលទទួលបានការស្រោចស្រព និងកសិករដាំដំណាំបន្ថែមដែលទទួលបានការស្រោចស្រព បានរាយការណ៍ថាប្រព័ន្ធធារាសាស្ត្របានធ្វើឲ្យជីវភាពពួកគាត់ប្រសើរឡើង ខណៈដែល ២% និង ១០% បានទទួលឥទ្ធិពលខ្លាំងជាងគេដោយបានបញ្ជាក់ថា ប្រព័ន្ធធារាសាស្ត្របានធ្វើឲ្យជីវភាពរបស់ពួកគាត់បានប្រសើរឡើងច្រើន។ ការវិភាគស្ថិតិបង្ហាញថា ប្រព័ន្ធធារាសាស្ត្រជះឥទ្ធិពលខ្លាំងមកលើកសិករដែលដីស្រែរបស់ពួកគាត់អាចស្រោចស្រពបានសម្រាប់ការផលិតដំណាំបន្ថែម។

រូប ៥.៣. ប្រព័ន្ធធារាសាស្ត្រ និងជីវភាព




*N=១២០ កម្រិតយកជាការបាន (Significance level) <0,0៥*
*ប្រភព: ការស្ទង់មតិបែបរហ័សលើគ្រួសារកសិករ (ខែ មិថុនា ឆ្នាំ ២០១១)*

រូប ៥.៤. ថាមវន្តនៃជីវភាព




*N=១២០ កម្រិតយកជាការបាន (Significance level) <0,0១*
*ប្រភព: ការស្ទង់មតិបែបរហ័សលើគ្រួសារកសិករ (ខែ មិថុនា ឆ្នាំ ២០១១)*

រូប៥.៤ បង្ហាញចម្លើយរបស់កសិករអំពីរបៀបដែលជីវភាពរបស់ពួកគាត់បានផ្លាស់ប្តូរ នៅពេលប្រៀបធៀបទៅនឹងមួយឆ្នាំមុន ហើយសំណួរនេះគឺអាចចោទសួរបានចំពោះកសិករទាំងអស់ដែលបានចូលរួមក្នុងការស្ទង់មតិនេះ។ លទ្ធផលបង្ហាញថា ៤០%នៃកសិករដែលមានដីស្រែពឹងលើទឹកភ្លៀង យល់ឃើញថាជីវភាពរបស់ពួកគាត់បានប្រសើរឡើង។ យ៉ាងណាមិញ សមាមាត្រនៃចំនួនកសិករហាក់បីដូចជាខ្ពស់ជាងនៅក្នុងចំណោមកសិករ ដែលដីស្រែរបស់ពួកគាត់អាចទទួលបានការស្រោចស្រពពីប្រព័ន្ធធារាសាស្ត្រ។ ៥២% និង ៥៨% នៃកសិករដែលទទួលបានការស្រោចស្រពក្នុងរដូវវស្សា និងកសិករដែលទទួលបានការស្រោចស្រពសំរាប់ដំណាំបន្ថែម ទទួលបាននូវជីវភាពល្អប្រសើរឡើង បើប្រៀបធៀបទៅនឹងមួយឆ្នាំមុន។ ថ្វីបើកសិករទាំងនេះបានបង្ហាញថា ជីវភាពរបស់ពួកគាត់មានភាពប្រសើរឡើងក្តី ក៏មានកសិករដទៃទៀតបាន

បង្ហាញថាពួកគាត់មិនបានទទួលនូវការផ្លាស់ប្តូរលើផ្នែកជីវភាពនោះទេ ឬជួបប្រទះជីវភាពទាបជាងមុនថែមទៀតផង។ ២៨% នៃកសិករដែលមានដីស្រែពឹងលើទឹកភ្លៀង បានរាយការណ៍ថាជីវភាពរបស់ពួកគាត់បានថមថយទាបជាងមុន។ សមាមាត្រនេះ គឺខ្ពស់ប្រសិនបើប្រៀបធៀបទៅនឹង ៥% និង ១០% នៃកសិករ ដែលជីវភាពរបស់ពួកគាត់បានថមថយផងដែរនោះ និងដែលដីស្រែរបស់ពួកគាត់ទទួលបានការស្រោចស្រពក្នុងរដូវវស្សា និង ការស្រោចស្រពសំរាប់ដំណាំបន្ថែម។

ដើម្បីបង្ហាញពីទំនាក់ទំនងរវាងការទទួលបានការស្រោចស្រពពីប្រព័ន្ធធារាសាស្ត្រ និងជីវភាពរបស់កសិករ អ្នកសម្ភាសន៍ត្រូវបានកំណត់ឲ្យធ្វើចំណាត់ថ្នាក់លើកម្រិតជីវភាពរបស់គ្រួសារដែលបានសម្ភាសន៍ដោយផ្អែកលើព័ត៌មានដែលបានផ្តល់ដោយអ្នកឆ្លើយ និងការសង្កេតរបស់អ្នកសម្ភាសន៍ក្នុងពេលសម្ភាសន៍ដោយពិចារណាលើកម្រិតនៃប្រាក់ចំណូល បំណុល ទីជម្រក និងទ្រព្យ។ ជាលទ្ធផល ១៧%នៃគ្រួសារ មានជីវភាពធូរធារ ៥៥%មានកម្រិតជីវភាពមធ្យម និង ២៨%ផ្សេងទៀតត្រូវបានចាត់ទុកថាមានជីវភាពក្រីក្រ។

តារាង ៥.៥. កម្រិតជីវភាពរបស់កសិករ (% នៃកសិករ)

| | | ពឹងលើ ទឹកភ្លៀង | ស្រោចស្រព រដូវវស្សា | ស្រោចស្រព ដំណាំបន្ថែម | សរុប |
|---|---|---|---|---|---|
| | ចំនួន | ៦០ | ៦០ | ៦០ | ១៨០ |
| ធូរធារ | | ១៧ | ១៣ | ២២ | ១៧ |
| មធ្យម | | ៥៣ | ៥៥ | ៥៧ | ៥៥ |
| ក្រ | | ៣០ | ៣២ | ២២ | ២៨ |
| សរុប | | ១០០ | ១០០ | ១០០ | ១០០ |

ប្រភព: ការស្ទង់មតិបែបរហ័សលើគ្រួសារកសិករ (ខែ មិថុនា ឆ្នាំ ២០១១)

នៅពេលព្យាយាមស្វែងយល់ថាតើ ប្រព័ន្ធធារាសាស្ត្រមានទំនាក់ទំនងជាមួយភាពក្រីក្រឬទេ ទិន្នន័យបានបញ្ជាក់នៅក្នុងតារាង ៥.៥ ដែលបង្ហាញថាការផ្សារភ្ជាប់នេះមានលក្ខណៈមិនច្បាស់លាស់។ ការប្រឈមនឹងភាពក្រីក្រហាក់បីដូចជាមានតិចជាងនៅក្នុងចំណោមកសិករ ដែលទទួលការស្រោចស្រពសំរាប់ដំណាំបន្ថែម(២២%) ប៉ុន្តែភាគរយនេះមិនមានលក្ខណៈស្ថិតិគួរឲ្យកត់សំគាល់នោះទេ ប្រសិនបើប្រៀបធៀបទៅនឹង ៣០%ក្នុងចំណោមកសិករពឹងលើទឹកភ្លៀង។ ម្យ៉ាងទៀត ការប្រឈមនឹងភាពក្រីក្រក្នុងចំណោមកសិករដែលទទួលបានការស្រោចស្រពក្នុងរដូវវស្សា (៣២%) គឺមិនមែនប្រាកដថាទាបទេ បើធៀបទៅនឹងការប្រឈមនឹងភាពក្រីក្រក្នុងចំណោមកសិករពឹងលើទឹកភ្លៀង។

## ៦. សេចក្តីសន្និដ្ឋាន និងទស្សនៈវិស័យអនាគត

ផ្អែកលើការសិក្សាលើឯកសារមានស្រាប់ និងការវាយតម្លៃផ្ទាល់ រួមទាំងការអង្កេតបែបរហ័សជាមួយកសិករនៅក្នុងសហគមន៍ ដែលអាចទទួលបានការស្រោចស្រពពីប្រព័ន្ធធារាសាស្ត្រគេអាចទាញសេចក្តីសន្និដ្ឋានដូចខាងក្រោម។

ផ្ទៃដីស្រោចស្រពនៅថ្នាក់ជាតិហាក់បីដូចជាមិនមានសង្គតិភាព ចំពោះស្ថិតិនិងទិន្នន័យដែលទទួលបានពីឯកសារមានស្រាប់និងប្រភពទិន្នន័យនានា។ តួលេខរាយការណ៍របស់រាជរដ្ឋាភិបាល គឺមានទំហំខ្ពស់ជាងច្រើន នៅពេលប្រៀបធៀបទៅនឹងប្រភពផ្សេងទៀត។ ទិន្នន័យដែលទទួលបានពីការស្ទង់មតិថ្នាក់ជាតិ (CSES ឆ្នាំ២០០៧) បានបង្ហាញថា ២៥%នៃដីកសិកម្មត្រូវបានស្រោចស្រពក្នុងឆ្នាំ២០០៧ ខណៈដែលរាជរដ្ឋាភិបាលកម្ពុជាបានកត់សម្គាល់ថាផ្ទៃដីស្រោចស្រពបានឡើងដល់ ១,១៦ លានហិកតា ក្នុងឆ្នាំ២០១០ ដែលតំណាងឲ្យ៣៣%នៃដីដាំដំណាំ ឬ៤២%នៃផ្ទៃដីធ្វើស្រែ។ ផ្ទុយទៅវិញ មូលដ្ឋានទិន្នន័យឃុំបង្ហាញថាមានតែ ២១% ប៉ុណ្ណោះនៃផ្ទៃដីដាំដុះសរុបនៅកម្ពុជាត្រូវបានស្រោចស្រពក្នុងឆ្នាំ២០០៨។ ដោយសារមូលហេតុទាំងអស់នេះ វាប្រហែលជាត្រូវការការពិនិត្យមើល ឬការពន្យល់បន្ថែមពីក្រសួងធនធានទឹក និងឧតុនិយម ដើម្បីបញ្ជាក់ពីទំហំស្រោចស្រពនៃប្រព័ន្ធធារាសាស្ត្រនៅកម្ពុជា។

ភស្តុតាងពីការវាយតម្លៃផ្ទាល់ បានរកឃើញថាផ្ទៃដីស្រោចស្រពគឺមានកម្រិតសូម្បីតែនៅក្នុងឃុំដែលអាចទទួលបានការស្រោចស្រពពីប្រព័ន្ធធារាសាស្ត្រស្តារឡើងវិញ។ មានតែ ៣៣% ប៉ុណ្ណោះនៃដីស្រែនៅក្នុងឃុំទាំងនេះ បានទទួលប្រយោជន៍ពីទឹកធារាសាស្ត្រ ខណៈដែលដីស្រែដែលនៅសល់ត្រូវពឹងអាស្រ័យលើទឹកភ្លៀងដដែល។ លើសពីនេះទៀត មានតែ ៩% ប៉ុណ្ណោះនៃផ្ទៃដីស្រែវស្សាសរុបនៅក្នុងឃុំ បានទទួលប្រយោជន៍ពីទឹកធារាសាស្ត្រសម្រាប់ការធ្វើស្រែដើមរដូវវស្សា (មេសា-សីហា) និងទទួលបានទឹកបំពេញបន្ថែមពីទឹកភ្លៀង។ ផ្ទៃដីស្រែដែលទទួលប្រយោជន៍ពីទឹកធារាសាស្ត្រសម្រាប់ធ្វើស្រែក្នុងរដូវប្រាំង (ធ្នូ-មេសា) មានត្រឹមតែ ៣% ប៉ុណ្ណោះនៃផ្ទៃដីស្រែវស្សាសរុប។ ចំណុចនេះបង្ហាញយ៉ាងច្បាស់ថា សមត្ថភាពធារាសាស្ត្រក្នុង រដូវប្រាំងគឺមានកម្រិតខ្លាំងណាស់ សូម្បីតែនៅតាមតំបន់ដែលនៅទីនោះទទួលបាននូវគម្រោងស្តារនីតិសម្បទាក៏ដោយ។

របកគំហើញបន្តបង្ហាញថា ប្រព័ន្ធធារាសាស្ត្រកែលម្អនាំមកនូវប្រយោជន៍ច្រើនដល់ជីវភាពរស់នៅ។ ដោយសារកសិករត្រូវបានសាកសួរថា តើប្រព័ន្ធធារាសាស្ត្របានធ្វើឲ្យជីវភាពពួកគាត់ប្រសើរឡើងឬទេ របកគំហើញបង្ហាញទំនាក់ទំនងសំខាន់មួយរវាងថាមវន្តជីវភាពរបស់កសិករ និងការទទួលបានការស្រោចស្រពពីប្រព័ន្ធធារាសាស្ត្រ។ កសិករភាគច្រើនដែលបានទទួលអត្ថប្រយោជន៍ពីប្រព័ន្ធធារាសាស្ត្របានរាយការណ៍ថាប្រព័ន្ធធារាសាស្ត្របានធ្វើឲ្យជីវភាពពួកគាត់ប្រសើរឡើង។ ការស្ទង់មតិបង្ហាញថែមទៀតថាសមាមាត្រនៃកសិករដែលមានជីវភាពប្រសើរឡើងធៀបទៅនឹងឆ្នាំមុន គឺមានកម្រិតខ្ពស់បំផុតនៅក្នុងចំណោមកសិករដែលទទួលបានការស្រោចស្រពសំរាប់ដំណាំបន្ថែម ហើយកម្រិតខ្ពស់បន្ទាប់គឺកសិករដែលទទួលបានការស្រោចស្រពក្នុងរដូវវស្សា។ ផ្ទុយទៅវិញ សមាមាត្រនៃកសិករដែលបានរាយការណ៍ថាជីវភាពរបស់ខ្លួនបានធ្លាក់ចុះធៀបទៅនឹងឆ្នាំមុនៗ គឺមានកម្រិតខ្ពស់ជាងនៅក្នុងចំណោមកសិករពឹងលើទឹកភ្លៀង ប្រសិនបើប្រៀបធៀបទៅនឹងកសិករនៅក្នុងក្រុមពីរផ្សេងទៀត ដែលទទួលបានការស្រោចស្រពពីប្រព័ន្ធធារាសាស្ត្រ។ ទោះបីជាមានឥទ្ធិពលវិជ្ជមានបែបនេះលើជីវភាពរស់នៅក្តី ក៏វាមិនមែនប្រាកដជាមានន័យថាការវិនិយោគលើប្រព័ន្ធធារាសាស្ត្រគឺមានប្រសិទ្ធភាពចំណាយដែរ ដោយសារការវិភាគថ្លៃចំណាយនិងផលប្រយោជន៍មិនត្រូវបានអនុវត្តនៅក្នុងការសិក្សានេះទេ។

ឥទ្ធិពលនៃប្រព័ន្ធធារាសាស្ត្រលើការបង្កើនទិន្នផល ត្រូវបានផ្តល់ចំណាត់ថ្នាក់ខ្ពស់បំផុតដោយកសិករដោយធៀបទៅនឹងកត្តាបង្កើនទិន្នផលផ្សេងទៀត រួមមានជីគីមី ពូជកែលម្អ បច្ចេកទេសកសិកម្ម ការកំចាត់សត្វល្អិតចង្រៃ និង ធាតុអាកាស/ទឹកភ្លៀងល្អ។

ផលប៉ះពាល់ប្រព័ន្ធធារាសាស្ត្រអាចមើលឃើញកាន់តែច្បាស់ក្នុងរយៈពេលវែង ដោយសារវាអាចករកើតមានឡើងទៅតាមពេលវេលា។ ថ្វីបើកសិករបានរាយការណ៍អំពីផលប៉ះពាល់វិជ្ជមាននៃប្រព័ន្ធធារាសាស្ត្រមកលើជីវភាពរបស់ពួកគាត់ក្តី ក៏ទំនាក់ទំនងរវាងការទទួលបានការស្រោចស្រពពីប្រព័ន្ធធារាសាស្ត្រ និងកម្រិតជីវភាព ហាក់ដូចជាមានភាពមិនច្បាស់លាស់។ ការប្រឈមនឹងភាពក្រីក្រគឺមានលក្ខណៈមិនខុសគ្នាច្រើនទេរវាងកសិករពឹងលើទឹកភ្លៀង និងកសិករដែលទទួលផលពីប្រព័ន្ធធារាសាស្ត្រ។ ទោះជាយ៉ាងណាក្តីប្រការនេះមិនមែនប្រាកដជាមានន័យថា ប្រព័ន្ធធារាសាស្ត្រមិនធ្វើឲ្យមានផលប៉ះពាល់ច្រើនលើជីវភាពរបស់កសិករនោះទេ។ ផលប៉ះពាល់អាចករកើតមានឡើងទៅតាមពេលវេលា និងអាចមើលឃើញច្បាស់នៅតាមឆ្នាំក្រោយៗទៀត ដោយសារការវាយតម្លៃនេះទើបត្រូវបានធ្វើឡើងក្នុងរយៈពេល២ឆ្នាំប៉ុណ្ណោះក្រោយពេលស្តារនីតិសម្បទា។ ម្យ៉ាងទៀត ជីវភាពរស់នៅមិនមែនផ្អែកលើប្រព័ន្ធធារាសាស្ត្រតែមួយនោះទេ ប៉ុន្តែថាមវន្តកម្មជីវភាពរស់នៅអាចត្រូវបានរារាំងដោយកត្តាផ្សេងទៀត ក្រៅពីកត្តាប្រព័ន្ធធារាសាស្ត្រ។

អត្ថប្រយោជន៍នៃប្រព័ន្ធធារាសាស្ត្រ ត្រូវបានបង្ហាញដោយការស្ម័គ្រចិត្តរបស់កសិករក្នុងការបង់ថ្លៃទឹករហូតដល់ ៧៥ដុល្លារអាមេរិក និង ១៥៦ដុល្លារអាមេរិកក្នុងមួយហិកតាសម្រាប់ប្រព័ន្ធធារាសាស្ត្រចំនួនពីរនៅខេត្តតាកែវៈ ១) អាងស្តុកទឹកដងខ្ទមសម្រាប់ផ្ទៃដីស្រែវស្សា និង ២) ប្រព័ន្ធធារាសាស្ត្របន្ទាយឆ្លាយសម្រាប់ផ្ទៃដីស្រែប្រាំង។ ការវាយតម្លៃបានរកឃើញថាការកែលម្អប្រព័ន្ធធារាសាស្ត្របាននាំមកនូវអត្ថប្រយោជន៍មួយចំនួនជូនកសិករ ដែលរួមមានទឹកធារាសាស្ត្របំពេញបន្ថែមសម្រាប់ស្រែវស្សា អន្តរាគមន៍នៅពេលមានគ្រោះរាំងស្ងួត ការផលិតដំណាំបន្ថែមនៅដើមរដូវវស្សាឬក្នុងរដូវប្រាំង ផលស្រូវល្អ ប្រព័ន្ធរំដោះទឹកដើម្បីរំដោះទឹកលើសចេញពីវាលស្រែនៅពេលចាំបាច់ ការពង្រីកផលិតកម្មបន្លែ កន្លែងកំសាន្ត ការមានផ្លូវសម្រាប់ធ្វើដំណើរ និងដឹកជញ្ជូនធាតុចូលព្រមទាំងផលិតផលកសិកម្ម ការប្រើប្រាស់របស់គ្រួសារនិងសត្វ និងកំណើនមច្ឆាជាតិជាដើម។

ទោះបីជាមានអត្ថប្រយោជន៍ទាំងនេះក្តី ក៏ដំណើរការប្រព័ន្ធជួបប្រទះនឹងបញ្ហាប្រឈមគួរអោយកត់សម្គាល់មួយចំនួន។ កិច្ចប្រតិបត្តិការ និងការថែទាំប្រព័ន្ធមានភាពទន់ខ្សោយ។ ប្រព័ន្ធខ្លះមិនទាំងមានបង្កើត FWUCដើម្បីដំណើរការនិងថែទាំប្រព័ន្ធ ជាពិសេសប្រព័ន្ធទាំងឡាយដែលត្រូវបានផ្តល់មូលនិធិដោយរាជរដ្ឋាភិបាលកម្ពុជា។ ប្រព័ន្ធផ្សេងទៀតបានបង្កើតFWUC ប៉ុន្តែកិច្ចដំណើរការប្រកបដោយប្រសិទ្ធភាពរបស់ FWUC គឺស្ថិតនៅក្នុងក្តីមន្ទិល។ កសិករមួយចំនួនតូចបង់ថ្លៃទឹក ហើយថ្លៃទឹកនោះគឺមានតម្លៃទាបពេក។

ថ្វីបើការប្រមូលថ្លៃទឹកមានកម្រិតអាចជាលទ្ធផលនៃសមត្ថភាពទាប និងការដឹកនាំទន់ខ្សោយរបស់គណៈកម្មាធិការFWUCក្តី ក៏ការចូលរួមមានកម្រិតរបស់កសិករនៅក្នុងការបង់ថ្លៃទឹកអាចពន្យល់បានដោយការផ្គត់ផ្គង់ទឹកធារាសាស្ត្រមិនគ្រប់គ្រាន់ពីប្រព័ន្ធ និងផលចំណេញទាបចំពោះការផលិតស្រូវ។ ការផ្គត់ផ្គង់ទឹកធារាសាស្ត្រមានកម្រិតត្រូវបានបង្ហាញថែមទៀតថាបណ្តាលមកពី ហេដ្ឋារចនាសម្ព័ន្ធមិនពេញលេញ ដូចជាប្រឡាយរងទី៣និងសំណង់ស្ទាក់ទឹក ប្លង់/ការកែលម្អប្រព័ន្ធមិនល្អ ប្រភពទឹកមានកម្រិត ដូចជាស្ទឹងតូចឬអាងស្តុកទឹកពឹងលើទឹកភ្លៀង ការប្រជែងទាញយកទឹកពីប្រព័ន្ធផ្សេងទៀតនៅខាងលើខ្សែទឹក និងការស្ទាក់ប្រើទឹកធារាសាស្ត្រដោយសារការប្រើអំណាចបំពាន។ ម្យ៉ាងទៀត ការប្រមូលថ្លៃទឹកក៏ជួបការលំបាកផងដែរ ប្រសិនបើប្រព័ន្ធធារាសាស្ត្របំពេញបន្ថែមតែទឹកភ្លៀងក្នុងរដូវវស្សា។ ក្នុងករណីដូចនេះ កសិករមិនចង់បង់ថ្លៃទឹកដោយសារពួកគាត់យល់ថា ទឹកធារាសាស្ត្រគ្រាន់តែបំពេញបន្ថែមនូវទឹកទទួលបានពីទឹកភ្លៀងប៉ុណ្ណោះ ជាពិសេសប្រព័ន្ធធារាសាស្ត្រត្រូវបានចាត់ទុកថាគ្មានប្រយោជន៍អ្វីទេ ប្រសិនបើរដូវវស្សាមានទឹកភ្លៀងធ្លាក់ល្អ។ ម្យ៉ាងទៀត ការមិនចង់បង់ថ្លៃទឹករបស់កសិករក៏ត្រូវបានពន្យល់ផងដែរ ដោយផលចំណេញទាបរបស់ពួកគាត់

លើការផលិតស្រូវ ដោយសារដីគ្មានជីជាតិ ការបំផ្លាញដោយសត្វល្អិតចង្រៃ និងកង្វះជំនាញបច្ចេកទេសរបស់កសិករ។

ដោយផ្អែកលើការរៀនសូត្រពីប្រព័ន្ធធារាសាស្ត្រស្ថិតក្នុងការសិក្សាទាំងនេះ កសិករបានកត់សម្គាល់ពីឥទ្ធិពលសំខាន់នៃប្រព័ន្ធធារាសាស្ត្រមកលើផលិតកម្មកសិកម្ម ក៏ដូចជាជីវភាពរបស់ពួកគាត់ដែរ។ កសិករបានវាយតម្លៃឥទ្ធិពលនៃប្រព័ន្ធធារាសាស្ត្រខ្ពស់បំផុតទាក់ទិននឹង កត្តាផ្សេងទៀតរួមមានជីគីមី និងពូជកែលម្អថាបានរួមចំណែកច្រើនបំផុតដល់កំណើនទិន្នផល។ ទោះជាយ៉ាងណាក្តី ការវាយតម្លៃក៏បានកត់សម្គាល់ផងដែរថាប្រសិទ្ធភាពនៃប្រព័ន្ធធារាសាស្ត្រត្រូវបានថមថយដោយប្លង់/ការកែលម្អមិនល្អនៃប្រព័ន្ធ ការផ្គត់ផ្គង់ទឹកធារាសាស្ត្រមិនគ្រប់គ្រាន់ និងការគ្មានគណៈកម្មាធិការFWUC /គណៈកម្មាធិការFWUCទន់ខ្សោយ។ ហេតុដូច្នេះ ការសិក្សានេះស្នើឲ្យគិតគូរពីបញ្ហាខាងក្រោម ដើម្បីបង្កើនបន្ថែមទៀតនូវប្រសិទ្ធភាពនៃវិស័យធារាសាស្ត្រនៅកម្ពុជា។

- ប្រព័ន្ធធារាសាស្ត្រគប្បីត្រូវបានសាងសង់ ឬស្តារនីតិសម្បទាដោយកសាងហេដ្ឋារចនាសម្ព័ន្ធពេញលេញ មានប្លង់ត្រឹមត្រូវ និងមានការតាមដានមើលការសាងសង់ ឬការស្តារនីតិសម្បទា។ កង្វះនូវប្រឡាយរងទី៣ និងសំណង់ស្ទាក់ទឹក ត្រូវបានរកឃើញថា ជាឧបសគ្គចម្បងនៅក្នុងការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ/ទឹក។ ម្យ៉ាងទៀត ការមានប្លង់ត្រឹមត្រូវ និងការតាមដានមើលការសាងសង់ ឬការស្តារនីតិសម្បទាប្រព័ន្ធនឹងជួយធានាឲ្យបានថា ប្រព័ន្ធនឹងមិនផ្គត់ផ្គង់ទឹកខ្វះដល់ផ្ទៃដីគ្រោងស្រោចស្រពរបស់ប្រព័ន្ធ និងធានាឲ្យបានថាការគ្រប់គ្រងទឹកនឹងមិនត្រូវបានថមថយដោយរចនាសម្ព័ន្ធប្រព័ន្ធនោះទេ។

- កិច្ចប្រឹងប្រែងគប្បីត្រូវធ្វើដើម្បីស្វែងយល់ និងចងក្រងជាឯកសារនូវការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ / ទឹក ឬFWUCsប្រកបដោយជោគជ័យ ដើម្បីអាចដកស្រង់មេរៀនល្អៗសម្រាប់ទុកជាគំរូ។ ទន្ទឹមនឹងនេះ យន្តការផ្សេងទៀតដើម្បីអនុវត្តការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ/ទឹកប្រកបដោយប្រសិទ្ធភាព គួរគប្បីយកមកសាកល្បងផងដែរ ដូចជាការគ្រប់គ្រងដែលដឹកនាំដោយផ្នែកឯកជន ឬថែទាំដោយអង្គការមិនមែនរដ្ឋាភិបាលជាដើម។ ការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ/ទឹក ដឹកនាំដោយផ្នែកឯកជនអនុញ្ញាតឲ្យផ្នែកឯកជន (បុគ្គលឬក្រុមហ៊ុន) ដំណើរការប្រព័ន្ធតាមរយៈការដេញថ្លៃ។ ការគ្រប់គ្រងដែលថែទាំដោយអង្គការមិនមែនរដ្ឋាភិបាល គឺធ្វើឡើងក្នុងន័យអនុញ្ញាតឲ្យអង្គការមិនមែនរដ្ឋាភិបាលប្រកបដោយសមត្ថភាពនិងអាចទុកចិត្តបាន ជួយក្នុងការរៀបចំដំណើរការដែលមានលក្ខណៈជាស្ថាប័នរបស់FWUC ដែលត្រូវបានបង្កើតឡើងនៅក្នុងបណ្តាឆ្នាំដំបូង។ ទោះជាក្នុងករណីណាក៏ដោយ ប្រព័ន្ធផ្តល់គ្រឿងលើកទឹកចិត្តដ៏សមស្របមួយគួរត្រូវរៀបចំឡើងនៅនឹងកន្លែង។

- ការវិភាគថ្លៃចំណាយ និងអត្ថប្រយោជន៍ឲ្យបានស៊ីជម្រៅមួយលើប្រព័ន្ធធារាសាស្ត្រមានស្រាប់នៅតាមកន្លែងផ្សេងៗគ្នានិងប្រភេទដី នឹងផ្តល់ជាសក្ខីភាពកាន់តែច្បាស់សម្រាប់ការសម្រេចចិត្តអំពីកន្លែងណាឬប្រព័ន្ធមួយណា ដែលគប្បីត្រូវកំណត់ជាអាទិភាព ដើម្បីធ្វើផែនការនិងប្រើប្រាស់ធនធានឲ្យបានកាន់តែប្រសើរឡើង។ លើសពីនេះទៀត ដោយសាររបកគំហើញបានបង្ហាញថា ប្រព័ន្ធធារាសាស្ត្រអាចផ្តល់អត្ថប្រយោជន៍ជាច្រើនបន្ថែមលើការផ្តល់ទឹកស្រោចស្រព ពហុប្រយោជន៍/មុខងារនៃប្រព័ន្ធធារាសាស្ត្រគប្បីត្រូវបានគិតគូរឲ្យបានដិតដល់ចំពោះការរៀបចំប្រព័ន្ធ និងត្រូវបានដាក់បញ្ចូល

ទៅក្នុងការគណនាថ្លៃចំណាយនិងអត្ថប្រយោជន៍ ដើម្បីអាចលើកកម្ពស់ប្រសិទ្ធភាពចំណាយរបស់គម្រោងសាងសង់ប្រព័ន្ធធារាសាស្ត្រនីមួយៗ។

- ដោយសារមានរបាយការណ៍ស្រដៀងៗគ្នា ស្តីពីតួលេខនៃទំហំស្រោចស្រពនៃប្រព័ន្ធធារាសាស្ត្រថ្នាក់ជាតិ មកពីប្រភពផ្សេងៗគ្នា វិធីមួយដើម្បីបំភ្លឺឬកំណត់សមត្ថភាព ឬលទ្ធភាពស្រោចស្រពជាក់ស្តែងនៃប្រព័ន្ធធារាសាស្ត្ររបស់កម្ពុជាទាំងមូលគឺជាប្រការចាំបាច់មួយ។ ចំណុចនេះអាចតម្រូវឲ្យមានការពិនិត្យមើលឡើងវិញដ៏មធ្យ័តមួយ ឬការស្ទង់មតិមួយដើម្បីបញ្ជាក់ពីស្ថិតិលទ្ធភាពស្រោចស្រពជាក់ស្តែងនៃប្រព័ន្ធធារាសាស្ត្រដែលបានសាងសង់និងស្តារនីតិសម្បទា ដោយមានការឯកភាពនៅក្នុងចំណោមភាគីពាក់ព័ន្ធ រួមទាំងស្ថាប័នរាជរដ្ឋាភិបាល និងទីភ្នាក់ងារដៃគូអភិវឌ្ឍន៍។ ទន្ទឹមនឹងនេះ កិច្ចប្រឹងប្រែងដើម្បីកែលម្អវិធីប្រមូលទិន្នន័យនៅក្នុងចំណោមស្ថាប័នពាក់ព័ន្ធ និង/ឬមានសមត្ថកិច្ច ក៏គួរតែត្រូវអនុវត្តផងដែរ។

## ៧. ឯកសារយោង


ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ និង ក្រសួងធនធានទឹកនិងឧតុនិយម (ឆ្នាំ ២០០៧)។ យុទ្ធសាស្ត្រកសិកម្មនិងទឹក ឆ្នាំ ២០១០-១៣ រាជធានីភ្នំពេញៈ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ក្រសួងធនធានទឹកនិងឧតុនិយម។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (២០១១)។ របាយការណ៍ប្រចាំឆ្នាំស្តីពីកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ ២០១០-១១ មហាសន្និបាតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ថ្ងៃទី ០៥-០៧ ខែមេសា ឆ្នាំ ២០១១។ រាជធានីភ្នំពេញៈ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ និង ក្រសួងធនធានទឹកនិងឧតុនិយម (២០១០)។ ឯកសាររៀបចំកម្មវិធីសម្រាប់យុទ្ធសាស្ត្រកសិកម្មនិងទឹក ឆ្នាំ ២០១០-១៣ រាជធានីភ្នំពេញៈ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ក្រសួងធនធានទឹកនិងឧតុនិយម។

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល (ឆ្នាំ ២០០៩)។ ស្ថានភាពនៃគម្រោងវិស័យធារាសាស្ត្រភូមិភាគពាយព្យ ត្រួតពិនិត្យដោយអ្នកផ្តល់ប្រឹក្សាឯករាជ្យៈ មិនបោះពុម្ពផ្សាយ។

ង៉ោ សុថាត និង ចាន់ សុផល (ឆ្នាំ ២០១០)។ ហិរញ្ញប្បទានក្នុងវិស័យកសិកម្ម និងសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្មសម្រាប់កសិករខ្នាតតូច រាជធានីភ្នំពេញៈ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា។

រាជរដ្ឋាភិបាលកម្ពុជា (ឆ្នាំ ២០០៥)។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០០៦-១០ រាជធានីភ្នំពេញៈ រាជរដ្ឋាភិបាលកម្ពុជា។

រាជរដ្ឋាភិបាលកម្ពុជា (ឆ្នាំ ២០០៨)។ ការពិនិត្យវាយតម្លៃពាក់កណ្តាលអាណត្តិ ឆ្នាំ ២០០៨ លើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០០៦-១០ រាជធានីភ្នំពេញៈ រាជរដ្ឋាភិបាលកម្ពុជា។

រាជរដ្ឋាភិបាលកម្ពុជា (២០១០)។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ឆ្នាំ ២០០៩-១៣ រាជធានីភ្នំពេញៈ រាជរដ្ឋាភិបាលកម្ពុជា។

ធនាគារពិភពលោក (ឆ្នាំ ២០០៦)។ កម្ពុជាៈ កាត់បន្ថយភាពក្រីក្រឲ្យបានពាក់កណ្តាលមុនដំណាច់ឆ្នាំ ២០១៥? ការវាយតម្លៃភាពក្រីក្រ ឆ្នាំ ២០០៦ រាជធានីភ្នំពេញៈ ធនាគារពិភពលោក។

## ៨. ឧបសម្ព័ន្ធ

### ប្រព័ន្ធទី ១: ប្រព័ន្ធធារាសាស្ត្រត្រាំម្នាស់ [ខេត្តពោធិ៍សាត់]

**ទស្សនៈរួម:** ប្រព័ន្ធនេះស្ថិតនៅក្នុងឃុំត្នោតជុំ ស្រុកក្រគរ។ ប្រព័ន្ធនេះមិនមានសកម្មភាពទាំងស្រុងនៅមុនពេលស្តារនីតិសម្បទា។ ការស្តារនីតិសម្បទាត្រូវបានបញ្ចប់ក្នុងឆ្នាំ ២០១០ ដោយមានជំនួយពីធនាគារអភិវឌ្ឍន៍អាស៊ី និង AFD តាមរយៈគម្រោងវិស័យធារាសាស្ត្រប៉ែកពាយព្យ។ ការស្តារនីតិសម្បទារួមមាន អាងស្តុកទឹក និងទ្វារទឹកមួយកាត់ស្ទឹងត្រាំម្នាស់ ប្រឡាយមេមួយប្រវែង៥,៤គីឡូម៉ែត្រ ប្រឡាយរងទី២ ចំនួន៥ប្រវែង១០គីឡូម៉ែត្រ ប្រឡាយមេរំដោះទឹក១ប្រវែង៣,៤គីឡូម៉ែត្រ និងប្រឡាយរំដោះទឹកទី២ ចំនួន២ ប្រវែង៨,៨គីឡូម៉ែត្រ។ ប្រព័ន្ធនេះគឺសំដៅផ្តល់អត្ថប្រយោជន៍នៃទឹកធារាសាស្ត្រជូនដល់ដីស្រែទំហំ ១.២១២ ហិកតានៅក្នុងភូមិចំនួន ៦ [16]នៃឃុំត្នោតជុំ។

**អត្ថប្រយោជន៍:** អត្ថប្រយោជន៍នៃការស្តារនីតិសម្បទា រួមមាន:

- ទឹកធារាសាស្ត្របំពេញបន្ថែម
- អន្តរាគមន៍ពេលមានគ្រោះរាំងស្ងួត
- ការផលិតដំណាំបន្ថែមក្នុងរដូវប្រាំង
- ផលស្រូវល្អ
- ប្រព័ន្ធរំដោះទឹក
- ផលិតកម្មបន្លែ
- លទ្ធភាពប្រើផ្លូវលើខ្នងប្រឡាយ
- កន្លែងកំសាន្តនៅខាងក្រៅ
- ការប្រើប្រាស់នៅក្នុងគ្រួសារ និងការប្រើប្រាស់របស់សត្វ។

មុនពេលស្តារនីតិសម្បទា ស្រែទាំងអស់នៅក្នុងប្រព័ន្ធនេះ ក៏ដូចជាផ្នែកផ្សេងទៀតរបស់ឃុំគឺពឹងលើទឹកភ្លៀងទាំងស្រុង។ បច្ចុប្បន្ន ប្រជាជនអាចប្រើទឹកធារាសាស្ត្រពីប្រព័ន្ធស្តារនីតិសម្បទា នៅពេលមិនមានទឹកភ្លៀងគ្រប់គ្រាន់។ FWUC បានប៉ាន់ប្រមាណថាផ្ទៃដីគ្រោងស្រោចស្រពទាំងមូលបានទទួលអត្ថប្រយោជន៍ពីប្រព័ន្ធជាមួយទឹកបំពេញបន្ថែមពីទឹកភ្លៀង ប៉ុន្តែនៅពេលមានគ្រោះរាំងស្ងួត ប្រព័ន្ធប្រហែលជាអាចជួយទ្រទ្រង់បានត្រឹមតែ៦៥០ហិកតាប៉ុណ្ណោះ ដែលស្មើពាក់កណ្តាលនៃផ្ទៃដីគ្រោងស្រោចស្រព។ ដោយសារការស្តារនីតិសម្បទាប្រព័ន្ធទើបតែត្រូវបានបញ្ចប់ក្នុងឆ្នាំ២០១០ កសិករទាំងអស់មិនសុទ្ធតែបានទទួលអត្ថប្រយោជន៍ពីទឹកធារាសាស្ត្រនៅក្នុងរដូវវស្សាកន្លងទៅនោះទេ។ ប៉ុន្តែ កសិករដែលបានប្រើទឹកធារាសាស្ត្របាននិយាយថាផលស្រូវរបស់ខ្លួនហាក់បីដូចជាបានកើនឡើងពី ២,៥តោនក្នុងមួយហិកតា ដល់ប្រហែល ៣ តោនក្នុងមួយហិកតា ដែលបង្ហាញពីកំណើន ២០%។

[16] ភូមិសែនប៉ែន ភូមិត្បែងជ្រុំ ភូមិឈើទាល ភូមិកណ្តាល ភូមិចំបក់ធំ និង ភូមិដងទឹកលាជ។

ទឹកក៏មានផងដែរពីប្រព័ន្ធក្នុងរដូវប្រាំង ប៉ុន្តែមិនមានកសិករច្រើនទេដែលបានសាកល្បងធ្វើស្រែ ដោយសារពួកគាត់ចង់សង្កេតមើលបរិមាណទឹក និង កំណត់ថាតើក្បាលទឹកមានគ្រប់គ្រាន់ឬទេ។ ដូច្នេះ ការផលិតស្រូវត្រូវបានសាកល្បងដោយកសិករមួយចំនួនតែប៉ុណ្ណោះ លើស្រែប្រហែល៥០ហិកតា ពីខែមករា ដល់ខែមេសា។ តាមរយៈការសង្កេតមើលបរិមាណទឹកនៅក្នុងរដូវប្រាំងកន្លងទៅ គណៈកម្មាធិការFWUC បានប៉ាន់ស្មានថាប្រព័ន្ធអាចស្រោចស្រពផ្ទៃដីប្រហែល៤៥០ហិកតា ដែលស្មើនឹងប្រមាណ ៣៧% នៃសមត្ថភាពរបស់វាក្នុងរដូវវស្សា។ ការសាកល្បងបង្ហាញថាការដាំដំណាំលើកទីពីរក្នុងរដូវប្រាំង គួរផ្តល់ផលប្រហែល ៤ តោនក្នុងមួយហិកតា ជាមធ្យម។

ជាមួយការផ្តល់ប្រឡាយរំដោះទឹកនៅក្នុងប្រព័ន្ធ ក្រុមប្រឹក្សាឃុំនិងអ្នកផ្តល់ព័ត៌មានគន្លឹះបានសម្តែងទស្សនៈថាកសិករអាចបង្ហៀរទឹកជំនន់ ឬទឹកលើសចេញពីស្រែរបស់ខ្លួនបានដោយងាយនៅពេលចាំបាច់។ ដោយសារសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្មត្រូវបានផ្តល់ជូនជាផ្នែកមួយនៃគម្រោង កសិករបានចាប់ផ្តើមទទួលយក ប៉ុន្តែនៅមិនទាន់បញ្ជ្រាបឲ្យបានទូលាយនៅឡើយនៅតាមសហគមន៍កសិករ។ ម្យ៉ាងទៀត ការស្តារនីតិសម្បទាប្រព័ន្ធ បានអនុញ្ញាតឲ្យប្រជាជនមានឱកាសប្រើផ្លូវក្រាលគ្រួសក្រហមលើខ្នងប្រឡាយ ដែលបង្ករលក្ខណៈងាយស្រួលច្រើនសម្រាប់ការធ្វើដំណើរ និងការដឹកជញ្ជូនធាតុចូល ព្រមទាំងផលិតផលកសិកម្ម។ ការងារចំបងមួយរបស់ប្រព័ន្ធមានគោលបំណងផ្តល់ទឹកន្លែងមួយ សម្រាប់ឲ្យប្រជាជនក្នុងសហគមន៍បានទៅលេងកំសាន្តនៅខាងក្រៅផងដែរ។

**ការថែទាំ:** ក្នុងគោលបំណងធានាឲ្យបាននូវការគ្រប់គ្រង និងការប្រើប្រាស់ទឹកពីប្រព័ន្ធប្រកបដោយនិរន្តរភាព គម្រោងបានចងក្រងកសិករនៅក្នុងប្រព័ន្ធឲ្យក្លាយទៅជាFWUCមួយ ដែលរួមមានកសិករចំនួន ៩២៦នាក់។ គណៈកម្មាធិការFWUC ក៏ត្រូវបានបង្កើតឡើងផងដែរដែលមានសមាជិក ៤រូប (ស្ត្រី ១រូប) ដើម្បីទទួលខុសត្រូវលើការគ្រប់គ្រង កិច្ចប្រតិបត្តិការ និងការថែទាំប្រព័ន្ធ។ គណៈកម្មាធិការFWUC ប្រមូលថ្លៃទឹកពីកសិករ។ យោងតាមFWUC នាពេលបច្ចុប្បន្ន ថ្លៃទឹកនៅមិនទាន់ត្រូវបានយកពីកសិករក្នុងរដូវវស្សាទេ ប៉ុន្តែយកពីកសិករដែលធ្វើស្រែក្នុងរដូវប្រាំង។ ថ្លៃទឹកគឺ ២០.០០០ រៀលក្នុងមួយហិកតា ប្រសិនបើស្រោចស្រពដោយលំហូរតាមទំនាញផែនដី និង ៥.០០០ រៀលក្នុងមួយហិកតា ប្រសិនបើស្រោចស្រពតាមរយៈម៉ាស៊ីនបូមទឹក។ FWUC ពន្យល់បន្ថែមទៀតថាថ្លៃទឹកនឹងឡើងរៀងរាល់ឆ្នាំក្នុងរយៈពេល ៥ឆ្នាំដំបូង ដោយមានគោលដៅឡើងដល់ ៤០.០០០ រៀលក្នុងមួយហិកតា។ FWUC បានរាយការណ៍ថាប្រហែល៤៥% នៃផ្ទៃដីគ្រោងស្រោចស្រពត្រូវបានស្រោចស្រពដោយលំហូរតាមទំនាញផែនដី ខណៈដែល៥៥% ផ្សេងទៀតត្រូវការម៉ាស៊ីនបូមទឹក។

**ជោគជ័យ និង គុណវិបត្តិ:** ក្រុមប្រឹក្សាឃុំ គណៈកម្មាធិការFWUC និង អ្នកផ្តល់ព័ត៌មានគន្លឹះ បានចង្អុលបង្ហាញថា ជោគជ័យនៃការស្តារនីតិសម្បទាប្រព័ន្ធអាចត្រូវរាប់បានក្នុងកម្រិត ៨០% ដោយសារកសិករពេលនេះអាចពឹងលើទឹកធារាសាស្ត្រ នៅពេលមិនមានទឹកភ្លៀងគ្រប់គ្រាន់ ឬនៅពេលមានគ្រោះរាំងស្ងួត។ យោងតាមអាជ្ញាធរមូលដ្ឋាន និងអ្នកផ្តល់ព័ត៌មានគន្លឹះ កសិករនៅក្នុងឃុំជួបប្រទះគ្រោះរាំងស្ងួតស្ទើរតែរាល់ឆ្នាំក្នុងរយៈពេល៥ឆ្នាំកន្លងទៅនេះ។

អ្វីដែលនៅតែជាបញ្ហាប្រឈមមួយសម្រាប់ប្រព័ន្ធ គឺប្រការដែលកសិករខ្វះប្រឡាយរងទី៣ និង សំណង់ស្ទាក់ទឹក។ ប្រឡាយរងទី៣ត្រូវបានគូសប្លង់ដោយប្រព័ន្ធ ប៉ុន្តែវាត្រូវបានទុកឲ្យកសិករជាអ្នកសាងសង់ប្រព័ន្ធដោយខ្លួនឯង។ យោងតាមFWUC កសិករភាគច្រើនដែលមានដីរងផលប៉ះពាល់ពីប្លង់ប្រឡាយរងទី៣ សុខចិត្តបរិច្ចាគដីរបស់ខ្លួន ប៉ុន្តែពួកគាត់ខ្វះកម្លាំងពលកម្មនិងទុនសម្រាប់ជីកប្រឡាយ។

**សេចក្តីសន្និដ្ឋានៈ** ប្រព័ន្ធនៅមិនទាន់ដំណើរការស្រួលនៅឡើយដោយសារវាទើបតែសាងសង់ហើយ។ ហេតុដូច្នេះ កសិករអាចសង្កេតនិងសាកល្បងសមត្ថភាពរបស់ប្រព័ន្ធនៅក្នុងរដូវវស្សានិងរដូវប្រាំងកន្លងទៅ។ ផ្អែកលើការសង្កេតនេះ ប្រព័ន្ធទំនងជានឹងផ្តល់ទឹកគ្រប់គ្រាន់បន្ថែមលើទឹកភ្លៀង។ ប្រព័ន្ធអាចសង្គ្រោះផ្ទៃដីពាក់កណ្តាលនៃផ្ទៃដីគ្រោងស្រោចស្រព ក្នុងពេលមានគ្រោះរាំងស្ងួត និងអនុញ្ញាតឲ្យគេអាចដាំដំណាំបន្ថែមក្នុងរដូវប្រាំងលើផ្ទៃដីប្រហែល ៣៧%នៃតំបន់នេះ។ ក្រៅពីអត្ថប្រយោជន៍ផ្សេងទៀត ការមានទឹកទំនងជាអាចជម្រុញកំណើនផលនៅក្នុងការផលិតស្រូវ។ ទោះបីជាមានអត្ថប្រយោជន៍ទាំងអស់នេះក្តី ក៏កសិករមានការលំបាកក្នុងការយកទឹកពីប្រព័ន្ធ ដោយសារកង្វះសំណង់ស្ទាក់ទឹកនៅតាមទីកន្លែងខ្លះ និងកង្វះប្រឡាយរងសម្រាប់បង្ហូរទឹកបញ្ចូលទៅក្នុងស្រែ។

## ប្រព័ន្ធទី ២: ប្រព័ន្ធធារាសាស្ត្រជ្រៃជើងនិងម្រះព្រៅ [ខេត្តបាត់ដំបង]

**ទស្សនៈរួមៈ** ប្រព័ន្ធនេះស្ថិតនៅក្នុងឃុំជ្រៃនៃស្រុកមោងឫស្សី ខេត្តបាត់ដំបង។ ការស្តារនីតិសម្បទាប្រព័ន្ធបានបញ្ចប់ក្នុងឆ្នាំ២០០៩ដោយមានជំនួយពីសហភាពអឺរ៉ុប តាមរយៈគម្រោងECOSORN។ ការស្តារនីតិសម្បទា រួមមានជាអាទ៍ ប្រឡាយមេប្រវែង២.៩៧៨ម៉ែត្រ ប្រឡាយរងទី២ប្រវែង៤.០០០ម៉ែត្រ ប្រឡាយរងទី៣ប្រវែង១១.០៧៧ម៉ែត្រ និងប្រឡាយរំដោះទឹកប្រវែង១០០ម៉ែត្រ។ ប្រព័ន្ធនេះភាគច្រើនគឺពឹងលើទឹកមកពីស្ទឹងមោង និងសំដៅស្រោចស្រពដីស្រែទំហំ ៥០៦ ហិកតា។

**អត្ថប្រយោជន៍ៈ** ការស្តារនីតិសម្បទាប្រព័ន្ធនេះបានផ្តល់អត្ថប្រយោជន៍ជូនកសិករនៅភូមិជ្រៃជើង និងម្រះព្រៅ (ឃុំជ្រៃ)។ អត្ថប្រយោជន៍ទាំងនេះ រួមមានៈ

- ទឹកធារាសាស្ត្របំពេញបន្ថែម
- អន្តរាគមន៍ពេលមានគ្រោះរាំងស្ងួត
- ការផលិតដំណាំបន្ថែម (ដើមរដូវវស្សា)
- ផលស្រូវល្អ
- លទ្ធភាពប្រើផ្លូវលើខ្នងប្រឡាយ។

ការស្តារនីតិសម្បទា មិនបាននាំឲ្យមានការពង្រីកផ្ទៃដីស្រោចស្រពក្នុងរដូវវស្សាច្រើនទេ។ មុនពេលស្តារនីតិសម្បទា ប្រព័ន្ធក៏បានដំណើរការផងដែរដើម្បីផ្តល់អត្ថប្រយោជន៍ដល់ដីស្រែប្រហែល ៦០ ហិកតានៅក្នុងប្រព័ន្ធ។ ក្រោយពេលស្តារនីតិសម្បទា ផ្ទៃដីគ្រោងស្រោចស្រពទំហំ ៥០៦ ហិកតាអាចទទួលការស្រោចស្រព។ ប៉ុន្តែ ដីប្រហែល ៣០ ហិកតានៃផ្ទៃដីទាំងនេះត្រូវទឹកជន់លិចក្នុងរដូវវស្សា។ ទឹកជំនន់បានធ្វើឲ្យការធ្វើស្រែមិនអាចធ្វើបានក្នុងរដូវវស្សា ប៉ុន្តែអាចធ្វើបានក្នុងរដូវប្រាំងវិញ។ ការស្តារនីតិសម្បទាក៏បានបង្កើនផ្ទៃដីស្រោចស្រពសម្រាប់ដាំដំណាំបន្ថែមនៅដើមរដូវវស្សាផងដែរ ដោយមានកំនើនចាប់ពី ៦០ហិកតា ដល់

២៥០ហិកតា។ អ្នកផ្តល់ព័ត៌មានគន្លឹះបានរាយការណ៍ថា ផលស្រូវវស្សានៅតែមានកម្រិតប្រហែល ២,៣ តោនក្នុងមួយហិកតា ខណៈដែលផលនៃដំណាំបន្ថែមនៅដើមរដូវវស្សាហាក់បីដូចជាបានកើនឡើងពី ២,៥ តោនក្នុងមួយហិកតា ដល់ ប្រហែល៣តោនក្នុងមួយហិកតា ប្រសិនបើប្រៀបធៀបទៅនឹងបណ្តាឆ្នាំមុនពេលស្តារនីតិសម្បទា។ ថ្វីបើការទទួលបានការស្រោចស្រពពីទឹកធារាសាស្ត្រមិនមែនជាកត្តាពន្យល់តែមួយសំរាប់កំនើននេះក៏ដោយ ក៏តួលេខនេះបង្ហាញពីកំណើនផល ២០%ផងដែរ។ ប្រការគួរឲ្យកត់សម្គាល់គឺថាកសិករទទួលផលទាំងអស់ចាំបាច់ត្រូវបូមទឹកធារាសាស្ត្រពីប្រឡាយមេ។ ក្រៅពីអត្ថប្រយោជន៍ទាំងអស់នេះ ប្រឡាយដែលត្រូវបានកែលម្អ ត្រូវបានគេរាយការណ៍ថា បានផ្តល់ផ្លូវធ្វើដំណើរល្អប្រសើរតាមរយៈផ្លូវលើខ្នងប្រឡាយ ដែលអាចប្រើបានសម្រាប់ការធ្វើដំណើរ និងការដឹកជញ្ជូនធាតុចូល ព្រមទាំងផលិតផលកសិកម្ម។

ការវាយតម្លៃបានរកឃើញថា ការស្តារនីតិសម្បទាប្រព័ន្ធបាននាំឲ្យមានឥទ្ធិពលអវិជ្ជមានមួយចំនួន។ ស្រែប្រហែល ៣០ ហិកតានៅក្នុងប្រព័ន្ធត្រូវទឹកជន់លិចក្នុងរដូវវស្សាដោយសារមូលហេតុចំនួនបីៈ ១) សណ្ឋានដីទាប ២) ប្លង់និងការសាងសង់ខុសចំពោះបំពង់រំដោះទឹក និង ៣) កង្វះសំណង់ស្ទាក់ទឹកសម្រាប់ខ្ទប់ ឬស្ទាក់ទិសទឹក។ ប៉ុន្តែ ដីស្រែ៣០ ហិកតានេះអាចធ្វើស្រែបានពីរដង ពោលគឺនៅដើមរដូវវស្សា និងក្នុងរដូវប្រាំង។ គុណវិបត្តិនៃការស្តារនីតិសម្បទាប្រព័ន្ធត្រូវគេបានរាយការណ៍ថា ដីស្រែប្រហែល ១៣០ ហិកតានៅក្រៅប្រព័ន្ធដែលធ្លាប់ទទួលបានទឹកធារាសាស្ត្រដោយលំហូរតាមទំនាញផែនដី សម្រាប់ការធ្វើស្រែនៅដើមរដូវវស្សានិងក្នុងរដូវវស្សា នៅពេលនេះត្រូវស្រោចស្រពដោយម៉ាស៊ីនបូមទឹកទៅវិញ។

**ការថែទាំៈ** FWUCមួយត្រូវបានបង្កើតឡើងដើម្បីដំណើរការ គ្រប់គ្រង និងថែទាំប្រព័ន្ធ។ កសិករចំនួន ២២០នាក់ (ស្ត្រី ៧០នាក់) គឺជាសមាជិករបស់FWUC ដែលនៅក្នុងនោះ សមាជិកចំនួន ១០ នាក់ត្រូវបានជ្រើសរើសជាគណៈកម្មាធិការ FWUC ។ ប៉ុន្តែ គណៈកម្មាធិការ FWUC នៅមិនទាន់ដំណើរការនៅឡើយ។ មានតែប្រធានម្នាក់ប៉ុណ្ណោះដែលត្រូវបានរាយការណ៍ថាបានធ្វើសកម្មភាពមកដល់ពេលនេះ ខណៈដែលសមាជិកផ្សេងទៀតរបស់គណៈកម្មាធិការមិនបានចូលរួម។ ថ្លៃទឹកមិនត្រូវបានប្រមូលដោយសារៈ ១) គណៈកម្មាធិការ FWUC មិនសកម្មឲ្យបានគ្រប់គ្រាន់ជាមួយការគ្រប់គ្រងប្រព័ន្ធនិងទឹកធារាសាស្ត្រ ២) ការផ្គត់ផ្គង់ទឹកស្រោចស្រពសម្រាប់ការធ្វើស្រែនៅដើមរដូវវស្សាគឺមានកម្រិត និង ៣) ការប្រើទឹកធារាសាស្ត្រពីប្រព័ន្ធនៅមានចំនួនតិចដោយសារមានភ្លៀងគ្រប់គ្រាន់ក្នុងរដូវវស្សា និងពុំមានគ្រោះរាំងស្ងួតក្នុងរយៈពេល ៤ ឆ្នាំកន្លងទៅនេះ។

**ជោគជ័យ និង គុណវិបត្តិៈ** អាជ្ញាធរមូលដ្ឋាន និង ប្រជាជនក្នុងសហគមន៍ បានវាយតម្លៃជោគជ័យនៃការស្តារនីតិសម្បទាប្រព័ន្ធក្នុងកម្រិត ៧០% ដោយសារវាពង្រីកផ្ទៃដីស្រោចស្រពសម្រាប់ការធ្វើស្រែរដូវវស្សាផងនិងស្រែបន្ថែមផងនៅដើមរដូវវស្សា និងផ្តល់ផ្លូវធ្វើដំណើរលើខ្នងនៃប្រឡាយមេ។ ជោគជ័យនៃការស្តារនីតិសម្បទាត្រូវបានរារាំងដោយគុណវិបត្តិមួយចំនួន។ សណ្ឋានដីនៃប្រឡាយរងទី៣និងប្រឡាយរងទី២ គឺខ្ពស់ជាងប្រឡាយមេ។ ប្រការនេះគឺដោយសារប្រឡាយមេគឺជាប្រឡាយជីកមួយ ខណៈដែលប្រឡាយរងទី៣និងប្រឡាយរងទី២ សំដៅជួយសម្រួលទឹកធារាសាស្ត្រដោយលំហូរតាមទំនាញផែនដី។ ម្យ៉ាងទៀត ប្រព័ន្ធខ្វះសំណង់មួយសម្រាប់ស្ទាក់ទឹកធារាសាស្ត្រពីប្រឡាយមេ ចូលទៅក្នុងប្រឡាយរងទី២។ ដោយសារមូលហេតុនេះ ទឹកធារាសាស្ត្រមិនអាចហូរពីប្រឡាយមេចូលទៅក្នុងប្រឡាយរងទី៣ ដូច្នេះកសិករចាំបាច់ត្រូវបូមទឹក។

លើសពីនេះទៀត វាធ្វើឲ្យដីស្រែនៅខាងក្រោមខ្សែទឹកនៃប្រឡាយមេត្រូវទឹកជន់លិច ដោយសារសណ្ឋានដីទាបនៃដីស្រែ។

**សេចក្តីសន្និដ្ឋាន:** ការស្តារនីតិសម្បទាបានលើកកម្ពស់សមត្ថភាពនៃប្រព័ន្ធក្នុងការស្រោចស្រពដីស្រែទំហំ ៥០៦ ហិកតាក្នុងរដូវវស្សា និង ដីស្រែប្រហែល ២៥០ ហិកតាសម្រាប់ដំណាំបន្ថែម នៅដើមរដូវវស្សា ដោយបំពេញបន្ថែមលើការស្រោចស្រពទទួលបានពីទឹកភ្លៀង។ ការមានប្រព័ន្ធធារាសាស្ត្រហាក់បីដូចជាជម្រុញកំណើននៅក្នុងផលិតកម្មកសិកម្ម ដោយសារផលស្រូវបានល្អប្រសើរឡើង។ ទោះបីជាមានអត្ថ-ប្រយោជន៍ទាំងអស់នេះក្តី ការកែលម្អប្រព័ន្ធក៏បាននាំមកនូវឥទ្ធិពលអវិជ្ជមានមួយចំនួនដែរ ដូចជាតំបន់ខ្លះត្រូវទឹកជន់លិចដោយសារកង្វះសំណង់ស្ទាក់ទឹក និងប្រព័ន្ធរំដោះទឹក។ ចំពោះកិច្ចដំណើរការរបស់FWUC វាមិនមានលក្ខណៈគួរឲ្យសង្ឃឹមទេ ដោយសារគណៈកម្មាធិការFWUCមិនសកម្ម ហើយការប្រមូលថ្លៃទឹកនៅមិនទាន់បានចាប់ផ្តើមនៅឡើយ។

## ប្រព័ន្ធទី ៣: ប្រព័ន្ធធារាសាស្ត្រប្រឡាយលេខ ១ (ខេត្តបាត់ដំបង)

**ទស្សនៈរួម:** ប្រព័ន្ធនេះស្ថិតនៅក្នុងឃុំចំនួនបី[17] នៃស្រុកចំនួនពីរនៃខេត្តបាត់ដំបង។ ស្ទឹងបវេលគឺជាប្រភពទឹកសម្រាប់ប្រព័ន្ធធារាសាស្ត្រ។ ការស្តារនីតិសម្បទាប្រព័ន្ធបានបញ្ចប់ក្នុងឆ្នាំ ២០១០ ដោយមានជំនួយពីធនាគារអភិវឌ្ឍន៍អាស៊ី និងAFD តាមរយៈគម្រោងវិស័យធារាសាស្ត្រភូមិភាគពាយព្យ។ ការស្តារនីតិសម្បទារួមមានជាអាទិ៍ ប្រឡាយមេមួយប្រវែងប្រហែល ១.៣០០ម៉ែត្រ ប្រឡាយរងទី២មួយប្រវែងប្រហែល ៧.៤០០ម៉ែត្រ ប្រឡាយមេរំដោះទឹកមួយប្រវែងប្រហែល២.៦០០ម៉ែត្រ និងប្រឡាយរំដោះទឹកទី២ចំនួនពីរប្រវែងប្រហែល១.៥០០ម៉ែត្រ។ ប្រព័ន្ធនេះសំដៅផ្តល់ទឹកធារាសាស្ត្រដល់ដីស្រែទំហំ ១.០៦១ ហិកតានៅក្នុងប្រព័ន្ធ។ គម្រោងបានកែប្រឡាយធារាសាស្ត្ររងទី៣ចាស់ៗឲ្យទៅជាកូនប្រឡាយរំដោះទឹករងទី៣ និងបានស្នើឡើងនូវការសាងសង់ប្រឡាយធារាសាស្ត្ររងទី៣ថ្មីៗស្របនឹងប្រឡាយរងចាស់ ដែលត្រូវកសាងដោយមូលនិធិសមូហភាពរបស់កសិករ។

**អត្ថប្រយោជន៍:** បទសម្ភាសន៍ជាមួយភាគីពាក់ព័ន្ធនៅកម្រិតឃុំនិងសហគមន៍ បានបង្ហាញថាការស្តារនីតិសម្បទាប្រព័ន្ធបានផ្តល់អត្ថប្រយោជន៍ជូនកសិករទាំងនៅក្នុងប្រព័ន្ធ[18] និងនៅក្រៅប្រព័ន្ធ។ អត្ថប្រយោជន៍ពីប្រព័ន្ធ រួមមាន:

- ទឹកធារាសាស្ត្របំពេញបន្ថែម
- ផលិតកម្មដំណាំបន្ថែមនៅដើមរដូវវស្សា
- អន្តរាគមន៍ពេលមានគ្រោះរាំងស្ងួត
- អត្ថប្រយោជន៍សាយភាយទៅដល់ប្រព័ន្ធខាងក្រៅ
- ផលស្រូវល្អ

[17] ឃុំខ្នាចរមាស ស្រុកបវេល និង ឃុំរូងជ្រៃ ឃុំបន្សាយត្រែង ស្រុកថ្មគោល។

[18] ភូមិខ្នាចរមាស (ឃុំខ្នាចរមាស) ភូមិប្រកៀប ភូមិគោកខ្ពស់ និង ភូមិបល្ល័ង្កក្រោម (ឃុំរូងជ្រៃ) ភូមិថ្មី ភូមិព្រៃលាវ និង ភូមិកោងកាង (ឃុំបន្សាយត្រែង)។

- សមត្ថភាពរំដោះទឹកចេញ
- លទ្ធភាពប្រើប្រាស់ផ្លូវ និងផ្លូវលើខ្នងទំនប់
- កន្លែងកំសាន្តនៅខាងក្រៅ។

ការស្តារនីតិសម្បទា អនុញ្ញាតឲ្យប្រព័ន្ធមានហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រកែលម្អដើម្បីជួយសម្រួលទឹកស្រោចស្រពទៅក្នុងស្រែ និងបំពេញបន្ថែមលើទឹកភ្លៀងក្នុងរដូវវស្សា។ មុនពេលស្តារនីតិសម្បទា ប្រព័ន្ធបានដំណើរការ និងមានសមត្ថភាពស្រោចស្រពដីស្រែប្រហែល ៦០០ ហិកតានៅក្នុងរដូវនីមួយៗ ពោលគឺដើមរដូវវស្សា និងក្នុងរដូវវស្សា។ បន្ទាប់មក កិច្ចប្រឹងប្រែងស្តារនីតិសម្បទាបានពង្រីកផ្ទៃដីស្រោចស្រពដល់ ១.០៦១ហិកតាក្នុងរដូវវស្សា ដែលជាកំណើនប្រហែល ៧៧%។

ការកែលម្អប្រព័ន្ធបានជម្រុញឲ្យកសិករធ្វើស្រែដើមរដូវវស្សាកាន់តែច្រើនឡើង។ យោងតាម FWUC ដីស្រែទំហំ ១.០៣១ ហិកតាត្រូវបានធ្វើនៅក្នុងផ្ទៃដីគ្រោងស្រោចស្រពនៃប្រព័ន្ធ ប៉ុន្តែកសិករបានជួបប្រទះកង្វះទឹកធារាសាស្ត្រពីប្រព័ន្ធក្នុងឆ្នាំនេះ។ ផ្អែកលើបទពិសោធន៍នេះ ប្រព័ន្ធត្រូវបានប៉ាន់ស្មានថាអាចផ្គត់ផ្គង់ទឹកឲ្យដីស្រែប្រហែល ៧២០ ហិកតាតែប៉ុណ្ណោះ សម្រាប់ការធ្វើស្រែនៅដើមរដូវវស្សា ដែលស្មើនឹង ៧០%នៃផ្ទៃដីប្រព័ន្ធ ឬកំណើន ២០% ប្រសិនបើប្រៀបធៀបទៅនឹងឆ្នាំមុនពេលស្តារនីតិសម្បទា។ ការវាយតម្លៃផ្ទាល់បានបញ្ជាក់ថាផ្ទៃដីគ្រោងស្រោចស្រពនៅក្នុងប្រព័ន្ធមិនត្រូវបានស្រោចស្រពពេញលេញឡើយ ហើយចំណុចនេះត្រូវបានពន្យល់ដោយមូលហេតុទាក់ទិនគ្នាចំនួនបី: ១) សណ្ឋានដីនៃផ្ទៃដីមិនស្រោចស្រពគឺខ្ពស់ជាង និងនៅឆ្ងាយពីទ្វារទឹកជាង ២) ទឹកធារាសាស្ត្រត្រូវបានបង្វែរទៅផ្គត់ផ្គង់ស្រែនៅខាងក្រៅប្រព័ន្ធដែលស្ថិតនៅក្នុងសណ្ឋានដីទាបជាង (ដីស្រែប្រហែល ១.២០០ហិកតា[19] នៅខាងក្រៅប្រព័ន្ធត្រូវបានរាយការណ៍ថាបានទទួលអត្ថប្រយោជន៍ពីទឹកធារាសាស្ត្រ តាមរយៈប្រឡាយរំដោះទឹកមេ) និង ៣) ការផ្គត់ផ្គង់ទឹកពីស្ទឹងបវេលគឺមានតិចដោយសារការប្រជែងពីប្រព័ន្ធធារាសាស្ត្រ ៣ ផ្សេងទៀត[20] នៅខាងលើខ្សែទឹកប្រព័ន្ធ។

ដោយសារការស្តារនីតិសម្បទាប្រព័ន្ធទើបតែត្រូវបានបញ្ចប់ក្នុងឆ្នាំ ២០១០ កសិករភាគច្រើនទើបតែបានចាប់ផ្តើមធ្វើស្រែដើមវស្សាប៉ុណ្ណោះ ដូច្នេះពួកគាត់មិនអាចរាយការណ៍ថាតើផលស្រូវរបស់ពួកគាត់នឹងកើនឡើង ឬយ៉ាងណានោះទេ។ ប៉ុន្តែ មានកសិករមួយចំនួនដែលបានទទួលអត្ថប្រយោជន៍ពីទឹកធារាសាស្ត្រពីប្រព័ន្ធក្នុងឆ្នាំ ២០១០ នៅក្នុងផ្នែកស្តារនីតិសម្បទានៃប្រព័ន្ធ។ ចម្លើយពីកសិករទាំងនេះ បង្ហាញកំណើនផលពី ៣ តោនក្នុងមួយហិកតា ដល់ ៣,៥ តោនក្នុងមួយហិកតា សម្រាប់ស្រែដើមរដូវវស្សា និងស្រែវស្សា។

ការស្តារនីតិសម្បទាប្រព័ន្ធ រួមមានការកែលម្អផ្លូវប្រហែល ៨ គីឡូម៉ែត្រដែលឆ្លងកាត់ប្រព័ន្ធ។ ម្យ៉ាងទៀត កសិករក៏ទទួលអត្ថប្រយោជន៍ផងដែរពីប្រព័ន្ធធារាសាស្ត្រនិងប្រឡាយរំដោះទឹក នូវផ្លូវលើខ្នងប្រឡាយក្រាលគ្រួសក្រហមប្រវែងប្រហែល២០គីឡូម៉ែត្រ ដែលរថយន្តនិងគោយន្តអាចធ្វើដំណើរបាន។ កសិករបានសម្តែងការពេញចិត្តរបស់ខ្លួនយ៉ាងខ្លាំងជាមួយនឹងផ្លូវ ជាពិសេសសម្រាប់ការដឹកជញ្ជូនធាតុចូល និងផលិតផលកសិកម្មរបស់ពួកគាត់។

---

[19] ដីស្រែអាចធ្វើបានសម្រាប់ទាំងដំណាំរដូវវស្សា និងដំណាំបន្ថែមនៅដើមរដូវវស្សា។

[20] ប្រព័ន្ធធារាសាស្ត្រពុទ្រា ប្រព័ន្ធធារាសាស្ត្រដូនដៀវ និងប្រព័ន្ធធារាសាស្ត្រព្រែកសង្កា។

**ការថែទាំ:** ដោយមានជំនួយពីគម្រោងស្តារនីតិសម្បទា FWUCត្រូវបានបង្កើតឡើង។ កសិករចំនួន ៥១៣ នាក់ ដែលមានដីស្រែក្នុងប្រព័ន្ធគឺជាសមាជិករបស់FWUC ដែលនៅក្នុងនោះ កសិករចំនួន ៣០ (ស្ត្រី ០១នាក់) ត្រូវបានជ្រើសរើសឲ្យធ្វើជាគណៈកម្មាធិការFWUC ដែលមានភារកិច្ចដំណើរការ គ្រប់គ្រង និងថែទាំប្រព័ន្ធ។ បទសម្ភាសន៍ជាមួយគណៈកម្មាធិការFWUC បានបង្ហាញថាគម្រោងនឹងជួយដល់ការថែទាំក្នុងរយៈពេលប្រាំឆ្នាំ ដោយចែករំលែកការបង់ថ្លៃថែទាំ ៨០% ៦០% ៤០% ២០% ក្នុងរយៈពេលបួនឆ្នាំដំបូងក្រោយពេលស្តារនីតិសម្បទា ខណៈដែលFWUCនឹងរួមចំណែកដល់ថ្លៃចំណាយដែលនៅសល់ និងទទួលខុសត្រូវទាំងស្រុងលើថ្លៃចំណាយលើការថែទាំចាប់ពីឆ្នាំទីប្រាំ។ ធនធានហិរញ្ញវត្ថុរបស់FWUC ត្រូវតែបានមកពីការប្រមូលថ្លៃទឹកធារាសាស្ត្រ។

ថ្លៃទឹកធារាសាស្ត្រត្រូវបានយកដូចតទៅនេះ ១០.០០០ រៀលក្នុងមួយហិកតាសម្រាប់ប្រព័ន្ធធារាសាស្ត្របូម ២០.០០០ រៀលក្នុងមួយហិកតាសម្រាប់ប្រព័ន្ធធារាសាស្ត្រចម្រុះបូម និងលំហូរតាមទំនាញផែនដី ហើយ ៣០.០០០ រៀលក្នុងមួយហិកតាសម្រាប់ប្រព័ន្ធធារាសាស្ត្រលំហូរតាមទំនាញផែនដី។ ប៉ុន្តែ គណៈកម្មាធិការ FWUC បានរាយការណ៍ថា ថ្វីបើប្រព័ន្ធត្រូវបានគ្រោងផ្តល់ទឹកធារាសាស្ត្រដោយលំហូរតាមទំនាញផែនដីភាគច្រើនក្តី ក៏៨០%នៃដីស្រែនៅក្នុងប្រព័ន្ធត្រូវបានស្រោចស្រពដោយម៉ាស៊ីនបូមទឹកដែរ។ គេបានពន្យល់ថាប្រព័ន្ធធារាសាស្ត្របូមទឹកត្រូវបានប្រើ ដោយសារលំហូរតាមទំនាញផែនដីមានភាពយឺត ដែលជាហេតុមិនអាចទាញការស្រោចស្រពឲ្យបានច្រើន ពីការបញ្ចេញទឹកធារាសាស្ត្រពីខ្សែទឹកខាងលើក្នុងរយៈពេលបួនថ្ងៃនៃរាល់ពីរសប្តាហ៍។ ទាក់ទិននឹងការប្រមូលថ្លៃទឹក គណៈកម្មាធិការFWUCបានត្អូញត្អែរថា វាគឺជាបញ្ហាប្រឈមដ៏ពិបាកមួយក្នុងការទាមទារឲ្យប្រជាជនបង់ថ្លៃទឹក ដោយសារការផ្គត់ផ្គង់ទឹកគឺមានកម្រិតសម្រាប់ពួកគាត់។ ដោយសារមូលហេតុនេះ ប្រហែល ៣០%នៃសមាជិកFWUCបានបង់ថ្លៃទឹករបស់ពួកគេ។

**ជោគជ័យ និង គុណវិបត្តិ:** អាជ្ញាធរមូលដ្ឋាន និងប្រជាជនក្នុងសហគមន៍បានវាយតម្លៃការស្តារនីតិសម្បទាប្រព័ន្ធថាបានទទួលជោគជ័យ ៨០% ដោយសារវាបានពង្រីកផ្ទៃដីស្រោចស្រព ទាំងក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ ហើយបានផ្តល់ផ្លូវធ្វើដំនើរល្អប្រសើរដល់កសិករ។ យ៉ាងណាមិញ កសិករបានរាយការណ៍គុណវិបត្តិដូចខាងក្រោម:

- ពុំមានការផ្តល់ប្រឡាយរងទី៣ លើកលែងតែប្លង់របស់វា។ តាមទស្សនៈរបស់គណៈកម្មាធិការ FWUC កសិករមិនព្រមកសាងប្រឡាយរងទី៣ដោយប្រើមូលនិធិសមូហភាពរបស់ពួកគាត់ ដោយសារពួកគាត់មើលឃើញថាការប្រើប្រឡាយរងចាស់ និងម៉ាស៊ីនបូមទឹកគឺជាជម្រើសមួយប្រសើរជាង។
- ការផ្គត់ផ្គង់ទឹកធារាសាស្ត្រខ្វះសម្រាប់ស្រែនៅក្នុងប្រព័ន្ធ ដោយសារការប្រជែងពីប្រព័ន្ធធារាសាស្ត្រផ្សេងទៀតនៅខាងលើខ្សែទឹក។
- ការផ្គត់ផ្គង់ទឹកធារាសាស្ត្រខ្វះក៏បណ្តាលមកពីការប្រជែងពីកសិករ នៅក្រៅប្រព័ន្ធផងដែរ។ មានការចោទប្រកាន់ថា កសិករនៅក្រៅប្រព័ន្ធបង់ថ្លៃក្រៅផ្លូវការឲ្យអាជ្ញាធរទឹក។
- កសិករនៅក្រៅប្រព័ន្ធទទួលអត្ថប្រយោជន៍ពីទឹកធារាសាស្ត្រ ដោយមិនចាំបាច់ត្រូវបង់ថ្លៃទឹក ខណៈដែលកសិករនៅក្នុងប្រព័ន្ធជួបប្រទះការផ្គត់ផ្គង់ទឹកធារាសាស្ត្រខ្វះ។

**សេចក្តីសន្និដ្ឋាន:** ការស្តារនីតិសម្បទាប្រព័ន្ធបាននាំឲ្យមានប្រព័ន្ធធារាសាស្ត្រប្រសើរឡើង រួមទាំងប្រព័ន្ធធារាសាស្ត្រ និងប្រឡាយរំដោះទឹក ដែលបានជួយពង្រីកផ្ទៃដីស្រោចស្រពសម្រាប់ការធ្វើស្រែក្នុងរដូវវស្សានិងនៅដើមរដូវវស្សា ទាំងនៅក្នុងនិងក្រៅប្រព័ន្ធ។ ដីស្រែនៅក្រៅប្រព័ន្ធទទួលអត្ថប្រយោជន៍ពីប្រព័ន្ធតាមរយៈប្រឡាយរំដោះទឹក និងត្រូវបានរាយការណ៍ថាមានទំហំធំប៉ុនផ្ទៃដីគ្រោងស្រោចស្រពនៅក្នុងប្រព័ន្ធដែរ។ ម្យ៉ាងទៀត ការស្តារនីតិសម្បទាបានផ្តល់ផ្លូវសម្រាប់ឲ្យកសិករធ្វើដំណើរ និងដឹកជញ្ជូនធាតុចូល ព្រមទាំងផលិតផលកសិកម្មរបស់ពួកគាត់។ ទោះជាយ៉ាងណាក្តី ប្រព័ន្ធនេះខ្វះប្រឡាយរងទី៣ ហើយជួបប្រទះការផ្គត់ផ្គង់ទឹកធារាសាស្ត្រខ្វះសម្រាប់ស្រែនៅដើមរដូវវស្សា ដោយសារមានការប្រជែងតម្រូវការទឹកពីប្រព័ន្ធផ្សេងទៀតនៅខាងលើខ្សែទឹក និងមានទំនាស់ផលប្រយោជន៍លើទឹកធារាសាស្ត្រដោយកសិករនៅក្រៅប្រព័ន្ធ។ ដោយសារគុណវិបត្តិទាំងអស់នេះ មានផ្ទៃដីតែ៧០%ប៉ុណ្ណោះនៃផ្ទៃដីគ្រោងស្រោចស្រពនៅប្រព័ន្ធត្រូវបានស្រោចស្រពជាក់ស្តែង សម្រាប់ស្រែដើមរដូវវស្សា។ ៨០% នៃស្រែនៅក្នុងប្រព័ន្ធត្រូវបានស្រោចស្រពដោយម៉ាស៊ីនបូមទឹក ជាជាងលំហូរតាមទំនាញផែនដីតាមការគ្រោងទុក ហើយមានតែ៣០%ប៉ុណ្ណោះនៃសមាជិកFWUC បានបង់ថ្លៃទឹករបស់ពួកគេ។

## ប្រព័ន្ធទី ៤: ប្រព័ន្ធធារាសាស្ត្រពន្លៃ [ខេត្តបន្ទាយមានជ័យ]

**ទស្សនៈរួម:** ប្រព័ន្ធនេះស្ថិតនៅក្នុងភូមិពន្លៃ ឃុំពន្លៃ ស្រុកភ្នំស្រុក។ អាងស្តុកទឹកចំណុះប្រហែល ៣ លានម$^3$ ត្រូវបានស្តារនីតិសម្បទា ខណៈដែលប្រឡាយធារាសាស្ត្រត្រូវបានគ្រោងថ្មី និងត្រូវបានសាងសង់ដោយគម្រោងវិស័យធារាសាស្ត្រភូមិភាគពាយព្យ ដែលផ្តល់មូលនិធិដោយធនាគារអភិវឌ្ឍន៍អាស៊ី និង AFD។ អាងស្តុកទឹកលាតសន្ធឹងលើផ្ទៃដីទំហំ ៦៤៥ ហិកតា[21]។ ការស្តារនីតិសម្បទា និងការសាងសង់ប្រព័ន្ធត្រូវបានបញ្ចប់ក្នុងឆ្នាំ ២០០៩ និង គ្រោងស្រោចស្រពដីស្រែទំហំ ៧៥៧ ហិកតារបស់គ្រួសារចំនួន ៧៦៥ នៅក្នុងភូមិចំនួន ៤ នៃឃុំចំនួនពីរ គឺឃុំពន្លៃ ស្រុកភ្នំស្រុក និង ឃុំផ្គាំ ស្រុកស្វាយចេក។ តួលេខនេះបង្ហាញថាអាងស្តុកទឹកទំហំមួយហិកតាអាចផ្គត់ផ្គង់ទឹកធារាសាស្ត្រសម្រាប់ដីស្រែប្រហែល ១,២ ហិកតា។

**អត្ថប្រយោជន៍:** យោងតាមគណៈកម្មាធិការFWUC ប្រព័ន្ធធារាសាស្ត្រពន្លៃត្រូវបានកសាងតាមគំរូ លំហូរតាមទំនាញផែនដី និង ផ្តល់អត្ថប្រយោជន៍ដូចខាងក្រោម៖

- ទឹកធារាសាស្ត្របំពេញបន្ថែម
- អន្តរាគមន៍ពេលមានគ្រោះរាំងស្ងួត
- ការផលិតដំណាំបន្ថែមក្នុងរដូវប្រាំង
- សមត្ថភាពរំដោះទឹកចេញ
- ផលស្រូវល្អ
- ផ្លូវសម្រាប់ការដឹកជញ្ជូន
- អត្ថប្រយោជន៍ផ្សេងទៀតដូចជាត្រីជាដើម។

[21] ឯកសារគម្រោងវិស័យធារាសាស្ត្រភូមិភាគពាយព្យ។

គណៈកម្មាធិការFWUC បានអធិប្បាយថាដីស្រែប្រហែលជិត ៨០០ហិកតាទទួលអត្ថប្រយោជន៍ពីប្រព័ន្ធ។ មុនពេលស្តារនីតិសម្បទា អាងនេះស្តុកទឹកទុកបានតិចជាង និងអាចស្រោចស្រពដីស្រែប្រហែល ៣៥០ ហិកតា ដែលមានន័យថាដីស្រែ ៤៥០ ហិកតា ឬ ប្រហែលជា ១៣០% បានទទួលការស្រោចស្រពពីទឹកធារាសាស្ត្រ។ ម្យ៉ាងទៀត វត្តមាននៃប្រព័ន្ធរំដោះទឹកក៏អនុញ្ញាតផងដែរឲ្យកសិករអាចរំដោះទឹកជំនន់ ឬទឹកលើសចេញពីដីស្រែរបស់ពួកគាត់បានដោយងាយនៅពេលចាំបាច់។ ឧទាហរណ៍ ស្រែប្រហែល ២៥០ ហិកតាត្រូវបានសង្គ្រោះពីទឹកជំនន់ក្នុងរដូវវស្សា។ គួរឲ្យកត់សម្គាល់ ផលស្រូវជាមធ្យមក្នុងរដូវវស្សាត្រូវបានរាយការណ៍ថាបានកើនឡើងពីប្រហែល ១,៥ តោនក្នុងមួយហិកតា ដល់ប្រហែល ២ តោនក្នុងមួយហិកតា ដែលតំណាងឲ្យកំណើន៣៣% ទោះបីជាប្រព័ន្ធធារាសាស្ត្រមិនមែនគឺជាកត្តាពន្យល់តែមួយគត់ក្តី។

ការដាំដំណាំបន្ថែមក្នុងរដូវប្រាំង ក៏អាចធ្វើទៅបានផងដែរដោយសារមានប្រព័ន្ធធារាសាស្ត្រ។ ប៉ុន្តែដោយបរិមាណទឹកមានកម្រិតនៅក្នុងអាងស្តុកទឹក មានដីស្រែប្រហែល ៦០ ហិកតាប៉ុណ្ណោះដែលអាចត្រូវបានស្រោចស្រពក្នុងរដូវប្រាំង។ សមាមាត្រដីនេះតំណាងឲ្យប្រហែល ៨%ប៉ុណ្ណោះនៃសមត្ថភាពស្រោចស្រពរបស់ប្រព័ន្ធក្នុងរដូវវស្សា។ ដើម្បីបែងចែកអត្ថប្រយោជន៍ក្នុងចំណោមសមាជិករបស់FWUC កសិករបានដាក់វេនគ្នាធ្វើស្រែប្រាំងពីដីស្រែមួយដុំទៅដីស្រែមួយដុំទៀតរាល់ឆ្នាំ។ ផលស្រូវនៃស្រែប្រាំងបន្ថែម ត្រូវបានរាយការណ៍ថាមានប្រហែល ២តោនក្នុងមួយហិកតា។ គណៈកម្មាធិការFWUC បានលើកឡើងថា ការបង្ហាញវាលស្រែពូជស្រូវផ្ការំដួល គឺជាផ្នែកមួយនៃសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្មរបស់ប្រព័ន្ធ ដែលទទួលផលបាន ៤ តោនក្នុងមួយហិកតា។

ការស្តារនីតិសម្បទាប្រព័ន្ធធារាសាស្ត្រពន្លៃ ក៏បានអនុញ្ញាតផងដែរឲ្យប្រជាជនអាចប្រើទំនប់អាងស្តុកទឹក និងទំនប់ប្រឡាយជាផ្លូវធ្វើដំណើរ។ ក្នុងន័យនេះ ប្រព័ន្ធបានផ្តល់ជាផ្លូវក្រាលគ្រួសក្រហមប្រវែង ៨,៥ គីឡូម៉ែត្រលើទំនប់នៃអាងស្តុកទឹក ដែលអាចធ្វើដំណើរបានដោយម៉ូតូ និងរថយន្ត។ ម្យ៉ាងទៀត អាងស្តុកទឹកទ្រទ្រង់មច្ឆជាតិកាន់តែច្រើន ដែលជាប្រភពអាហារសម្រាប់ប្រជាជនមូលដ្ឋាន។

ទោះបីជាមានអត្ថប្រយោជន៍ទាំងអស់នេះក្តី ក៏ការស្តារនីតិសម្បទាប្រព័ន្ធបានផ្តល់ផលប៉ះពាល់ខ្លះលើប្រជាជនមូលដ្ឋានផងដែរ។ ឧទាហរណ៍ ប្រហែលជា១០០គ្រួសារធ្លាប់បានទទួលអត្ថប្រយោជន៍ពីការធ្វើស្រែវស្សាលើដីស្រែប្រហែល ១៤០ហិកតានៅក្នុងអាងស្តុកទឹក ប៉ុន្តែនៅពេលនេះ មិនអាចធ្វើបានតទៅទៀតទេ ដោយសារទឹកជំនន់ដែលបង្កដោយការស្តុកទឹករបស់អាង។

**ការថែទាំ:** FWUCត្រូវបានបង្កើតឡើងក្រោយពេលស្តារនីតិសម្បទា និងសាងសង់ប្រព័ន្ធ ហើយត្រូវបានប្រគល់ភារកិច្ចឲ្យទទួលបន្ទុកលើកិច្ចប្រតិបត្តិការ ការគ្រប់គ្រង និង ការថែទាំប្រព័ន្ធ។ ប៉ុន្តែ FWUCមានកាតព្វកិច្ចទទួលខុសត្រូវ តែលើផ្ទៃដីខាងក្រោមខ្សែទឹកនៃប្រព័ន្ធដែលរួមមានប្រឡាយ និងប្រព័ន្ធរំដោះទឹក ខណៈដែលក្រសួងធនធានទឹក និងឧតុនិយម ទទួលបន្ទុកលើការថែទាំក្បាលហុងទឹកដែលរួមមានអាងស្តុកទឹក និងទ្វារទឹក។ ម្យ៉ាងទៀត គម្រោងនឹងចែករំលែកថ្លៃចំណាយលើការថែទាំជាមួយFWUC ៨០% ៦០% ៤០% ២០% ក្នុងរយៈពេលបួនឆ្នាំ ក្រោយពេលស្តារនីតិសម្បទា ខណៈដែលFWUCនឹងទទួលបន្ទុកទាំងស្រុងលើថ្លៃចំណាយលើការថែទាំចាប់ពីឆ្នាំទីប្រាំទៅ។

FWUC ត្រូវបានចែកចេញជាក្រុមធំៗចំនួន ៣ និងក្រុមរងចំនួន ១២ ជាមួយគ្រួសារជាសមាជិកសរុបចំនួន ៤៣៨។ គណៈកម្មាធិការ FWUC ប្រមូលថ្លៃប្រើទឹកពីសមាជិករបស់ខ្លួនក្នុងតម្លៃ ៤០.០០០ (១០ ដុល្លារអាមេរិក) សម្រាប់ការធ្វើស្រែប្រាំងបន្ថែមក្នុងមួយហិកតា។ ក្នុងរយៈពេល ២ឆ្នាំចុងក្រោយនេះ ថ្លៃទឹកជាង ៣ លានរៀលត្រូវបានប្រមូលបាននិងតម្កល់ទុកនៅក្នុងធនាគារ។ ថ្លៃទឹកសម្រាប់រដូវវស្សានៅមិនទាន់បានអនុវត្តនៅឡើយ ប៉ុន្តែ FWUC មានផែនការប្រមូលនៅក្នុងរដូវខាងមុខក្នុងតម្លៃ ១០.០០០ រៀល (២,៥ ដុល្លារអាមេរិក) ក្នុងមួយហិកតា។

ចំពោះការគ្រប់គ្រងប្រព័ន្ធនិងទឹក FWUCជួបប្រទះនឹងបញ្ហាប្រឈមមួយចំនួន។ ជារួម គណៈកម្មាធិការFWUCបានរាយការណ៍ថាសមាជិកពិតជាបង់ថ្លៃទឹក ប៉ុន្តែពួកគាត់មិនបង់ទាំងអស់នោះទេ ខណៈដែលអ្នកខ្លះមិនបង់សោះតែម្តង។ បញ្ហាប្រឈមផ្សេងទៀតរួមមាន ការប្រជែងលើតម្រូវការទឹកធារាសាស្ត្រពីប្លុកផ្សេងៗគ្នា កង្វះការចូលរួមពីសមាជិកFWUC និងកង្វះខាតក្នុងការអនុវត្តបទបញ្ញត្តិ រួមទាំងបទបញ្ជាផ្ទៃក្នុងរបស់ FWUC។

**ជោគជ័យ និង គុណវិបត្តិ:** កម្រិតនៃជោគជ័យរបស់ប្រព័ន្ធធារាសាស្ត្រត្រូវបានវាយតម្លៃក្នុងកម្រិតប្រហែល ៨០%។ ការវាយតម្លៃបែបនេះគឺដោយសារការស្តារនីតិសម្បទាប្រព័ន្ធមិនមែនធ្វើឡើងត្រឹមតែអាងស្តុកទឹកប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់ជាទ្វារទឹក សំណង់ស្ទាក់ទឹក ប្រឡាយស្រោចស្រពពេញលេញ (ប្រឡាយមេ ប្រឡាយរងទី២ និងប្រឡាយរងទី៣) និងប្រព័ន្ធរំដោះទឹក។ ចំណុចខ្លាំងនៃគម្រោងក៏អាចកើតចេញមកពីការពិគ្រោះយោបល់ជាមួយនឹងការផ្តល់ការបណ្តុះបណ្តាលជូនអាជ្ញាធរមូលដ្ឋាន និងអ្នកទទួលផលផងដែរ។ ដីដែលត្រូវរងផលប៉ះពាល់ដោយការស្តារនីតិសម្បទាប្រព័ន្ធនិងសំណង់ ត្រូវបានសងជាប្រាក់ក្នុងតម្លៃប្រហែល ០,១៦ដុល្លារអាមេរិកក្នុងមួយម៉ែត្រការ៉េ។ ប៉ុន្តែ អ្វីដែលប្រជាជនរកឃើញថាជាគុណវិបត្តិរបស់ប្រព័ន្ធ គឺគុណភាពរបស់ប្រព័ន្ធ។ គណៈកម្មាធិការ FWUC និង អាជ្ញាធរមូលដ្ឋាន បាននិយាយថាអ្នកម៉ៅការសំណង់មិនបានអនុវត្តការងារសំណង់របស់ខ្លួនតាមស្តង់ដារដែលពួកគាត់ចង់បាន និងមិនត្រូវបានចាប់ឲ្យទទួលខុសត្រូវផងដែរ។ ឧទាហរណ៍ ប្រឡាយរងទី៣ត្រូវមានកម្ពស់ស្មើនឹងបាតដីស្រែ ប៉ុន្តែអ្នកម៉ៅការសំណង់បែរជាកសាងជាប្រឡាយជីកមួយទៅវិញ ដូច្នេះទឹកហូរយ៉ាងយឺតដើម្បីស្រោចស្រពវាលស្រែ។

**សេចក្តីសន្និដ្ឋាន:** ក្រោយពេលកែលម្អ ប្រព័ន្ធត្រូវបានបំពាក់ដោយប្រព័ន្ធពេញលេញ: ទ្វារទឹក ប្រព័ន្ធស្ទាក់ទឹក ប្រឡាយរងទី២និងកូនប្រឡាយរងទី៣ និងប្រឡាយរំដោះទឹក។ ការស្តារនីតិសម្បទាប្រព័ន្ធបានលើកកម្ពស់ចំណុះស្តុកទឹករបស់អាង ដោយពង្រីកផ្ទៃដីស្រោចស្រពបានប្រហែល ៤៥០ហិកតា ប៉ុន្តែបានបណ្តាលឲ្យផ្ទៃដី ១៤០ហិកតាជន់លិចដោយការស្តុកទឹករបស់អាង។ ដូច្នេះ ផលចំណេញសុទ្ធនៃដីស្រែស្រោចស្រព គឺប្រហែល ៤០០ ហិកតា ដែលស្មើនឹងប្រហែល ១១៥% នៃសមត្ថភាពស្រោចស្រពមុនពេលស្តារនីតិសម្បទា។

## ប្រព័ន្ធទី ៥: ប្រព័ន្ធធារាសាស្ត្រទានកាំ-បន្ទាត់បោះ [ខេត្តបន្ទាយមានជ័យ]

**ទស្សនៈរួម:** ប្រព័ន្ធនេះស្ថិតនៅក្នុងភូមិបន្ទាត់បោះ ឃុំទានកាំ។ អាងស្តុកទឹកលាតសន្ធឹងលើផ្ទៃដីប្រហែល ៣០០ ហិកតា ដោយមានចំណុះស្តុកទឹកប្រហែល ៥ លានម៉ែត្រគូប។ ប្រព័ន្ធត្រូវបានស្តារនីតិ-

សម្បទាក្នុងឆ្នាំ២០០៩ រួមមានប្រឡាយមេប្រវែង២.៥០០ម៉ែត្រ និងប្រឡាយរំដោះទឹកប្រវែង ៣.៥០០ម៉ែត្រ ដោយមានជំនួយពីសហភាពអឺរ៉ុប តាមរយៈគម្រោង ECOSORN។ ប្រឡាយរងទី៣ប្រវែងប្រហែល ៥.០០០ ម៉ែត្រត្រូវបានសាងសង់ថ្មីដោយគម្រោង។ ប្រព័ន្ធគ្រោងស្រោចស្រពដីស្រែ ២៥០ហិកតាក្នុងរដូវវស្សា បន្ថែមលើទឹកភ្លៀង។ គួរឲ្យកត់សម្គាល់ផងដែរថា ទឹកពីដែនទទួលទឹកភ្លៀងនៃអាងស្តុកទឹក ដែលបានស្តារនីតិសម្បទាត្រូវបានប្រើមិនត្រឹមតែសម្រាប់ស្រោចស្រពដីស្រែ ២៥០ហិកតា នៅក្នុងប្រព័ន្ធប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងស្រោចស្រពស្រែ ២០០ហិកតាផ្សេងទៀតនៅក្នុងភូមិទានកាំទៀតផង។ បទសម្ភាសន៍ជាមួយប្រជាជនមូលដ្ឋានបានបង្ហាញថា ដីស្រែ២០០ហិកតានៅក្នុងភូមិទានកាំនេះបានទទួលអត្ថប្រយោជន៍ពីទឹកធារាសាស្ត្រចេញពីអាងស្តុកទឹក មុនពេលស្តារនីតិសម្បទាទៅទៀត។ ប្រការនេះមានន័យថាកិច្ចប្រឹងប្រែងស្តារនីតិសម្បទា បានកែលម្អការស្តុកទឹកទុកដើម្បីពង្រីកសមត្ថភាពស្រោចស្រព។ ហេតុដូច្នេះ ជាសរុបប្រព័ន្ធផ្តល់ទឹកធារាសាស្ត្រសម្រាប់ដីស្រែប្រហែល ៤៥០ ហិកតា បានន័យថាអាងស្តុកទឹកទំហំ ១ ហិកតាអាចស្រោចស្រពដីស្រែប្រហែល ១,៥ ហិកតា។

**អត្ថប្រយោជន៍ៈ** ការវាយតម្លៃផ្ទាល់នៅមូលដ្ឋានបង្ហាញថា ប្រព័ន្ធធារាសាស្ត្រដែលត្រូវបានស្តារនីតិ-សម្បទាគ្រោងផ្តល់អត្ថប្រយោជន៍ជូនភូមិចំនួន២ នៅក្នុងឃុំទានកាំ ពោលគឺភូមិបន្ទាត់បោះ និងភូមិអ៊្ញ។ ប៉ុន្តែអត្ថប្រយោជន៍មានកម្រិតដូចខាងក្រោមៈ

- ទឹកធារាសាស្ត្របំពេញបន្ថែម
- សមត្ថភាពរំដោះទឹកចេញ
- កំណើនផលស្រូវ
- ការធ្វើដំណើរតាមផ្លូវលើខ្នងប្រឡាយ (កង់និងម៉ូតូ)។

មុនពេលស្តារនីតិសម្បទា ប្រព័ន្ធក៏បានផ្តល់ទឹកធារាសាស្ត្រផងដែរឲ្យដល់ដីស្រែប្រហែល ១៧០ ហិកតា តាមរយៈម៉ាស៊ីនបូមទឹក ដោយសារអាងស្តុកទឹកនៃប្រឡាយគឺទាបជាងបាតវាលស្រែ និងដោយសារកង្វះប្រឡាយស្រោចស្រព។ បន្ទាប់មក កិច្ចប្រឹងប្រែងស្តារនីតិសម្បទាបានកែលម្អប្រឡាយមេមានស្រាប់ឲ្យក្លាយទៅជា គំរូប្រព័ន្ធធារាសាស្ត្រលំហូរតាមទំនាញផែនដីមួយ ដោយការកសាងប្រឡាយរងទី៣ថ្មី។ ការកែលម្អប្រព័ន្ធបានបង្កើនផ្ទៃដីស្រោចស្រពឡើងដល់ ២៥០ហិកតា ដែលមានន័យថាដីស្រែបន្ថែមទំហំ ៨០ ហិកតា ឬដីស្រែប្រហែល៤៥% ថែមទៀត បានទទួលអត្ថប្រយោជន៍ពីទឹកធារាសាស្ត្រ។ ការមានប្រឡាយរំដោះទឹកក៏អនុញ្ញាតឲ្យកសិករបង្ហូរទឹកលើសចេញពីស្រែរបស់ខ្លួនផងដែរប្រសិនបើចាំបាច់។ ចម្លើយពីគណៈកម្មាធិការ FWUC និងភាគីពាក់ព័ន្ធផ្សេងទៀតនៅកម្រិតសហគមន៍ បង្ហាញថាផលស្រូវក្នុងរដូវវស្សានៅពេលនេះ គឺប្រហែល ១,៨តោនក្នុងមួយហិកតា ប្រៀបធៀបទៅនឹងប្រហែល ១,៥តោនក្នុងមួយហិកតា មុនពេលស្តារនីតិសម្បទា ដែលបង្ហាញពីកំណើន២០% ជាលទ្ធផលនៃទឹកធារាសាស្ត្រ និងកត្តាផ្សេងទៀត។

ប្រជាជនមូលដ្ឋានបានពន្យល់ថែមទៀតថាប្រព័ន្ធធារាសាស្ត្រ មានប្រយោជន៍តែសម្រាប់បំពេញបន្ថែមលើទឹកភ្លៀងប៉ុណ្ណោះ ជាពិសេស នៅដើមរដូវវស្សា។ សមត្ថភាពធ្វើអន្តរាគមន៍ពេលមានគ្រោះរាំងស្ងួតទំនងជាធ្វើមិនបានទេ ដោយសារនៅពេលមានគ្រោះរាំងស្ងួត ទឹកស្តុកទុកនៅក្នុងអាងក៏ទាបដែរ ដែលជាហេតុមិនអាចបង្វែរទឹកទៅស្រោចស្រពស្រែនៅក្នុងប្រព័ន្ធដែលមានសណ្ឋានដីខ្ពស់ជាងទេ។

គួរឲ្យកត់សម្គាល់ផងដែរថា អត្ថប្រយោជន៍នៃប្រព័ន្ធធារាសាស្ត្រភាគច្រើនគឺបានទៅលើអ្នកមានដែលជាម្ចាស់កម្មសិទ្ធិដីស្រែភាគច្រើន។ ការវាយតម្លៃផ្ទាល់បានបង្ហាញថាដីស្រែជិត ២០០ ហិកតា ឬ ប្រហែល ៧០% ស្ថិតក្នុងទំហំស្រោចស្រពនៃប្រព័ន្ធ គឺជាកម្មសិទ្ធិរបស់គ្រួសារស្តុកស្តម្ភចំនួនប្រហែល១០ ដែលរស់នៅក្រៅភូមិ និងនៅទីរួមស្រុក រួមទាំងអតីតអភិបាលស្រុកមួយរូប និងអ្នកជំនួញផ្សេងទៀត។ អ្នកខ្លះក្នុងចំណោមអ្នកទាំងនេះ មានដីរហូតដល់ ២០-៣០ ហិកតាក្នុងមួយនាក់ៗ។ ដីស្រែនៅសល់ចំនួន ៧០-៨០ ហិកតាត្រូវបានចែកគ្នាដោយគ្រួសារប្រហែល ១២៥ ដែលជាអ្នកមានលំនៅដ្ឋាននៅក្នុងភូមិបន្ទាត់បោះ និងភូមិអ៊ូ។

ទោះបីជាមានផលចំណេញពីដីស្រែស្រោចស្រព ៨០ហិកតា ដែលអត្ថប្រយោជន៍ភាគច្រើនបានទៅអ្នកមាន ការកែលម្អប្រព័ន្ធមានឥទ្ធិពលអវិជ្ជមានលើដីស្រែ ៨០ហិកតា ផ្សេងទៀត។ ដោយសារសណ្ឋានដីខ្ពស់នៃប្រព័ន្ធ ការទប់ទឹកឲ្យបានឡើងដល់កម្រិតមួយដើម្បីឲ្យវាអាចស្រោចស្រពបាន គឺជាកិច្ចការមួយចាំបាច់។ ដោយសារមូលហេតុនេះ ដីស្រែប្រហែល ២០ ហិកតាត្រូវបានទឹកជន់លិច ខណៈដែលដីស្រែ ៦០ ហិកតាផ្សេងទៀតលែងបានទទួលទឹកស្រោចស្រពពីអាងស្តុកទឹក និងបានក្លាយទៅជាពឹងលើទឹកភ្លៀង។

ចំពោះការមានផ្លូវប្រើ ប្រជាជនចាត់ទុកថាវា គឺជាគុណសម្បត្តិផងនិងជាគុណវិបត្តិផង។ អ្វីដែលល្អគឺថាប្រជាជនអាចជិះកង់ និងម៉ូតូលើផ្លូវជាប់ប្រឡាយ។ ប៉ុន្តែ ប្រជាជនបានត្អូញត្អែរថាការដឹកជញ្ជូនទិន្នផលកសិកម្មរបស់ពួកគាត់តាមរទេះគោ និងតាមមធ្យោបាយផ្សេងទៀតបានក្លាយទៅជាកាន់តែពិបាកឡើងដោយសារពុំមានការផ្តល់ស្ពាន ឬលូទឹកដើម្បីឆ្លងកាត់ប្រឡាយរងទី៣ដែលទើបកសាងហើយ។

**ការថែទាំៈ** FWUC ត្រូវបានបង្កើតឡើងក្រោយពេលកែលម្អប្រព័ន្ធ ជាមួយភារកិច្ចធានាឲ្យបាននូវកិច្ចប្រតិបត្តិការ ការគ្រប់គ្រង និងការថែទាំប្រព័ន្ធ។ មានកសិករចំនួន ១២៥ នាក់ដែលជាសមាជិករបស់FWUC ហើយកសិករចំនួន ១៦ នាក់គឺជាសមាជិកនៃគណៈកម្មាធិការ FWUC ដែលនៅក្នុងនោះ ពុំមានស្ត្រីទេ។ យោងតាមគណៈកម្មាធិការ FWUC ប្រហែល ៣០% នៃដីស្រែនៅក្នុងប្រព័ន្ធត្រូវការការស្រោចស្រពបន្ថែមដោយម៉ាស៊ីនបូមទឹក។ ដោយសារមូលហេតុនេះ ថ្លៃទឹកត្រូវបានយកខុសគ្នាៈ ៥.០០០ រៀលក្នុងមួយហិកតាសម្រាប់ស្រែនៅក្នុងប្រព័ន្ធ ដែលត្រូវបានស្រោចស្រពដោយលំហូរតាមទំនាញផែនដី ៣.០០០ រៀលក្នុងមួយហិកតាសម្រាប់ស្រែនៅក្នុងប្រព័ន្ធ ដែលត្រូវបានស្រោចស្រពដោយម៉ាស៊ីនបូមទឹក និង ១០.០០០ រៀលក្នុងមួយហិកតាសម្រាប់ស្រែនៅក្រៅប្រព័ន្ធ ដែលអាចស្រោចស្រពបានតែតាមរយៈការប្រើម៉ាស៊ីនបូមទឹកប៉ុណ្ណោះ។

គណៈកម្មាធិការ FWUC បានទទួលស្គាល់ថាការប្រមូលថ្លៃទឹកមិនបានទទួលជោគជ័យទេ។ ការមានទឹកធារាសាស្ត្រគឺមិនបានគ្រប់គ្រាន់សូម្បីតែសម្រាប់ស្រែនៅក្នុងប្រព័ន្ធផង ដូច្នេះមិនដែលបានទៅដល់អ្នកនៅក្រៅប្រព័ន្ធទេ។ ដោយសារអាងស្តុកទឹកភាគច្រើនស្តុកទឹកភ្លៀងយ៉ាងច្រើន វាអាចស្រោចស្រពដីស្រែនានាបន្ថែមលើទឹកភ្លៀង។ ក្នុងពេលមានគ្រោះរាំងស្ងួត អាងស្តុកទឹកខ្វះទឹក ដែលជាហេតុធ្វើឲ្យសមត្ថភាពស្រោចស្រពមានកម្រិត។ ហេតុដូច្នេះ FWUC មិនហ៊ានប្រមូលថ្លៃទឹកពីសមាជិកខ្លួនឡើយ។ ប្រធានគណៈកម្មាធិការ FWUC បានរាយការណ៍ថាថ្លៃទឹកត្រូវបានប្រមូលពីសមាជិកខ្លះកាលពីឆ្នាំមុន ប៉ុន្តែការផ្គត់ផ្គង់ទឹកធារាសាស្ត្រគឺមិនគ្រប់ ដូច្នេះ FWUCបានបង្វិលថ្លៃទឹកទៅឲ្យអ្នកបង់វិញ។ ដោយសារចំណុចទាំងអស់នេះ គណៈកម្មាធិការ FWUCបានយល់ឃើញថា អត្ថិភាពនិងកិច្ចដំណើរការនៃ FWUCទំនងជានឹងបរាជ័យ។

**ជោគជ័យ និង គុណវិបត្តិ:** អាជ្ញាធរមូលដ្ឋាន និង ប្រជាជនក្នុងសហគមន៍មិនចាត់ទុកការកែលម្អប្រព័ន្ធថាបានទទួលជោគជ័យទេ។ នៅពេលដែលត្រូវបានស្នើឲ្យវាយតម្លៃកម្រិតជោគជ័យនៃប្រព័ន្ធ ពួកគាត់បាននិយាយថាជោគជ័យប្រហែលមាន ៤០% ដែលភាគច្រើនត្រូវបានផ្សារភ្ជាប់ទៅនឹងប្រឡាយនិង ប្រព័ន្ធរំដោះទឹកដែលបានកែលម្អ ខណៈដែលទឹកធារាសាស្ត្រភាគច្រើនផ្តល់អត្ថប្រយោជន៍ឲ្យដល់អ្នកមាន ដែលមិនដែលបានបង់ថ្លៃទឹកឲ្យFWUC។ គុណវិបត្តិផ្សេងទៀត រួមមានៈ ១) ប្រព័ន្ធកែលម្អនេះធ្វើឲ្យការដឹកជញ្ជូនទិន្នផលកសិកម្មកាន់តែពិបាកឡើងដោយសារមិនមានស្ពាន/លូសម្រាប់ឆ្លងកាត់ប្រឡាយ និង ២) កង្វះទឹកធារាសាស្ត្រនៅក្នុងអាងស្តុកទឹក ដោយសារការទ្រុឌទ្រោមនៃប្រឡាយក្នុងការបង្វែរទឹកពីអាងស្តុកទឹកត្រពាំងថ្មទៅក្នុងអាងស្តុកទឹកទានកាំ-បន្ទាត់បោះ។

**សេចក្តីសន្និដ្ឋានៈ** ជារួម ការស្តារនីតិសម្បទាប្រព័ន្ធបានទទួលជោគជ័យលើការកែលម្អប្រព័ន្ធធារាសាស្ត្រ រួមមានការកសាងប្រឡាយរងទី៣ថ្មី ការកែលម្អប្រឡាយមេទៅជាគំរូប្រើលំហូរតាមទំនាញផែនដី និងការផ្តល់ប្រឡាយរំដោះទឹក។ ប៉ុន្តែ ការស្តារនីតិសម្បទាមិនប្រាកដជាបានកែលម្អផ្ទៃដីស្រោចស្រពទាំងអស់នោះទេ ពោលគឺកំណើនផ្ទៃដីស្រោចស្រពនៅក្នុងប្រព័ន្ធត្រូវបានកាត់កងដោយប្រការដែលថាផ្ទៃដីស្រែខ្លះត្រូវបានទឹកជន់លិច ហើយដីស្រែខ្លះទៀតលែងបានទទួលទឹកពីប្រព័ន្ធកែលម្អ។ ម្យ៉ាងទៀត ស្រែទទួលអត្ថប្រយោជន៍ភាគច្រើន គឺជាកម្មសិទ្ធិរបស់អ្នកមានមួយចំនួនតូចដែលរស់នៅក្នុងទីរួមស្រុក ជាជាងកសិករតូចតាចនៅក្នុងភូមិ។ លើសពីនេះទៀត សមត្ថភាពស្រោចស្រពរបស់ប្រព័ន្ធគឺមានត្រឹមតែទឹកស្តុកទុកក្នុងអាង ខណៈដែលអាងស្តុកទឹកខ្លួនឯងពឹងផ្អែកយ៉ាងច្រើនលើទឹកភ្លៀង។ ហេតុដូច្នេះ ប្រព័ន្ធធារាសាស្ត្រអាចដំណើរការបានបន្ថែមលើទឹកភ្លៀង ពោលគឺមិនមែនសម្រាប់ធ្វើអន្តរាគមន៍ពេលមានគ្រោះរាំងស្ងួតឡើយ។

## ប្រព័ន្ធទី ៦: ប្រព័ន្ធធារាសាស្ត្រទំនប់រំដេង [ខេត្តសៀមរាប]

**ទស្សនៈរួមៈ** ប្រព័ន្ធនេះស្ថិតនៅក្នុងឃុំពោធិ៍ខ្នារ ស្រុកសូទ្រនិគម ខេត្តសៀមរាប។ ដោយមានជំនួយពីសហភាពអឺរ៉ុបតាមរយៈគម្រោងECOSORN ប្រព័ន្ធត្រូវបានស្តារក្នុងឆ្នាំ២០០៩។ ការស្តារនីតិសម្បទាបានកែលម្អប្រឡាយមេប្រវែងជាង ១.៦០០ ម៉ែត្រ។ ប្រឡាយរងទី៣ប្រវែងប្រហែល ២.០០០ ម៉ែត្រត្រូវបានកសាងថ្មីដោយគម្រោង (ប្រវែងប្រហែល១២០ម៉ែត្រ មិនត្រូវបានកសាងនោះទេ ដោយសារម្ចាស់ដីរងផលប៉ះពាល់មិនព្រមបរិច្ចាគដីរបស់ខ្លួន)។ ការស្តារនីតិសម្បទាក៏បានកែលម្អទ្វារទឹកនៃក្បាលហុងទឹកផងដែរ ដើម្បីយកទឹកពីភ្នំគូលេន តាមរយៈការដំឡើងប្រព័ន្ធបំពង់រំដោះទឹកមួយ និងបានសាងសង់សំណង់ស្ទាក់ទឹកសម្រាប់ចែកចាយទឹកស្រោចស្រពនៅក្នុងប្រព័ន្ធ។ ប្រព័ន្ធនេះ គឺប្រើលំហូរតាមទំនាញផែនដី និងគ្រោងស្រោចស្រពដីស្រែទំហំ ៣៦២ ហិកតានៅក្នុងប្រព័ន្ធ។

**អត្ថប្រយោជន៍ៈ** ការវាយតម្លៃផ្ទាល់បង្ហាញថាការស្តារនីតិសម្បទាប្រព័ន្ធផ្តល់គុណសម្បត្តិ និងគុណវិបត្តិដូចខាងក្រោមៈ

- ទឹកធារាសាស្ត្របំពេញបន្ថែម
- ការផលិតដំណាំបន្ថែមខ្លះក្នុងរដូវប្រាំង
- អន្តរាគមន៍ពេលមានគ្រោះរាំងស្ងួត

- អត្ថប្រយោជន៍សាយភាយដល់ប្រព័ន្ធនៅខាងក្រៅ
- ផលស្រូវល្អ
- ផលិតកម្មបន្លែ
- ការធ្វើដំណើរតាមផ្លូវលើខ្នងប្រឡាយ (កង់ និងម៉ូតូ)
- អត្ថប្រយោជន៍ផ្សេងទៀត (ត្រី ទឹកប្រើប្រាស់សម្រាប់សត្វនិងគ្រួសារ)។

មុនពេលស្តារនីតិសម្បទា មានសេចក្តីរាយការណ៍ថាប្រព័ន្ធអាចស្រោចស្រពស្រែប្រហែល ១៥០ ហិកតានៅក្នុងប្រព័ន្ធ។ កិច្ចប្រឹងប្រែងកែលម្អប្រព័ន្ធបានបង្កើនសមត្ថភាពធារាសាស្ត្រឲ្យស្រោចស្រពដីស្រែទាំង ៣៦២ ហិកតារបស់គ្រួសារកសិករចំនួន ៣៣០ នៅក្នុងភូមិចំនួន ៤[22] ដែលតំណាងឲ្យកំណើនដីស្រែ ២១២ ហិកតា ឬ ១៤០%។ ផលស្រូវក្នុងរដូវវស្សាត្រូវបានរាយការណ៍ថាបានកើនឡើងពី ១,៨ តោនក្នុងមួយហិកតាដល់ ២,៣ តោនក្នុងមួយហិកតា ដែលបង្ហាញពីកំណើនប្រហែល ៣០% ជាលទ្ធផលនៃទឹកធារាសាស្ត្រ និងកត្តារួមចំណែកផ្សេងទៀត។ ការកែលម្អប្រព័ន្ធបានជម្រុញឲ្យកសិករដាំដំណាំលើកទីពីរក្នុងរដូវប្រាំង។ ប៉ុន្តែ ដោយសារទឹកមានកម្រិតក្នុងរដូវប្រាំង មានតែដីស្រែប្រហែល ២០ ហិកតាប៉ុណ្ណោះដែលត្រូវបានធ្វើស្រែ ជាមួយផលជាមធ្យម ២,១ តោនក្នុងមួយហិកតា។

ប្រព័ន្ធមិនមានប្រឡាយរំដោះទឹកទេ ប៉ុន្តែកសិករមិនមានបញ្ហាក្នុងការបង្ហូរទឹកជំនន់ ឬទឹកលើសពីដីស្រែរបស់ខ្លួននៅពេលចាំបាច់ឡើយ ដោយសារដីស្រែគឺស្ថិតនៅលើសណ្ឋានដីទីជម្រាល។ ចំពោះអន្តរាគមន៍ពេលមានគ្រោះរាំងស្ងួត ប្រជាជនបានប៉ាន់ស្មានថាប្រព័ន្ធនឹងអាចបម្រើដល់ដីស្រែនៅក្នុងប្រព័ន្ធ ដោយទទួលបានទឹកមកពីស្ទឹង ប្រសិនបើមានគ្រោះរាំងស្ងួត។ ប៉ុន្តែ មិនមានគ្រោះរាំងស្ងួតទេចាប់តាំងពីឆ្នាំ២០០៦ មក។

ប្រព័ន្ធផ្គត់ផ្គង់ទឹកធារាសាស្ត្រដើម្បីផ្តល់អត្ថប្រយោជន៍ដីស្រែវស្សាប្រហែល ៣៧០ ហិកតានៅក្នុងភូមិចំនួន ៥[23] នៃឃុំចាន់ស។ ប្រធានឃុំចាន់សបានមានប្រសាសន៍ថា "បើគ្មានការស្តារនីតិសម្បទាទេ កសិករនៅក្នុងឃុំនេះមុខជាមិនបានទទួលអត្ថប្រយោជន៍ពីទឹកស្រោចស្រពឡើយ" ។

ការមានទឹកធារាសាស្ត្រ បានអនុញ្ញាតឲ្យកសិករអាចដាំបន្លែថែមទៀត។ នៅក្នុងចំណោមភូមិទាំង៤ នៅក្នុងប្រព័ន្ធ ចំនួនគ្រួសារដែលចូលរួមក្នុងការផលិតបន្លែត្រូវបានរាយការណ៍ថា បានកើនឡើងពីប្រហែល ២៥ ដល់ ៩៥។ ទឹកស្រោចស្រពក៏បានបង្កើនចំនួនគ្រួសារដែលដាំបន្លែនៅក្រៅប្រព័ន្ធ(ឃុំចាន់ស) កើនឡើងពីចំនួនប្រហែល ១៥គ្រួសារ ដល់ ៤០គ្រួសារ។ សំខាន់ជាងនេះទៅទៀត ទឹកស្រោចស្រពមិនត្រឹមតែលើកទឹកចិត្តឲ្យគ្រួសារកាន់តែច្រើនឡើងដាំបន្លែប៉ុណ្ណោះទេ ប៉ុន្តែក៏បានអនុញ្ញាតឲ្យកសិករពង្រីកទំហំកសិដ្ឋានរបស់ខ្លួន និងដាំដំណាំកាន់តែច្រើនក្នុងមួយឆ្នាំថែមទៀតផង។

**ការថែទាំ:** ក្រោយពេលកែលម្អប្រព័ន្ធ គ្រួសារកសិករចំនួន ៣៣០ ដែលមានដីស្រែនៅក្នុងប្រព័ន្ធ ត្រូវបានបង្កើតទៅជា FWUC មួយ។ គណៈកម្មាធិការ FWUC រួមមានសមាជិក ៤ នាក់ (ប្រធាន ១រូប អនុប្រធាន ២រូប និង គណនេយ្យករ/បេឡា ១រូប)។ ប្រព័ន្ធត្រូវបានចែកចេញជា៤ប្លុក ហើយសមាជិកផ្សេងទៀត

[22] ភូមិរំដេង ភូមិបុស្ស ភូមិជប់ ភូមិដំរីឆ្លាំង។

[23] ភូមិចាន់សជើង ភូមិចាន់សត្បូង ភូមិថ្នល់ ភូមិសន្លោង និងភូមិដូនជៀវ។

របស់FWUC ត្រូវបានតែងតាំងឲ្យធ្វើជាប្រធាន និងអនុប្រធានប្លុក។ FWUCត្រូវបានប្រគល់ភារកិច្ចឲ្យទទួលខុសត្រូវរួមលើ កិច្ចប្រតិបត្តិការ ការគ្រប់គ្រង និងការថែទាំប្រព័ន្ធ ខណៈដែលសមាជិកFWUCមានកាតព្វកិច្ចត្រូវបង់ថ្លៃសម្រាប់ការប្រើទឹកធារាសាស្ត្រ តាមអត្រាកំណត់ស្រូវ ៣០ គីឡូក្រាម សម្រាប់ស្រែវស្សាមួយហិកតា។ ថ្លៃទឹកមិនត្រូវបានយកពីកសិករដែលដាំដំណាំបន្ថែមក្នុងរដូវប្រាំងទេ ដោយសារបរិមាណទឹកមានកម្រិត។ យោងតាមFWUC កសិករនៅក្នុងប្រព័ន្ធបានបង់ថ្លៃទឹករបស់ពួកគាត់។ ប៉ុន្តែ បញ្ហាប្រឈមគឺថាជាធម្មតាពួកគាត់បង់តិចជាងអ្វីដែលពួកគាត់ត្រូវបង់ ហើយអ្នកខ្លះមិនបង់តែម្តង។

**ជោគជ័យ និង គុណវិបត្តិ:** អាជ្ញាធរមូលដ្ឋាន និង កសិករទទួលផលវាយតម្លៃខ្ពស់ចំពោះកិច្ចប្រឹងប្រែងកែលម្អប្រព័ន្ធធារាសាស្ត្រ។ ប្រព័ន្ធត្រូវបានវាយតម្លៃថាទទួលជោគជ័យ ១០០% ដោយសារវាបានផ្តល់អត្ថប្រយោជន៍ច្រើន។ ស្រែទាំងអស់នៅក្នុងប្រព័ន្ធអាចត្រូវបានស្រោចស្រពដោយលំហូរតាមទំនាញផែនដីនៃទឹកធារាសាស្ត្រពីប្រព័ន្ធ ហើយកសិករបានបង់ថ្លៃទឹករបស់ខ្លួន។ ទោះបីជាមានជោគជ័យបែបបនេះក្តី ក៏មានការលើកឡើងពីគុណវិបត្តិដែរ ឧទាហរណ៍ ប្រព័ន្ធខ្វះសំណង់ស្ទាក់ទឹកនៅតាមទីកន្លែងចំនួន ៤។ ម្យ៉ាងទៀត ប្រឡាយរងទី៣ប្រវែងប្រហែល ១២០ម៉ែត្រមិនត្រូវបានកសាង ប៉ុន្តែគឺដោយសារកសិករមិនព្រមបរិច្ចាគដីរងផលប៉ះពាល់របស់ខ្លួន។

**សេចក្តីសន្និដ្ឋាន:** ការកែលម្អប្រព័ន្ធធារាសាស្ត្រទំនប់រំដេង បានរួមចំណែកជាអត្ថប្រយោជន៍ច្រើនជូនដល់កសិករទាំងនៅក្នុង និងនៅក្រៅប្រព័ន្ធ។ កសិករមានទឹកធារាសាស្ត្រប្រើពេញលេញ ដោយសារលំហូរតាមទំនាញផែនដី ដូច្នេះពួកគាត់មានអារម្មណ៍ទុកចិត្តអំពីការធ្វើស្រែរបស់ពួកគាត់ សូម្បីតែនៅពេលមានភ្លៀងតិចតួច ឬមានគ្រោះរាំងស្ងួតក្តី។ ជាទូទៅ កសិករសង្កេតឃើញផលស្រូវរបស់ខ្លួនមានការកើនឡើង។ បរិមាណទឹកធារាសាស្ត្រពីប្រព័ន្ធកែលម្អនេះ ក៏បានលើកទឹកចិត្តឲ្យកសិករកាន់តែច្រើនដាំបន្លែផងដែរ។ FWUC ដែលទទួលបន្ទុកលើការថែទាំប្រព័ន្ធ បាននិងកំពុងដំណើរការ។ ជាទូទៅ សមាជិកបានបង់ថ្លៃទឹក ថ្វីបើក្នុងករណីខ្លះ មិនបានគ្រប់ចំនួនក្តី។

## ប្រព័ន្ធទី ៧: ប្រព័ន្ធធារាសាស្ត្រសាមសិបកញ្ញា (ខេត្តកំពង់ធំ)

**ទស្សនៈរួម:** អាងស្តុកទឹកសាមសិបកញ្ញា ត្រូវបានស្តារនីតិសម្បទាដោយក្រសួងធនធានទឹក និងឧតុនិយម ក្នុងឆ្នាំ២០០៨ ជាមួយប្រភពទឹកចម្បងពីស្ទឹងស្ទោង។ អាងស្តុកទឹកស្ថិតនៅក្នុងស្រុកចំនួនបី (ស្ទោង កំពង់ស្វាយ និង បល្ល័ង្ក) នៃខេត្តកំពង់ធំ។ យោងតាមមន្ទីរធនធានទឹកនិងឧតុនិយមខេត្ត អាងនេះកំពុងស្តុកទឹកប្រហែល ១៩ លានម៉ែត្រគូប ដែលស្មើនឹងប្រហែល ៣៥% នៃផែនការ។ មានការពន្យល់ថាប្រសិនបើការស្តុកទឹកកើនឡើង នោះផ្ទៃដីលំនៅដ្ឋាន និងដីស្រែកាន់តែច្រើននឹងត្រូវទឹកជន់លិច។ មន្ទីរធនធានទឹក និងឧតុនិយមខេត្ត បានពន្យល់ថែមទៀតថាមូលនិធិរបស់រាជរដ្ឋាភិបាល អាចស្តារនីតិសម្បទាបានតែប្រឡាយមេជាដំណាក់ៗប៉ុណ្ណោះ។ ចំណុចនេះ គឺដោយសារ: ១) ការបញ្ចេញមូលនិធិពីរាជរដ្ឋាភិបាលជាតិ គឺមានកម្រិត និង ២) ប្រព័ន្ធនេះគឺខ្នាតធំ ដែលតម្រូវឲ្យមានមូលនិធិធំ។ ក្នុងបណ្តាឆ្នាំកន្លងមក សំណង់ស្ទាក់ទឹកចំនួន១៥ និងប្រឡាយមេចំនួន៣ ប្រវែងសរុបប្រហែល៤៤គីឡូម៉ែត្រត្រូវបានស្តារនីតិសម្បទា។

**អត្ថប្រយោជន៍:** ផ្អែកលើបទសម្ភាសន៍ជាមួយមន្ទីរធនធានទឹកនិងឧតុនិយមខេត្ត ផ្ទៃដីគ្រោងស្រោចស្រពនៃប្រព័ន្ធ ត្រូវបានរាយការណ៍ថាមានទំហំប្រហែល ១២.០០០ ហិកតា និងគ្រោងផ្តល់អត្ថប្រយោជន៍ជូនកសិករនៅក្នុងឃុំចំនួន១៧[24] នៅក្នុងស្រុកចំនួន៣។ ប៉ុន្តែ ដោយសារការស្តារនីតិសម្បទា ប្រព័ន្ធនៅមិនទាន់បានបញ្ចប់ និងដោយសារកង្វះការប្រមូលទិន្នន័យ មន្ទីរធនធានទឹកនិងឧតុនិយមខេត្តមិនអាចរាយការណ៍អំពីផ្ទៃដីស្រោចស្រពជាក់ស្តែង នៃប្រព័ន្ធនៅក្នុងដំណាក់កាលបច្ចុប្បន្នបានទេ។ ដើម្បីស្វែងយល់បន្ថែមអំពីអត្ថប្រយោជន៍របស់ប្រព័ន្ធ ក្រុមសិក្សាបានចុះសិក្សាឃុំចំនួនបួន (២ក្នុងស្រុកកំពង់ស្វាយ[25] និង២ក្នុងស្រុកស្ទោង[26]) ដែលត្រូវបានឆ្លងកាត់ដោយប្រឡាយមេ និងត្រូវបានផ្តល់អនុសាសន៍ដោយមន្ទីរធនធានទឹកនិងឧតុនិយមខេត្ត។

**ឃុំដំរីស្លាប់ (ស្រុកកំពង់ស្វាយ)**: ឃុំនេះនៅជាប់អាងស្តុកទឹក។ ដីស្រែសរុបនៅក្នុងឃុំ[27] មានទំហំ ៨.៧៦០ ហិកតា។ ប្រឡាយមេប្រវែងប្រហែល ១២ គីឡូម៉ែត្រឆ្លងកាត់ឃុំ រួមទាំងប្រឡាយរងទី២ប្រវែងប្រហែល ២ គីឡូម៉ែត្រ។ នៅតាមដងប្រឡាយ មានសំណង់ស្ទាក់ទឹកចំនួន ៥[28] ។ ប្រឡាយទាំងនេះជាសរុបអាចស្រោចស្រពដីស្រែប្រហែល ៦៨០ ហិកតាបន្ថែមលើទឹកភ្លៀង។ យោងតាមក្រុមប្រឹក្សាឃុំ ប្រឡាយរងទី២អាចស្រោចស្រពដីស្រែប្រហែល ២០០ ហិកតា ខណៈដែលប្រឡាយមេផ្តល់ទឹកធារាសាស្ត្រ ឲ្យដីស្រែប្រហែល ៤៨០ ហិកតានៅតាមសងខាងប្រឡាយ។ ក្រុមប្រឹក្សាឃុំបញ្ជាក់ថា ជាធម្មតា ទឹកស្រោចស្រពមិនអាចទៅដល់ស្រែដែលស្ថិតនៅឆ្ងាយជាង ២០០ ម៉ែត្រពីប្រឡាយមេនោះទេ។ ការមានទឹកធារាសាស្ត្រពីប្រព័ន្ធក៏បានអនុញ្ញាតឲ្យគេដាំដំណាំបន្ថែមក្នុងរដូវប្រាំង ដែលអាចធ្វើបានលើដីប្រហែល ២០០ ហិកតានៅតាមដងប្រឡាយមេ។ ចំពោះផល ក្រុមប្រឹក្សាឃុំបានកត់សម្គាល់ឃើញការកែលម្អ ប្រសិនបើប្រៀបធៀបទៅនឹងមុនពេលស្តារនីតិសម្បទា។ នៅតាមកន្លែងដែលមានទឹកធារាសាស្ត្រប្រើ ផលស្រូវកើនឡើងពីប្រហែល ១,៧ តោនក្នុងមួយហិកតាដល់ប្រហែល ៣ តោនក្នុងមួយហិកតា។ ចំពោះមធ្យោបាយស្រោចស្រពស្រូវ ការមានសំណង់ស្ទាក់ទឹកអនុញ្ញាតឲ្យ ៨០% នៃដីស្រែអាចស្រោចស្រពបានដោយលំហូរតាមទំនាញផែនដី ខណៈដែល ២០%ផ្សេងទៀតត្រូវការម៉ាស៊ីនបូមទឹក។ ក្រុមប្រឹក្សាឃុំបានបន្ថែមថា ប្រសិនបើមានប្រឡាយរងទី៣បន្ថែម ដីស្រែច្រើនថែមទៀតមុខជាបានទទួលអត្ថប្រយោជន៍ពីគម្រោង។

**ឃុំសាន់គ (ស្រុកកំពង់ស្វាយ)**: ឃុំនេះលាតសន្ធឹងពីឃុំដំរីស្លាប់។ ប្រវែងនៃប្រឡាយដែលឆ្លងកាត់ឃុំសាន់គ គឺប្រហែល ១០ គីឡូម៉ែត្រ និងផ្តល់ទឹកធារាសាស្ត្រឲ្យដីស្រែប្រហែល ១.២០០ ហិកតា នៅសងខាងប្រឡាយ ដែលស្មើនឹងប្រហែល ១៨% នៃផ្ទៃដីស្រែវស្សាសរុបនៅក្នុងឃុំ។ ក្នុងរដូវប្រាំង កសិករដាំដំណាំលើកទីពីរលើដីស្រែប្រហែល ២៥០ ហិកតានៃដីស្រែទាំងនេះ។ ក្រុមប្រឹក្សាឃុំ បានសង្កេតឃើញការផ្លាស់ប្តូរនៅក្នុងផលស្រូវ ក្រោយពេលស្តារនីតិសម្បទាប្រព័ន្ធ។ ផលត្រូវបានរាយការណ៍ ថាបានកើនឡើងពីប្រហែល

---

[24] **ស្រុកស្ទោង:** រុងរឿង បន្ទាយស្ទោង ទ្រា កំពង់ចិនជើង កំពង់ចិនត្បូង ព្រះដំរី ចំណាលើ ចំណាក្រោម ម្សាក្រង និង សំព្រោច។ **ស្រុកកំពង់ស្វាយ:** ដំរីស្លាប់ សាន់គ និង ត្បែង។ **ស្រុកបល្ល័ង្ក:** ដូង សាមគ្គី ផាន់ញើម និង ក្រយា។

[25] ឃុំដំរីស្លាប់ និង ឃុំសាន់គ។

[26] ឃុំព្រះដំរី និង ឃុំរុងរឿង។

[27] ដីនេះស្ថិតនៅក្នុងដែនដីរដ្ឋបាលរបស់ឃុំ ប៉ុន្តែដីភាគច្រើនគឺជាកម្មសិទ្ធិរបស់ប្រជាជននៅក្នុងឃុំផ្សេងជិតខាង។

[28] ៣ ត្រូវបានសាងសង់ដោយក្រុមវិស្វកម្មកងទ័ព ១ ដោយមូលនិធិបដិភាគរបស់ប្រជាជន និង ១ ដោយមន្ទីរធនធានទឹកនិងឧតុនិយមខេត្ត។

១,៥ តោនក្នុងមួយហិកតាដល់ប្រហែល ២,២ តោនក្នុងមួយហិកតាជាមធ្យម ដែលបង្ហាញពីកំណើនប្រហែល ៤៥%។ អត្ថប្រយោជន៍នៃទឹកធារាសាស្ត្របានពង្រីកបន្ថែមដើម្បីធ្វើឲ្យការធ្វើស្រែអាចធ្វើទៅបានក្នុងរដូវប្រាំង លើដីស្រែប្រហែល ២.៧០០ ហិកតានៅក្នុងវាលរាបនេះ ដែលត្រូវទឹកជន់លិចក្នុងរដូវវស្សា និងដែលត្រូវបាន ទុកចោលក្នុងអតីតកាល។ ដីទាំងនេះផ្តល់ផលស្រូវប្រហែល ៤,៥តោនក្នុងមួយហិកតាជាមធ្យម។ ក្រុមប្រឹក្សា ឃុំបានរាយការណ៍ថាដីស្រែទាំងនេះភាគច្រើនទទួលទឹកធារាសាស្ត្រ ដោយលំហូរតាមទំនាញផែនដី។ ទោះបីជាមានអត្ថប្រយោជន៍ទាំងអស់នេះក្តី ក៏ក្រុមប្រឹក្សាឃុំបានរាយការណ៍ផងដែរអំពីបញ្ហាប្រឈមមួយ ចំនួន ដែលរួមមាន: ១) ខ្វះសំណង់ស្នាក់ទឹក (សំណង់ស្នាក់ទឹក៣ ត្រូវបានសាងសង់ក្នុងពេលស្តារនីតិ សម្បទា ប៉ុន្តែត្រូវបានកម្ទេចចោលដោយសារវាមានលក្ខណៈខុសបច្ចេកទេស) ២) កសិករមានការលំបាកក្នុង ការទទួលបានទឹក ដែលជាហេតុធ្វើឲ្យពួកគាត់ដណ្តើមគ្នាដោយសារកង្វះប្រឡាយរង។

**ឃុំព្រះដំរី (ស្រុកស្ទោង)**: ឃុំនេះស្ថិតនៅជិតអាងស្តុកទឹក និងមានភូមិចំនួន៩ ដែលរួមមាន ១.៥០៩ គ្រួសារ។ ដីស្រែសរុបរបស់ឃុំ គឺ ១.៦៤១ ហិកតាដែលដីស្រែទាំងអស់នេះ គឺសុទ្ធតែជាដីស្រែវស្សា។ ក្រុមប្រឹក្សាឃុំបានពន្យល់ថា ឃុំបានប្រើមូលនិធិឃុំ/សង្កាត់ និងមូលនិធិគ្រប់គ្រងធនធានធម្មជាតិរបស់អង្គការ Danidaក្នុងបណ្តាឆ្នាំកន្លងមក ដើម្បីស្តារនីតិសម្បទាប្រឡាយរងទី៣នៅក្នុងឃុំ ក្នុងការពង្រីកទឹកធារាសាស្ត្រ ពីប្រឡាយមេទៅក្នុងស្រែ។ ជាសរុប ប្រឡាយរងទី៣ប្រវែងប្រហែល៣.៣០០ម៉ែត្រ ត្រូវបានស្តារនីតិសម្បទា។ ជាលទ្ធផល ដីស្រែប្រហែល១.១០០ហិកតា អាចត្រូវបានស្រោចស្រពដោយទឹកធារាសាស្ត្រពីអាងស្តុក ទឹកសាមសិបកញ្ញាបន្ថែមលើទឹកភ្លៀងក្នុងរដូវវស្សា ហើយដីស្រែប្រហែល ៣៤០ហិកតាគឺមានសម្រាប់ការដាំ ដំណាំបន្ថែមក្នុងរដូវប្រាំង (ពីខែ មករា ដល់ខែ ឧសភា)។ ផ្ទៃដីតូចសម្រាប់ដំណាំបន្ថែម ត្រូវបានពន្យល់ដោយ បរិមាណទឹកពីអាងស្តុកទឹកមានកម្រិតក្នុងរដូវប្រាំង។ ក្នុងរដូវវស្សា ផលស្រូវត្រូវបានរាយការណ៍ថាបានកើន ឡើងពីប្រហែល ០,៩ តោនក្នុងមួយហិកតា ដល់ប្រហែល ២,៥ តោនក្នុងមួយហិកតា ខណៈដែលដំណាំ បន្ថែមក្នុងរដូវប្រាំងផ្តល់ផលប្រហែល ១,៥ តោនក្នុងមួយហិកតា។ ក្រុមប្រឹក្សាឃុំ បានប៉ាន់ស្មានថាប្រហែល ៤០% នៃស្រែស្រោចស្រពអាចទទួលបានទឹកធារាសាស្ត្រដោយលំហូរតាមទំនាញផែនដី ខណៈដែល ម៉ាស៊ីនបូមទឹក គឺចាំបាច់សម្រាប់ដីស្រែ ៦០% ផ្សេងទៀត។

**ឃុំរុងរឿង (ស្រុកស្ទោង)**: ឃុំនេះស្ថិតនៅចម្ងាយប្រហែល ១៥ គីឡូម៉ែត្រពីអាងស្តុកទឹក ដែលលាត សន្ធឹងតមកពីឃុំព្រះដំរី។ ឃុំនេះមានភូមិចំនួន ៩ ដែលមានគ្រួសារចំនួន ១.១០៣។ ផ្ទៃដីស្រែវស្សាសរុប មានទំហំប្រហែល ១.២០០ ហិកតា។ ក្រុមប្រឹក្សាឃុំ បានរាយការណ៍ថាប្រឡាយមេប្រវែងប្រហែល ៤.៦០០ ម៉ែត្រឆ្លងកាត់ឃុំ និង បានផ្តល់ទឹកធារាសាស្ត្រដល់ដីស្រែប្រហែល ៦២០ ហិកតា បន្ថែមលើទឹកភ្លៀងក្នុងរដូវ វស្សា។ ស្រែត្រូវបានស្រោចស្រពដោយលំហូរតាមទំនាញផែនដីពីប្រឡាយមេ។ ប៉ុន្តែ ដោយសារពុំមាន សំណង់ស្នាក់ទឹកសម្រាប់ទប់និងប្តូរទិសទឹក កសិករត្រូវទប់ប្រឡាយមេតាមមធ្យោបាយដៃដូចជាផ្ទាំងក្តារនិង ដី។ ផលស្រូវត្រូវបានរាយការណ៍ថាបានកើនឡើងពីប្រហែល ១,៥ តោនក្នុងមួយហិកតា ដល់ប្រហែល ២ តោនក្នុងមួយហិកតា ដែលតំណាងឲ្យកំណើន ៣៣%។ ដោយសារទឹកមានកម្រិតក្នុងរដូវប្រាំង និងចម្ងាយ ឆ្ងាយពីអាងស្តុកទឹក កសិករអាចដាំដំណាំបន្ថែមបានតែលើដីប្រហែល ១០ ហិកតាប៉ុណ្ណោះក្នុងរដូវប្រាំង។

ការស្តារនីតិសម្បទាប្រព័ន្ធបានផ្តល់ផលប៉ះពាល់ខ្លះលើប្រជាជនក្នុងសហគមន៍។ ក្រៅពីដីរងផលប៉ះ ពាល់មួយចំនួននៅតាមបណ្តោយទំនប់និងប្រឡាយ កំណើនទឹកស្តុកទុកក្នុងអាងបានធ្វើឲ្យដីស្រែនិងដីភូមិ

ត្រូវទឹកជន់លិច។ មន្ទីរធនធានទឹកនិងឧតុនិយមខេត្ត បានរាយការណ៍ថាគ្រួសារចំនួនប្រហែល ៧៥០ រងផលប៉ះពាល់ដោយទឹកជំនន់ ហើយរាជរដ្ឋាភិបាលកំពុងរិះរកដីកន្លែងផ្សេងដើម្បីឲ្យប្រជាជនទាំងនេះផ្លាស់លំនៅដ្ឋាន។

**ការថែទាំ:** ចាប់តាំងពីពេលស្តារនីតិសម្បទាអាងស្តុកទឹកក្នុងឆ្នាំ២០០៨មក ពុំមានFWUC ត្រូវបានបង្កើតឡើងទេ ដោយសារប្រព័ន្ធទាំងមូលនៅមិនទាន់បានបញ្ចប់នៅឡើយ។ ហេតុដូច្នេះ ពុំមានប្រព័ន្ធសម្រាប់ប្រមូលថ្លៃទឹកពីអ្នកប្រើទេ ហើយយន្តការថែរក្សាប្រព័ន្ធគឺមិនច្បាស់លាស់និងមិនដឹងនៅក្នុងចំណោមអាជ្ញាធរឃុំ។ បច្ចុប្បន្ន មានបុគ្គលពីររូបត្រូវបានតែងតាំងដោយមន្ទីរធនធានទឹកនិងឧតុនិយមខេត្តឲ្យទទួលបន្ទុកលើទ្វារទឹក និងថែទាំអាងស្តុកទឹក។

របាយការណ៍ពីឃុំដែលបានចុះសិក្សា បានបង្ហាញថាកសិករនៅក្នុងឃុំទាំងអស់ជួបប្រទះនឹងបញ្ហាប្រឈមនៃការបញ្ចេញទឹកមិនទៀងទាត់ពីអាងស្តុកទឹក។ ដើម្បីកែលម្អការសម្របសម្រួលតម្រូវការនិងការគ្រប់គ្រងទឹក ឃុំបានស្នើឲ្យបង្កើតFWUCមួយ ដើម្បីឲ្យកសិករអាចសម្របសម្រួលគ្នាឲ្យបានកាន់តែប្រសើរឡើង។ យោងតាមបទសម្ភាសន៍ជាមួយប្រជាជនមូលដ្ឋាន អ្នកទទួលបន្ទុកលើអាងស្តុកទឹកនិងទ្វារទឹកត្រូវបានចោទថា បានបញ្ចេញទឹកពីអាងស្តុកទឹក ដើម្បីឲ្យដីស្រែរាប់រយនៅក្នុងអាងស្តុកទឹកដែលជាកម្មសិទ្ធិរបស់គាត់និងអ្នកភូមិរបស់គាត់ អាចធ្វើស្រែបានក្នុងរដូវប្រាំង។ ហេតុដូច្នេះ ទឹកស្តុកទុកនៅសល់តិចនៅក្នុងអាងស្តុកទឹក ហើយកសិករនៅក្រៅអាងស្តុកទឹក ខ្វះទឹកធារាសាស្ត្រក្នុងរដូវប្រាំង។

**ជោគជ័យ និង គុណវិបត្តិ:** ការវិនិច្ឆ័យរួមលើជោគជ័យនៃការកែលម្អប្រព័ន្ធ មិនបានទាញសេចក្តីសន្និដ្ឋានពីការវាយតម្លៃបែបរហ័សនេះទេ ដោយសារទំហំធំនៃប្រព័ន្ធ និងពេលវេលាមានកម្រិតនៃការវាយតម្លៃ។ ប៉ុន្តែ របកគំហើញពីឃុំចំនួន ៤ ដែលកំពុងទទួលអត្ថប្រយោជន៍ច្រើនជាងគេពីប្រព័ន្ធ និងដែលត្រូវបានផ្តល់អនុសាសន៍ដោយមន្ទីរធនធានទឹកនិងឧតុនិយមខេត្ត បង្ហាញថាអត្ថប្រយោជន៍គឺមានច្រើន ប៉ុន្តែមិនមែនសន្ធឹកសន្ធាប់ទេ។ តារាង ៤.៣ បង្ហាញថា ប្រព័ន្ធជួយស្រោចស្រពដីស្រែ ៣.៦០០ហិកតាក្នុងរដូវវស្សាបន្ថែមលើទឹកភ្លៀង ដែលអនុញ្ញាតឲ្យគេអាចដាំដំណាំបន្ថែមក្នុងរដូវប្រាំងលើដីស្រែវស្សាទំហំ ៨០០ហិកតា និងស្រោចស្រពដីស្រែប្រាំង២.៧០០ហិកតា ដែលត្រូវទឹកជន់លិចក្នុងរដូវវស្សា។

តារាង ៤.៣. ផ្ទៃដីស្រោចស្រពនៅក្នុងឃុំ ៤ ដែលបានចុះសិក្សា និងដែលបានទទួលអត្ថប្រយោជន៍ពីគម្រោងធារាសាស្ត្រសាមសិបកញ្ញា

| No. | ឃុំ | ផ្ទៃដីស្រែវស្សា (ហិកតា) | ផ្ទៃដីមានប្រព័ន្ធធារាសាស្ត្រ (ហិកតា) ស្រោចស្រព រដូវវស្សា | ដំណាំបន្ថែមក្នុង រដូវប្រាំង | ផ្ទៃដីស្រែប្រាំង |
|---|---|---|---|---|---|
| ១ | ដំរីស្លាប់ | ៤.៩៦៤ | ៦៨០ | ២០០ | 0 |
| ២ | សាន់គ | ៦.៤៧០ | ១.២០០ | ២៥០ | 0 |
| ៣ | រុងរឿង | ១.២០០ | ១.១០០ | ៣៤០ | 0 |
| ៤ | ព្រះដំរី | ១.៦៤១ | ៦២០ | ១០ | ២.៧០០ |
| | សរុប | ១៤.២៧៥ | ៣.៦០០ | ៨០០ | ២.៧០០ |

*ប្រភព: បទសម្ភាសន៍ ជាមួយក្រុមប្រឹក្សាឃុំ និង ស្មៀនឃុំ (ខែ មិថុនា ឆ្នាំ ២០១១)*

ផ្អែកលើចម្លើយពីអ្នកផ្តល់បទសម្ភាសន៍នៅក្នុងឃុំចំនួន ៤ ដែលបានសិក្សា ប្រព័ន្ធគប្បីផ្តល់អត្ថប្រយោជន៍ឲ្យបានច្រើនជាងនេះជូនកសិករ ប៉ុន្តែ វាត្រូវបានរារាំងដោយ ១) ការស្តារនីតិសម្បទាមិនពេញលេញ (ប្រឡាយមេមិនពេញលេញ ខ្វះសំណង់ស្នាក់ទឹក និងមិនមានប្រឡាយរងទី៣) ២) ការគ្រប់គ្រងទឹកទន់ខ្សោយ ដោយមួយផ្នែកដោយសារការមិនមាន FWUC ដើម្បីសម្របសម្រួលតម្រូវការ និងការបញ្ចេញទឹក និង ៣) កង្វះទឹកសម្រាប់ដាំដំណាំបន្ថែមក្នុងរដូវប្រាំង។ ទោះជាយ៉ាងណាក្តី ការវាយតម្លៃក៏បង្ហាញផងដែរថា ប្រព័ន្ធមានសក្តានុពលខ្ពស់ក្នុងការផ្តល់អត្ថប្រយោជន៍ឲ្យដល់កសិករស្ថិតក្នុង ផ្ទៃដីគ្រោងស្រោចស្រពរបស់ប្រព័ន្ធ ជាពិសេស ដើម្បីបំពេញបន្ថែមលើទឹកភ្លៀងក្នុងរដូវវស្សា ដោយសារៈ ១) អាងស្តុកទឹកមានផ្ទៃដែនទទួលទឹកភ្លៀងធំ ២) អាងស្តុកទឹកមានប្រភពទឹកល្អ (ស្ទឹងស្ទោង) និង ៣) ផ្ទៃដីគ្រោងស្រោចស្រពភាគច្រើនស្ថិតនៅសណ្ឋានដីទីជម្រាល ដែលអំណោយផលសម្រាប់លំហូរតាមទំនាញផែនដី និងផ្តល់ផលប៉ះពាល់តិចមកលើកសិករ។

**សេចក្តីសន្និដ្ឋានៈ** ដោយសារទំហំធំនៃប្រព័ន្ធ និងដោយសារពេលវេលាមានកម្រិតនៅក្នុងការចុះសិក្សាផ្ទាល់នៅមូលដ្ឋាន ការសិក្សានេះមិនមានទំនុកចិត្តក្នុងការវិនិច្ឆ័យលើប្រព័ន្ធទាំងមូលទេ។ របកគំហើញពីការវាយតម្លៃបែបរហ័សនៅមូលដ្ឋាន បង្ហាញថាប្រព័ន្ធហាក់បីដូចជាមានសក្តានុពលច្រើនក្នុងការផ្តល់ទឹកធារាសាស្ត្រដល់ស្រែនៅក្នុងឃុំទាំង ១៧ ដែលបានរាយការណ៍នៃស្រុកចំនួនបី។ ប៉ុន្តែ មកដល់ពេលនេះ កិច្ចប្រឹងប្រែងស្តារនីតិសម្បទានៅមិនទាន់ចប់នៅឡើយ ដូច្នេះអត្ថប្រយោជន៍បច្ចុប្បន្នគឺមានតែចំពោះឃុំមួយចំនួនប៉ុណ្ណោះដែលត្រូវបានឆ្លងកាត់ដោយប្រឡាយមេដែលគេបានស្តារនីតិសម្បទា។ ភស្តុតាងពីមូលដ្ឋានក៏បង្ហាញផងដែរថាផលស្រូវបានកើនឡើងនៅតាមតំបន់ដែលមានទឹកធារាសាស្ត្រទៅដល់ និងថាប្រព័ន្ធមានសក្តានុពលច្រើនក្នុងការស្រោចស្រពដីស្រែ តាមរយៈលំហូរតាមទំនាញផែនដី ដោយសារសណ្ឋានដីទីជម្រាលអំណោយផល ប៉ុន្តែបច្ចុប្បន្នត្រូវជួបការលំបាកដោយសារកង្វះសំណង់ស្នាក់ទឹក និងប្រឡាយរងទី៣។

## ប្រព័ន្ធទី ៨: ប្រព័ន្ធធារាសាស្ត្រស្ទឹងជីនិត [ខេត្តកំពង់ធំ]

**ទស្សនៈរួមៈ** ការស្តារនីតិសម្បទាប្រព័ន្ធបានចាប់ផ្តើមក្នុងឆ្នាំ ២០០២ និង បានដំណើរការក្នុងឆ្នាំ ២០០៦ តាមរយៈជំនួយពីធនាគារអភិវឌ្ឍន៍អាស៊ី និង AFD។ ការស្តារនីតិសម្បទារួមមានអាងស្តុកទឹកនៅខាងលើខ្សែទឹកនៃស្ទឹងជីនិត និងប្រព័ន្ធប្រឡាយទឹក។ ប្រព័ន្ធនេះផ្តល់អត្ថប្រយោជន៍ឲ្យដល់ឃុំចំនួន៣[29] នៅក្នុងស្រុកបារាយណ៍ និងឃុំចំនួន៣[30] ក្នុងស្រុកសន្ទុក។ ជាផ្នែកមួយនៃការសិក្សានេះ ឃុំចំនួន៣ ក្នុងស្រុកសន្ទុក ត្រូវបានជ្រើសរើសសម្រាប់ការសង្កេតមើលអត្ថប្រយោជន៍ពីការស្តារនីតិសម្បទា។ ប្រព័ន្ធនេះមានប្រឡាយមេមួយប្រវែងប្រហែល ៧ គីឡូម៉ែត្រ និងប្រឡាយរងទី២ចំនួន ៥ ប្រវែងប្រហែល ១៨ គីឡូម៉ែត្រ។ ប្រព័ន្ធត្រូវបានចែកចេញជា ៤៨ ប្លុក មានប្រឡាយរងទី៣ចំនួន ៤៨ និង កូនប្រឡាយរំដោះទឹកចំនួន ៤៩។ ប្រឡាយមេរំដោះទឹកសំខាន់ៗក៏ត្រូវបានបំពាក់ផងដែរសម្រាប់រំដោះទឹកចេញពីប្រព័ន្ធ។ យោងតាមគណៈកម្មាធិការFWUC អាងនេះអាចស្តុកទឹកបាន២៣លានម៉ែត្រគូប ហើយប្រព័ន្ធត្រូវបានគ្រោងស្រោចស្រពដីស្រែ ២.៤០០ ហិកតានៅក្នុងប្រព័ន្ធ។

[29] ឃុំចុងដូង ឃុំឈូកខ្សាច់ និង ឃុំបល្ល័ង្គ។

[30] ឃុំបឹងល្វា ឃុំកំពង់ថ្ម និង ឃុំប្រាសាទ។

**អត្ថប្រយោជន៍:** បទសម្ភាសន៍ជាមួយភាគីពាក់ព័ន្ធនៅក្នុងប្រព័ន្ធ បានបង្ហាញថាការកែលម្អប្រព័ន្ធបាននាំមកនូវអត្ថប្រយោជន៍និងគុណវិបត្តិដូចខាងក្រោមៈ

- ទឹកធារាសាស្ត្របំពេញបន្ថែម
- អន្តរាគមន៍ពេលមានគ្រោះរាំងស្ងួត
- សមត្ថភាពរំដោះទឹកចេញ
- ដំណាំបន្ថែមក្នុងរដូវប្រាំង
- ផលស្រូវល្អ
- ផលិតកម្មបន្លែ
- ការធ្វើដំនើរតាមផ្លូវ និងផ្លូវលើខ្នងប្រឡាយ
- កន្លែងកំសាន្តនៅខាងក្រៅ
- អត្ថប្រយោជន៍ផ្សេងទៀត (ត្រី ទឹកសម្រាប់សត្វនិងគ្រួសារ)។

ដូចដែលត្រូវបានរាយការណ៍ដោយFWUC អាជ្ញាធរឃុំនិងអ្នកភូមិ ការកែលម្អប្រព័ន្ធធារាសាស្ត្រស្ទឹងជីនិតផ្តល់អត្ថប្រយោជន៍ជាច្រើនជូនកសិករ ជាពិសេស ទឹកធារាសាស្ត្រសម្រាប់ស្រែវស្សារបស់ពួកគាត់បន្ថែមលើទឹកភ្លៀង។ មុនពេលកែលម្អ មានតែស្រែមួយចំនួនប៉ុណ្ណោះដែលបានទទួលអត្ថប្រយោជន៍ពីប្រព័ន្ធទ្រុឌទ្រោមនេះ ខណៈដែលដីស្រែនៅក្នុងប្រព័ន្ធស្ទើរតែទាំងអស់គឺពឹងផ្អែកទាំងស្រុងលើទឹកភ្លៀង និងផ្តល់ផលបានប្រហែល ១,២ តោនក្នុងមួយហិកតា។ បច្ចុប្បន្ន ដីស្រែទាំងអស់នៅក្នុងប្រព័ន្ធ (លើកលែងតែដីស្រែនៅលើសណ្ឋានដីខ្ពស់ចេញ) មានទឹកធារាសាស្ត្រនៅពេលដែលពួកគាត់ត្រូវការទឹក ហើយកសិករលែងខ្លាចគ្រោះរាំងស្ងួត ឬសូម្បីតែទឹកជំនន់ទៀតហើយ ប៉ុន្តែពួកគាត់មានជំនឿកាន់តែច្រើនក្នុងការព្យាករណ៍ទិន្នផលកសិកម្មក្នុងកម្រិតផលជាមធ្យម ២,៥ តោនក្នុងមួយហិកតា។ ការមានទឹកបានលើកទឹកចិត្តកសិករកាន់តែច្រើនឡើងឲ្យដាំបន្លែ។

បរិមាណទឹកពីអាងស្តុកទឹក មានភាពបរិបូរណ៍ ហើយបរិមាណនេះអាចផ្តល់ទឹកធារាសាស្ត្រដល់ប្រព័ន្ធទាំងមូលក្នុងរដូវប្រាំង។ ប៉ុន្តែ មានកសិករតិចតួចណាស់ដែលដាំដំណាំបន្ថែមក្នុងរដូវប្រាំងដោយសារៈ ១) ការជ្រាបទឹកដោយសារដីខ្សាច់ ២) ផលទាបដែលជាហេតុមិនចំណេញ និង ៣) ការមានសត្វល្អិតចង្រៃច្រើន។ ការវាយតម្លៃផ្ទាល់បានបង្ហាញថាការផលិតដំណាំបន្ថែមក្នុងរដូវប្រាំងត្រូវបានសាកល្បងក្នុងឆ្នាំ ២០០៧ លើផ្ទៃដីប្រហែល ៤០% នៃផ្ទៃដីស្រោចស្រពរបស់ប្រព័ន្ធ ប៉ុន្តែមិនបានទទួលជោគជ័យដោយសាររងផលប៉ះពាល់ពីសត្វល្អិតចង្រៃ និងទិន្នផលទាប។ ផ្ទុយទៅវិញ កសិករមានការលំបាកក្នុងការថែទាំស្រែរបស់ខ្លួនដោយសារដីជ្រាបទឹក (ទឹកជ្រាបចេញពីស្រែយ៉ាងលឿន)។ ហេតុដូច្នេះ កសិករបានបោះបង់ការដាំដុះនៅឆ្នាំបន្ទាប់។ ដើម្បីជម្រុញការដាំដុះដំណាំបន្ថែម ឯកឧត្តម ចាន់ សារុន បានសាកល្បងផលិតកម្មក្នុងឆ្នាំ ២០០៩ ប៉ុន្តែបានបរាជ័យដោយសារសត្វល្អិតចង្រៃ និងទិន្នផលទាប។ បន្ទាប់មកការិយាល័យកសិកម្មនៅស្រុកសន្ទុកក៏បានសាកល្បងមើលក្នុងឆ្នាំ ២០១១ ហើយលទ្ធផលគឺថាស្រូវដុះ ប៉ុន្តែទិន្នផលទាបបានធ្វើឲ្យមានការខាតបង់។ ប៉ុន្តែ នៅក្នុងឆ្នាំដដែលនោះ (២០១១) មានការសាកល្បងដោយអ្នកធ្វើអាជីវកម្ម ដែលបានបង្ហាញលទ្ធផលមិនដូចគ្នាមួយ ពោលគឺផលស្រូវបានប្រហែល ៣,៥ តោនក្នុងមួយហិកតា ជាមធ្យម។

**ការថែទាំៈ** ប្រព័ន្ធត្រូវបានគ្រប់គ្រងដោយFWUC តាំងពីឆ្នាំ ២០០៧ ក្រោយពេលបញ្ចប់ការស្តារនីតិសម្បទា។ FWUC មានកសិករចំនួន ២.៨០០ នាក់ដែលមានស្រែនៅក្នុងប្រព័ន្ធ ខណៈដែលគណៈកម្មាធិការ FWUC មានសមាជិក ៥ រូប។ ការគ្រប់គ្រងប្រព័ន្ធត្រូវបានជួយដោយតំណាងអ្នកភូមិចំនួន ២៥ នាក់ និងបុគ្គលិកជួលចំនួន ៧ នាក់។ ក្នុងឆ្នាំ ២០១១ ថ្លៃទឹកត្រូវបានយកក្នុងតម្លៃ ៤០.០០០ រៀលក្នុងមួយហិកតាក្នុងមួយឆ្នាំ។ ថ្លៃទឹកនេះត្រូវបានយកលើមូលដ្ឋានមួយឆ្នាំ ដោយមិនគិតពីការធ្វើស្រែប៉ុន្មានដង និងការប្រើទឹកអស់ប៉ុន្មានទេ។ គណៈកម្មាធិការ FWUC ពន្យល់ថាថ្លៃទឹកត្រូវបានឯកភាពដោយកសិករ និងត្រូវបានកំណត់តម្លៃ ៦០.០០០ រៀលក្នុងមួយហិកតាក្នុងមួយឆ្នាំ ប៉ុន្តែត្រូវបានយកក្នុងឆ្នាំទីមួយ (ឆ្នាំ ២០០៧) ក្នុងតម្លៃ ២០.០០០ រៀល ខណៈដែលគម្រោងរួមចំណែកថ្លៃដែលនៅសល់ ហើយFWUCតម្លើងថ្លៃចំពោះកសិករពីមួយឆ្នាំទៅមួយឆ្នាំ ដើម្បីអាចទទួលខុសត្រូវពេញលេញលើការប្រមូលថ្លៃ និងការថែទាំមុនដំណាច់ឆ្នាំ ២០១៣។ ការទទួលខុសត្រូវលើការថែទាំ ត្រូវបានបែងចែកដើម្បីឲ្យមន្ទីរធនធានទឹកនិងឧតុនិយមខេត្តទទួលបន្ទុកលើសំណង់ខាងលើខ្សែទឹក ដែលរួមមានអាងស្តុកទឹក និងប្រឡាយមេ ខណៈដែល FWUC ទទួលបន្ទុកលើផ្នែកខាងក្រោមខ្សែទឹក ដែលរួមមានប្រឡាយរងទី២និងប្រឡាយរងទី៣ ប្រឡាយរំដោះទឹក និងសំណង់ផ្សេងទៀត។

ជោគជ័យរបស់ FWUC មកដល់ថ្ងៃនេះ ត្រូវបានបង្ហាញភស្តុតាងដោយការចូលរួមរបស់កសិករក្នុងការបង់ថ្លៃទឹក។ គណៈកម្មាធិការ FWUC បានប៉ាន់ស្មានថា ៩៥% នៃកសិករបានបង់ថ្លៃទឹករបស់ខ្លួនសម្រាប់ឆ្នាំ ២០១០ ឬ ប្រាក់ប្រហែល ៨៩ លានរៀល ដែលស្មើនឹងប្រហែល ៩៨% នៃថ្លៃទឹក ត្រូវបានប្រមូល។ គណៈកម្មាធិការFWUC បានត្អូញត្អែរថាកសិករមួយចំនួនបង់ថ្លៃទឹកមិនគ្រប់ រីឯអ្នកខ្លះផ្សេងទៀតបង់យឺត។ ទោះបីជាមានប្រាក់ចំណូលពីការប្រមូលថ្លៃទឹកក្តី ក៏ប្រាក់នេះមិនគ្រប់គ្រាន់សម្រាប់ទូទាត់ថ្លៃចំណាយលើការថែទាំឡើយ។ មានការលើកឡើងថាប្លង់ទំនើបនៃប្រព័ន្ធធ្វើឲ្យការថែទាំត្រូវចំណាយច្រើន។ ឧទាហរណ៍ ថវិកាគ្រោងសម្រាប់ការចំណាយក្នុងឆ្នាំ២០១០ មានចំនួន១៧៥លានរៀល ប៉ុន្តែមានតែ ៨៩ លានរៀលប៉ុណ្ណោះដែលត្រូវបានប្រមូលពីថ្លៃទឹក។ FWUC បានសម្តែងការបារម្ភរបស់ខ្លួនថា ថ្វីបើថ្លៃទឹកនឹងត្រូវបានប្រមូលក្នុងតម្លៃ៦០.០០០រៀលក្នុងមួយហិកតានៅក្នុងរយៈពេលពីរឆ្នាំខាងមុខក្តី ក៏ប្រាក់ចំណូលនេះនឹងមិនគ្រប់គ្រាន់ទេសម្រាប់បង់ថ្លៃថែទាំនៅពេលនោះ ដូច្នេះវាធ្វើឲ្យមានការបារម្ភអំពីនិរន្តរភាពរបស់ FWUC។

**សេចក្តីសន្និដ្ឋានៈ** ប្រព័ន្ធត្រូវបានបំពាក់ដោយសំណង់ទំនើប និងមានសមត្ថភាពស្តុកទឹកបានច្រើននៅក្នុងអាងស្តុកទឹក ដូច្នេះកង្វះទឹកធារាសាស្ត្រសម្រាប់ផ្ទៃដីគ្រោងស្រោចស្រពសម្រាប់រយៈពេលមួយឆ្នាំពេញនឹងពុំកើតមានឡើយ។ លក្ខណៈនេះបានលើកកម្ពស់ទំនុកចិត្តរបស់កសិករលើការធ្វើស្រែ និងបានលើកទឹកចិត្តដល់ការបង្កើនផល ដែលជាហេតុគប្បីពង្រឹងជីវភាពរបស់ពួកគាត់ តាមរយៈការកែលម្អសន្តិសុខស្បៀង និងចំណូលកាន់តែច្រើន។ ប៉ុន្តែ ទោះបីជាមានទឹកធារាសាស្ត្រក្នុងរដូវប្រាំងក្តី ក៏កសិករមិនដាំដំណាំបន្ថែមផងដែរដោយសារជួបឧបសគ្គនៃដីជ្រាបទឹក ការមានសត្វល្អិតចង្រៃច្រើន និងផលទាបក្នុងរដូវប្រាំង។ ម្យ៉ាងទៀត សំណង់ទំនើបនៃប្រព័ន្ធធ្វើឲ្យការថែទាំប្រព័ន្ធត្រូវចំណាយច្រើន ខណៈដែលថ្លៃទឹកមានតម្លៃទាប និងត្រូវបានរឹតត្បិតមួយចំណែកដោយដីស្រែអាចដាំដុះបានតែក្នុងរដូវប្រាំង។

## ប្រព័ន្ធទី ៩: ប្រព័ន្ធធារាសាស្ត្រប្រឡាយរួមស្រុក [ខេត្តព្រៃវែង]

**ទស្សនៈរួម:** ផ្អែកលើបទសម្ភាសន៍ជាមួយអាជ្ញាធរឃុំ នៅក្នុងឃុំជ្រៃ និងឃុំជាខ្លាងនៅស្រុកស្វាយអន្ទរ ការស្ដារនីតិសម្បទាប្រព័ន្ធបានចាប់ផ្ដើមតាំងពីឆ្នាំ២០០៧ ដោយមានការជួយគាំទ្រហិរញ្ញវត្ថុពីក្រសួងធនធានទឹកនិងឧតុនិយម។ តារាងខាងក្រោមបង្ហាញពីកិច្ចប្រឹងប្រែងស្ដារនីតិសម្បទាតាំងពីពេលនោះមក ប៉ុន្តែក្រុមសិក្សានេះបានចុះសិក្សាឃុំចំនួនពីរ (ឃុំជ្រៃ និងឃុំជាខ្លាង) ដែលនៅទីនោះ ការស្ដារនីតិសម្បទាបានធ្វើក្នុងឆ្នាំ២០០៨ និងឆ្នាំ២០០៩។ ឃុំនីមួយៗទទួលអត្ថប្រយោជន៍ពីប្រឡាយប្រវែងប្រហែល ៦ គីឡូម៉ែត្រ។ វាគឺជាប្រភេទប្រឡាយមេ ដែលដែនទទួលទឹកភ្លៀងមានទទឹង ១២ ម៉ែត្រ និង ជម្រៅ ៣,៥ ម៉ែត្រ។ ប្រឡាយនេះទទួលទឹកពីទឹកជំនន់នៃទន្លេមេគង្គ តាមរយៈស្រុកស៊ីធរកណ្ដាល (ខេត្តព្រៃវែង) និង ទឹកភ្លៀង។

តារាង ៤.៤. ទស្សនៈរួមអំពីការស្ដារនីតិសម្បទាប្រឡាយរួមស្រុក

| ជំហាន | ឆ្នាំ | ទីតាំង | ប្រវែង (គម) |
|---|---|---|---|
| ជំហានទី ១ | ២០០៧ | ពីចុងអំពិល ទៅសៀងឃ្វាង | ៨ |
| ជំហានទី ២ | ២០០៨ | ពីសៀងឃ្វាង ទៅព្រៃខ្លា និងជាខ្លាង | ១០ |
| ជំហានទី ៣ | ២០០៩ | ពីជាខ្លាង ទៅ ជ្រៃ | ១២ |
| ជំហានទី ៤ | ២០១០ | ពីជ្រៃ ទៅអង្គរទ្រេត និងពានរូង | ១២ |
| ជំហានទី ៥ | ២០១១ | ពីពានរូង ទៅទឹកថ្លា | ១២ |

*ប្រភព: សម្ភាសន៍ជាមួយអាជ្ញាធរឃុំនៅឃុំជាខ្លាង និងឃុំជ្រៃ*

**អត្ថប្រយោជន៍:** ការស្ដារនីតិសម្បទាប្រឡាយរួមស្រុក បាននាំមកនូវអត្ថប្រយោជន៍ និង គុណវិបត្តិដូចខាងក្រោម:

- ទឹកធារាសាស្ត្របំពេញបន្ថែម
- អន្តរាគមន៍ពេលមានគ្រោះរាំងស្ងួត
- សមត្ថភាពរំដោះទឹកចេញ
- ការផលិតដំណាំបន្ថែមក្នុងរដូវប្រាំង
- ផលស្រូវល្អ
- ផលិតកម្មបន្លែ
- លទ្ធភាពប្រើផ្លូវ និងផ្លូវលើខ្នងប្រឡាយ
- អត្ថប្រយោជន៍ផ្សេងទៀត (ត្រី ទឹកប្រើប្រាស់សម្រាប់គ្រួសារ និងសត្វ)។

ប្រឡាយរួមស្រុក គឺជាប្រព័ន្ធខ្នាតធំមួយ ដូច្នេះការសង្កេតមើលគុណសម្បត្តិ និងគុណវិបត្តិនៃប្រព័ន្ធទាំងមូលគឺមិនអាចសម្រេចបានដោយការវាយតម្លៃបែបរហ័សនេះទេ។ យ៉ាងណាមិញរបកគំហើញជាក់ស្ដែងពីឃុំដែលបានសិក្សានីមួយៗ ត្រូវបានបង្ហាញជូនដូចខាងក្រោម:

**ឃុំជាខ្លាង:** ឃុំនេះមានភូមិចំនួន ៨ និងមានគ្រួសារចំនួនប្រហែល ២.២០០ ដែលនៅក្នុងនោះគ្រួសារប្រហែល ១.៤០០ គឺជាគ្រួសារកសិករ។ ដីស្រែសរុបរបស់ឃុំមានចំនួន ២.៤៤៧ ហិកតា ដែលដីស្រែទាំងអស់នេះ គឺជាដីស្រែវស្សា។ ក្រុមប្រឹក្សាឃុំបានរាយការណ៍ថាប្រឡាយអាចផ្គត់ផ្គង់ទឹកបន្ថែមលើទឹកភ្លៀង

សម្រាប់ស្រោចស្រពដីស្រែនៅចម្ងាយប្រហែល ៣០០ ម៉ែត្រនៅសងខាងប្រឡាយ។ ជាមួយប្រឡាយប្រវែង ៦គីឡូម៉ែត្រឆ្លងកាត់ឃុំ ដីស្រែប្រហែល ៣៦០ហិកតា គប្បីទទួលបានអត្ថប្រយោជន៍ពីប្រឡាយ ប៉ុន្តែដោយសារមានប្រឡាយរងទី២ទ្រុឌទ្រោមមួយចំនួនតភ្ជាប់នឹងប្រឡាយមេនេះ អត្ថប្រយោជន៍បានរីកដល់ដីស្រែសរុបប្រហែល ៥១០ ហិកតា។ ក្នុងពេលមានគ្រោះរាំងស្ងួត ក្រុមប្រឹក្សាឃុំបានប៉ាន់ស្មានថាប្រឡាយអាចស្រោចស្រពស្រែតែក្នុងចម្ងាយ ១០០ ម៉ែត្រប៉ុណ្ណោះ ដែលស្មើនឹងប្រហែលមួយភាគបីនៃសមត្ថភាពរបស់វាបន្ថែមលើទឹកភ្លៀង។

ការស្រោចស្រពស្រែដោយលំហូរតាមទំនាញផែនដីពីប្រឡាយ គឺមិនអាចធ្វើបានទេ ប៉ុន្តែអាចធ្វើបានតាមរយៈម៉ាស៊ីនបូមទឹក ដែលគឺជាចំណាយច្រើនសម្រាប់កសិករ។ ក្រោយពេលស្តារនីតិសម្បទាប្រព័ន្ធ ផលស្រូវនៅតាមបណ្តោយប្រឡាយត្រូវបានសង្កេតឃើញថាបានកើនឡើងពីប្រហែល ១,៥ តោនក្នុងមួយហិកតាដល់ប្រហែល ២ តោនក្នុងមួយហិកតានាពេលបច្ចុប្បន្ន ដែលបង្ហាញពីកំណើន ៣៣% ថ្វីបើកត្តាផ្សេងទៀតគប្បីត្រូវបានរាប់បញ្ចូលផងដែរ ពោលគឺ មិនមែនដោយសារតែទឹកធារាសាស្ត្រតែមួយមុខប៉ុណ្ណោះទេ។ ដោយសារប្រឡាយមានទំហំធំនិងជ្រៅ កសិករក៏អាចបង្ហូរទឹកលើសក្នុងស្រែបញ្ចូលក្នុងប្រឡាយនេះផងដែរ ដែលគឺជាអត្ថប្រយោជន៍មួយទៀតរបស់ប្រឡាយ ដើម្បីការពារស្រែពីទឹកជំនន់។ ប៉ុន្តែ ទឹកធារាសាស្ត្រមិនអាចប្រើសម្រាប់ដំណាំបន្ថែមក្នុងរដូវប្រាំងបានទេ ដោយសារកង្វះទ្វារទឹក/សំណង់ស្ទាក់ទឹកដើម្បីទប់ទឹក ដូច្នេះទឹកចេះតែពីហូរចេញទៅខាងក្រោមខ្សែទឹកនៃប្រឡាយ។

**ឃុំជ្រៃ:** ឃុំនេះមានភូមិចំនួន ១៦ និងមានគ្រួសារចំនួនប្រហែល ៣.១០០ ដែលសុទ្ធសឹងជាគ្រួសារកសិករ។ ឃុំនេះមានដីស្រែសរុបប្រហែល ៣.៥៥០ ហិកតា និង ពុំមានដីស្រែប្រាំងទេ។ រួមជាមួយកូនប្រឡាយរងផ្សេងទៀត ប្រឡាយមេប្រវែង ៦ គីឡូម៉ែត្រដែលឆ្លងកាត់ឃុំ ផ្តល់អត្ថប្រយោជន៍ជូនកសិករ នៅក្នុងភូមិចំនួន ៥[31]។ អត្ថប្រយោជន៍ប្រមូលផ្តុំច្រើនជាងនៅក្នុងភូមិចំនួន ៣ ពោលគឺភូមិព្រៃតាណាន់ គោករវាង និង ស្វាយគុន។

ដូចដែលត្រូវបានរាយការណ៍ដោយអាជ្ញាធរឃុំអញ្ចឹង សមត្ថភាពស្រោចស្រពរបស់ប្រឡាយ បន្ថែមលើទឹកភ្លៀង គឺស្រោចស្រពបានតែស្រែនៅក្នុងរង្វង់ ៣០០ ម៉ែត្រនៅសងខាងប្រឡាយប៉ុណ្ណោះ។ តាមបណ្តោយប្រឡាយប្រវែងប្រហែល ៦ គីឡូម៉ែត្រឆ្លងកាត់ឃុំ ប្រឡាយរួមស្រុកនេះអាចផ្គត់ផ្គង់ទឹកធារាសាស្ត្រដល់ដីស្រែប្រហែល ៣៦០ ហិកតា។ ប៉ុន្តែ ឃុំបានប្រើមូលនិធិឃុំ/សង្កាត់រយៈពេល ៣ ឆ្នាំក្នុងពេលកន្លងមកដើម្បីស្តារប្រឡាយរងទី២មួយប្រវែងសរុប ៧,៧ គីឡូម៉ែត្រ ខណៈដែលប្រវែង ២,៤ គីឡូម៉ែត្រផ្សេងទៀតត្រូវបានស្តារដោយមន្ទីរធនធានទឹកនិងឧតុនិយមខេត្ត។ ដោយត្រូវបានបំពេញបន្ថែមដោយប្រឡាយរងទី២ទាំងនេះ ប្រឡាយរួមស្រុកពង្រីកសម្ថភាពស្រោចស្រពរបស់វាបន្ថែមទៀតដើម្បីផ្តល់អត្ថប្រយោជន៍ដល់ដីស្រែប្រហែល ៣៥០ ហិកតាថែមទៀត។ ប្រការនេះមានន័យថាដីស្រែសរុប ៧០០ ហិកតា ទទួលទឹកធារាសាស្ត្រពីប្រឡាយរួមស្រុក បំពេញបន្ថែមលើទឹកភ្លៀងក្នុងរដូវវស្សា។ ក្នុងពេលមានគ្រោះរាំងស្ងួត គេបានប៉ាន់ស្មានថាដីស្រែប្រហែលមួយភាគបីនៃដីស្រែស្រោចស្រពដែល ត្រូវបានបំពេញបន្ថែមដោយទឹកភ្លៀង និងអាចត្រូវបានសង្គ្រោះដោយប្រឡាយ។

[31] ភូមិក្រសាំងកូវី ភូមិព្រៃតាណាន់ ភូមិគោករវាង ភូមិស្វាយគុន និង ភូមិព្រហ៊ារ។

មធ្យោបាយស្រោចស្រពសម្រាប់ស្រែទាំងនេះគឺសុទ្ធតែត្រូវស្រោចស្រព ដោយម៉ាស៊ីនបូមទឹកទាំងអស់ ដែលបានការដាក់ចំណាយផងដែរចំពោះកសិករ។ យោងតាមអាជ្ញាធរឃុំ ការស្តារនីតិសម្បទាប្រឡាយមេបានផ្តល់ឥទ្ធិពលវិជ្ជមានខ្លះមកលើផលស្រូវ។ ផលស្រូវត្រូវបានរាយការណ៍ថាបានកើនឡើងពីប្រហែល ១,៥ តោនក្នុងមួយហិកតា ដល់ប្រហែល ២ តោនក្នុងមួយហិកតា ដែលបង្ហាញពីកំណើន៣៣% ដែលដូចជាករណីនៅក្នុងឃុំជាខ្លាងអញ្ចឹងដែរ។ ដោយមានទ្វារទឹកមួយសម្រាប់គ្រប់គ្រងទឹក ទឹកត្រូវបានទប់និងស្តុកទុកនៅក្នុងប្រឡាយ និង ត្រូវបានប្រើសម្រាប់ផលិតកម្មដំណាំបន្លែមលើផ្ទៃដី ៦៥ ហិកតា ក្នុងរដូវប្រាំង។ គួរឲ្យកត់សម្គាល់ផងដែរនោះ ដំណាំបន្លែមផ្តល់ផលតិចជាង១,៧តោនក្នុងមួយហិកតា។ អត្ថប្រយោជន៍មួយទៀតនៃប្រឡាយគឺថា វាបំពេញមុខងារជាប្រឡាយរំដោះទឹកមួយសម្រាប់បង្ហូរទឹកលើសចេញពីស្រែ។

ការមានទឹកពីប្រឡាយបានលើកទឹកចិត្តឲ្យកសិករ ជាពិសេសនៅភូមិគោករវាងនិងស្វាយគុន ដាំឈើហូបផ្លែ និងបន្លែ រួមមានឪឡឹក និងត្រសក់ជាដើម។

**ការថែទាំ:** បទសម្ភាសន៍ជាមួយឃុំទាំងពីរបានបង្ហាញថា ពុំមានកិច្ចប្រឹងប្រែងបង្កើតយន្តការថែទាំប្រព័ន្ធនៅថ្នាក់សហគមន៍ជាផ្នែកមួយនៃកិច្ចប្រឹងប្រែងស្តារនីតិសម្បទាឡើយ។ ហេតុដូច្នេះហើយ បានជាពុំមានFWUC នៅក្នុងឃុំទាំងពីរដើម្បីប្រមូលថ្លៃទឹក ឬទទួលបន្ទុកលើការថែទាំ។ ប៉ុន្តែ ការសិក្សាបានរកឃើញថាកសិករនៅភូមិដែលបានទទួលអត្ថប្រយោជន៍ពីប្រព័ន្ធ បានចងក្រងទៅជាក្រុមនៅក្នុងភូមិរបស់ពួកគេ។ នៅពេលប្រព័ន្ធខូច ពួកគេប្រមូលវិភាគទានពីគ្រួសារទទួលផលដើម្បីជួសជុល។

**ជោគជ័យ និង គុណវិបត្តិ:** ការស្តារនីតិសម្បទាបាននាំទឹកធារាសាស្ត្រមកជូនកសិករ និងបានជម្រុញឲ្យមានផលស្រូវកាន់តែល្អ ប៉ុន្តែកិច្ចប្រឹងប្រែងនេះហាក់បីដូចជាជួបការលំបាកខ្លាំងដោយសារធនធានមានកម្រិត។ ប្រឡាយត្រូវបានស្តារជាជំហានៗពីមួយឆ្នាំទៅមួយឆ្នាំជាមួយសំណង់មិនពេញលេញ ពោលគឺខ្វះប្រឡាយរងទី៣និងប្រឡាយរងទី២ ទ្វារទឹក/សំណង់ស្ទាក់ទឹក ជាដើម។ ហេតុដូច្នេះ ប្រឡាយអាចត្រឹមតែផ្តល់ទឹកដល់ដីស្រែដែលនៅជាប់ប្រឡាយប៉ុណ្ណោះ។ នៅឃុំជ្រៃ មូលនិធិឃុំ/សង្កាត់ត្រូវបានប្រើដើម្បីកែលម្អកូនប្រឡាយរងដើម្បីពង្រីកប្រឡាយមេឲ្យបានទៅដល់ស្រែកាន់តែច្រើនថែមទៀត ប៉ុន្តែមូលនិធិស្តួចស្តើងនោះមិនអាចពង្រីកផ្ទៃដីស្រោចស្រពឲ្យបានកាន់តែធំទេ។ លើសពីនេះទៀត កិច្ចប្រឹងប្រែងលើគម្រោងស្តារនីតិសម្បទាដើម្បីធានាកិច្ចប្រតិបត្តិការ និងនិរន្តរភាពនៃប្រព័ន្ធដោយបង្កើតFWUC ឬមធ្យោបាយផ្សេងទៀតដើម្បីទទួលបន្ទុកលើការគ្រប់គ្រងនិងការថែទាំប្រព័ន្ធ គឺមិនទាន់បានផ្តួចផ្តើម នៅឡើយទេ។

**សេចក្តីសន្និដ្ឋាន:** ការស្តារនីតិសម្បទាប្រព័ន្ធអនុញ្ញាតឲ្យកសិករមានទឹកធារាសាស្ត្រសម្រាប់ស្រែរបស់ពួកគាត់ ដែលជាហេតុធ្វើឲ្យពួកគាត់ធ្វើស្រែដោយមានទំនុកចិត្ត។ ប្រឡាយហាក់បីដូចជារួមចំណែកធ្វើអោយផលស្រូវវស្សាកាន់តែល្អ និងជួយឲ្យកសិករអាចដាំដំណាំបន្លែមក្នុងរដូវប្រាំង និងដាំឈើហូបផ្លែព្រមទាំងបន្លែ។ ប៉ុន្តែ ទឹកស្រោចស្រពអាចទៅដល់តែដីស្រែនៅជាប់ប្រឡាយតាមរយៈម៉ាស៊ីនបូមទឹក ដែលស្ថានភាពនេះបង្ហាញថា អត្ថប្រយោជន៍មិនត្រូវបានចែករំលែកឲ្យបានទូលាយនៅក្នុងចំណោមកសិករនៅក្នុងសហគមន៍ទេ។

## ប្រព័ន្ធទី ១០: ប្រព័ន្ធធារាសាស្ត្រត្រដែត (ខេត្តស្វាយរៀង)

**ទស្សនៈរួមៈ** ប្រព័ន្ធនេះស្ថិតនៅក្នុងឃុំព្រះពន្លា ស្រុកកំពង់រោទិ៍។ ប្រព័ន្ធត្រូវបានស្តារនីតិសម្បទាក្នុងឆ្នាំ ២០០៩ តាមរយៈមូលនិធិបន្ធូរបន្ថយបំណុលរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ។ ជារួម ប្រព័ន្ធមានប្រឡាយមេបីប្រវែង ១.៧០០ ម៉ែត្រ (ជាមួយជម្រៅជាមធ្យម ៣ ម៉ែត្រ និង ទទឹង ១១ ម៉ែត្រ) ប្រឡាយរងទី៣ចំនួន ១៨ ប្រវែង ១៤.៣៥០ ម៉ែត្រ (ត្រូវបានសាងសង់ភាគច្រើនផ្អែកលើគំរូលំហូរតាមទំនាញផែនដី) និង សំណង់ ៥៣ សម្រាប់គ្រប់គ្រង និងស្ទាក់ទឹក។ អាងស្តុកទឹកត្រូវបានសាងសង់ជាមួយស្ពានមួយ និងទំនប់មួយឆ្លងកាត់ស្ទឹងប្រសូត្រ ដើម្បីប្រមូលទឹកសម្រាប់ស្រោចស្រពផ្ទៃដីគ្រោងស្រោចស្រពទំហំ ២៤០ ហិកតា។

**អត្ថប្រយោជន៍ៈ** ផ្អែកលើការវាយតម្លៃផ្ទាល់នៅមូលដ្ឋាន ប្រព័ន្ធធារាសាស្ត្រនេះអាចផ្តល់អត្ថប្រយោជន៍នានាជូនដល់ប្រជាជននៅក្នុងសហគមន៍ ដូចខាងក្រោមៈ

- ទឹកធារាសាស្ត្របំពេញបន្ថែម
- អន្តរាគមន៍ពេលមានគ្រោះរាំងស្ងួត
- ការផលិតដំណាំបន្ថែមក្នុងរដូវប្រាំង
- ប្រព័ន្ធរំដោះទឹក
- កំណើនផលស្រូវ
- លទ្ធភាពប្រើប្រាស់ផ្លូវសម្រាប់ការធ្វើដំណើរនិងការដឹកជញ្ជូន
- កន្លែងកំសាន្តនៅខាងក្រៅ។

ក្រោយពេលស្តារនីតិសម្បទា ប្រព័ន្ធអាចផ្គត់ផ្គង់ទឹកធារាសាស្ត្រដល់ផ្ទៃដីគ្រោងស្រោចស្រពទាំង ២៤០ ហិកតា នៅក្នុងរដូវវស្សា។ វាផ្តល់អត្ថប្រយោជន៍ជូនកសិករនៅក្នុងភូមិចំនួន ៤[32] ដែលកសិករទាំងនោះភាគច្រើនគឺជាអ្នកភូមិត្រដែត។ យោងតាមFWUC និងអ្នកផ្តល់ព័ត៌មានគន្លឹះ ដីស្រែទាំង២៤០ហិកតាអាចត្រូវបានសង្គ្រោះដោយប្រព័ន្ធ នៅពេលមានគ្រោះរាំងស្ងួត។ ក្នុងចំណោមដីទាំង២៤០ហិកតានេះ ១០០ ហិកតាអាចត្រូវបានស្រោចស្រព ដោយលំហូរតាមទំនាញផែនដីពីប្រព័ន្ធ។ ដីស្រែ ១៤០ ហិកតាផ្សេងទៀតត្រូវបានស្រោចស្រពដោយស្ថានីយបូមទឹកមួយដែលដំណើរការដោយមន្ទីរធនធានទឹកនិងឧតុនិយមខេត្ត។ ទឹកពីស្ថានីយបូមទឹកនេះ ហូរដោយផ្ទាល់ចូលទៅក្នុងដីស្រែទាំង ១៤០ ហិកតា តាមរយៈលំហូរតាមទំនាញផែនដី ប៉ុន្តែបញ្ហាប្រឈមគឺថាម៉ាស៊ីនបូមទឹកមិនស្ថិតនៅទីនោះជាអចិន្ត្រៃយ៍ និងមិនត្រូវបានគ្រប់គ្រងដោយ FWUCនោះឡើយ។ ម៉ាស៊ីនបូមទឹកត្រូវបានយកមកស្ថានីយ តែនៅពេលណាដែលមានគ្រោះរាំងស្ងួត និងសំណើច្រើនពីកសិករប៉ុណ្ណោះ។ ប្រជាជនក្នុងសហគមន៍បានពន្យល់ថាពេលណាមានភ្លៀងតិចក្នុងរដូវវស្សា ពួកគាត់មិនអាចប្រើស្ថានីយបូមទឹកដើម្បីបំពេញទឹកបន្ថែមពីប្រព័ន្ធបានឡើយ។ ស្ថានីយបូមទឹកត្រូវប្រើតែសម្រាប់ធ្វើអន្តរាគមន៍ពេលមានគ្រោះរាំងស្ងួតប៉ុណ្ណោះ។

យោងតាមរបាយការណ៍នៃបទសម្ភាសន៍ ផលស្រូវហាក់បីដូចជាបានប្រសើរឡើងច្រើននៅក្នុងចំណោមដីស្រែទាំងឡាយដែលមានទឹកធារាសាស្ត្រគ្រប់គ្រាន់ ថ្វីបើប្រព័ន្ធធារាសាស្ត្រមិនមែនគឺជាកត្តារួម

[32] ភូមិត្រដែត ភូមិគ្រោក ភូមិព្រះពន្លា និងភូមិត្របែក។

ចំណែកតែមួយគត់ក្តី ។ ឧទាហរណ៍ មុនពេលស្តារនីតិសម្បទា ស្រែទំហំមួយហិកតាអាចផ្តល់ផលបានតែប្រហែល ១តោនស្រូវប៉ុណ្ណោះ ប៉ុន្តែនៅពេលនេះ នៅក្នុងដីស្រែដដែល ផលបានកើនឡើងដល់ប្រហែល ១,៥ តោន ដែលបង្ហាញកំណើន៥០%។ ម្យ៉ាងទៀត ដោយមានការកែលម្អលើប្រព័ន្ធ កសិករនៅក្នុងសហគមន៍នៅពេលនេះ បានចាប់ផ្តើមប្រើពូជកែលម្អ (ដូចជា ពូជស្រូវផ្ការំដួល និងពូជស្រូវសែនពិដោរជាដើម) ដែលអាចត្រូវបានផ្សារភ្ជាប់ទៅនឹងទំនុកចិត្តក្នុងចំណោមកសិករទាំងនោះលើការមានទឹកពីប្រព័ន្ធ។

ការមានទឹកពីប្រព័ន្ធអនុញ្ញាតឲ្យកសិករអាចដាំដំណាំលើកទីពីរ និងលើកទីបីក្នុងរដូវប្រាំងបាន។ យោងតាមFWUC និងអ្នកផ្តល់ព័ត៌មានគន្លឹះ ដំណាំលើកទីពីរត្រូវបានដាំលើផ្ទៃដីប្រហែល ៦០ ហិកតា (ពីខែ មករា ដល់ខែ មេសា) ហើយដំណាំទីបីអាចដាំបានលើដីប្រហែល ៣០ ហិកតា (ពីខែ ឧសភា ដល់ខែ កក្កដា) ដោយទទួលបានផលជាមធ្យម ៣,៥ តោនក្នុងមួយហិកតា។ ការកែលម្អប្រព័ន្ធក៏ផ្តល់ផងដែរនូវផ្លូវតាមបណ្តោយខ្នងប្រឡាយមេដែលសូម្បីតែរថយន្តក៏អាចធ្វើដំណើរបាន។ ជាមួយនឹងការមានផ្លូវ កសិករអាចធ្វើដំណើរ ឬដឹកជញ្ជូនធាតុចូលនិងផលិតផលកសិកម្មរបស់ខ្លួនបានកាន់តែងាយស្រួល។

ក្រៅពីអត្ថប្រយោជន៍ទាំងអស់នេះ អាងស្តុកទឹកត្រូវបានរាយការណ៍ថាបានបង្កឲ្យមានជាទឹកជំនន់លើដីស្រែប្រហែល ៤០ ហិកតានៅក្នុងភូមិជិតខាង។

**ការថែទាំ:** FWUC មួយត្រូវបានបង្កើតឡើងដើម្បីគ្រប់គ្រងគម្រោងប្រព័ន្ធធារាសាស្ត្រ។ FWUC មានគណៈកម្មាធិការគ្រប់គ្រងមួយ និងក្រុមរងចំនួន ១១ ដែលមានសមាជិកសរុប ៥៣ នាក់។ FWUC មានតួនាទីប្រមូលថ្លៃទឹកពីកសិករ ដែលមានតម្លៃ ៤០.០០០ រៀលក្នុងមួយហិកតា ប៉ុន្តែតម្លៃនេះមិនត្រូវបានយកចំពោះកសិករដែលដាំដំណាំបន្ថែមក្នុងរដូវប្រាំងទេ។ ប្រធាន FWUC បានរាយការណ៍ថាការប្រមូលថ្លៃទឹកមិនបានទទួលជោគជ័យទេ និងថាមានការពិបាកណាស់ក្នុងការប្រមូលថ្លៃទឹកពីកសិករ ដោយសារពួកគាត់ខ្លះបដិសេធមិនប្រើទឹកពីប្រព័ន្ធសម្រាប់ស្រោចស្រពដំណាំរបស់ពួកគាត់ ដូច្នេះពួកគាត់ប្រមូលបានថវិការតិចណាស់មកដល់ពេលនេះ (ប្រាក់ចំនួន ៧៨០.០០០ រៀលត្រូវបានប្រមូល)។ ប៉ុន្តែ មានសំណើពីមន្ទីរធនធានទឹកនិងឧតុនិយមខេត្ត ឲ្យប្រមូលថ្លៃទឹកពីកសិករនៅក្នុងប្រព័ន្ធទាំងអស់ នៅក្នុងរដូវដាំដុះខាងមុខ ទោះបីជាពួកគាត់ប្រើ ឬមិនប្រើទឹកពីប្រព័ន្ធធារាសាស្ត្រក្តី។

**ជោគជ័យ និង គុណវិបត្តិ:** អាជ្ញាធរមូលដ្ឋាន និង អ្នកភូមិ រួមទាំងអ្នកដែលមានដីស្រែរងផលប៉ះពាល់ដោយប្រព័ន្ធផង បានសម្តែងការពេញចិត្តរបស់ខ្លួនជាមួយប្រព័ន្ធ ដោយសារការកែលម្អលើការទទួលបានទឹកធារាសាស្ត្រ ផ្លូវតាមបណ្តោយខ្នងប្រឡាយ និងអត្ថប្រយោជន៍ផ្សេងទៀត ដូចជាការដាំដំណាំបន្ថែម និងកំណើនផលស្រូវ។ កសិករខ្លះដែលដីស្រែរបស់ពួកគាត់បានរងផលប៉ះពាល់ពីប្រព័ន្ធ បាននិយាយថាទិន្នផលស្រែរបស់ពួកគាត់នៅតែបានប្រសើរជាងកាលពីមុនពេលស្តារនីតិសម្បទា ដោយសារដីរបស់ពួកគាត់មានទំហំតូចជាង។ លើសពីនេះទៀត គម្រោងស្តារនីតិសម្បទាកសាងមិនត្រឹមតែអាងស្តុកទឹក និងប្រឡាយមេប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានកសាងប្រឡាយរងទី៣ឲ្យបានគ្រប់គ្រាន់នៅក្នុងប្រព័ន្ធ សម្រាប់បង្វែរទឹកចូលដល់ក្នុងស្រែដោយផ្ទាល់តែម្តង។ ប៉ុន្តែ ចំណុចខ្សោយគឺថា កសិករនៃដីស្រែ ១៤០ ហិកតានៅក្នុងប្រព័ន្ធមិនអាចប្រើទឹកធារាសាស្ត្រ តាមចិត្តចង់បាន ដោយសារស្ថានីយបូមទឹកនេះមិនត្រូវបានដំណើរការដោយ

FWUC ទេ ប៉ុន្តែ ត្រូវបានគ្រប់គ្រងដោយមន្ទីរធនធានទឹកនិងឧតុនិយមខេត្ត។ ស្ថានីយដំណើរការតែនៅពេលមានគ្រោះរាំងស្ងួត និងនៅពេលមានសំណើរួមច្រើនពីកសិករជាច្រើនប៉ុណ្ណោះ។

**សេចក្តីសន្និដ្ឋាន:** ការស្តារនីតិសម្បទាប្រព័ន្ធបានបង្ហាញថាគឺជាជោគជ័យដ៏ធំមួយ ដោយសារវាធ្វើឲ្យមានទឹកធារាសាស្ត្រសម្រាប់ស្រែទាំងអស់នៅក្នុងផ្ទៃដីគ្រោងស្រោចស្រពក្នុងរដូវវស្សា។ លក្ខណៈនេះបានអនុញ្ញាតឲ្យកសិករខ្លះអាចដាំដំណាំបន្ថែមក្នុងរដូវប្រាំង និងបានកែលម្អការធ្វើដំណើរតាមបណ្តោយខ្នងប្រឡាយ ព្រមទាំងបានផ្តល់អត្ថប្រយោជន៍ផ្សេងទៀត។ ប៉ុន្តែ កសិករបានជួបការលំបាកក្នុងការទទួលបានទឹកស្រោចស្រពសម្រាប់ដីស្រែប្រហែល ១៤០ ហិកតានៅក្នុងប្រព័ន្ធ នៅពេលមានភ្លៀងតិចឬគ្រោះរាំងស្ងួត ដោយសារស្ថានីយបូមទឹកត្រូវបានគ្រប់គ្រងដោយមន្ទីរធនធានទឹកនិងឧតុនិយមខេត្ត។ ម្យ៉ាងទៀត FWUC មិនដំណើរការបានល្អទេ និងអាចមិនទទួលបានជោគជ័យទេ ដោយសារកសិករមិនបង់ថ្លៃទឹក និងដោយសារសមត្ថភាពទាបនៅក្នុងចំណោម FWUC ខ្លួនឯងផ្ទាល់តែម្តង។

## ប្រព័ន្ធទី ១១: ប្រព័ន្ធធារាសាស្ត្រដងខ្ទម [ខេត្តតាកែវ]

**ទស្សនៈរួម:** ដងខ្ទមគឺជាឈ្មោះរបស់អាងស្តុកទឹក។ វាត្រូវបានកែលម្អក្នុងឆ្នាំ ២០០៩ ដោយក្រសួងធនធានទឹកនិងឧតុនិយម។ ការស្តារនីតិសម្បទាប្រព័ន្ធត្រូវបានធ្វើម្តងនៅដើមទសវត្សឆ្នាំ២០០០។ ទីតាំងនៃប្រព័ន្ធគឺនៅចន្លោះសង្កាត់រការក្រៅ (ក្រុងដូនកែវ) និង ឃុំស្រង៉ែ (ស្រុកទ្រាំង)។ ការស្តារនីតិសម្បទា ជាសំខាន់ គឺអាងស្តុកទឹកតែម្តង (រួមទាំងទំនប់ និងទ្វារទឹក) និង ប្រឡាយមេមួយប្រវែងប្រហែល ៦៦០ ម៉ែត្រ។ អត្ថប្រយោជន៍បានទៅដល់ភូមិចំនួនប្រាំនៃសង្កាត់រការក្រៅ (ភូមិព្រេច ត្រពាំងសាលា តុំ ធ្នុង និងត្រាំ) និងភូមិ ២ ផ្សេងទៀតនៃឃុំស្រង៉ែ (ភូមិព្រៃរុន និងព្រៃឈើទាល)។ ប្រឡាយនៅក្នុងប្រព័ន្ធ ត្រូវបានស្តារដោយក្រុមការងារគណៈបក្សប្រជាជនកម្ពុជា។

**អត្ថប្រយោជន៍:** ការស្តារនីតិសម្បទាអាងស្តុកទឹក ផ្តល់អត្ថប្រយោជន៍ជូនកសិករនៅក្នុងភូមិចំនួន ៥ នៃសង្កាត់រការក្រៅ[33] និង ភូមិចំនួន ២ នៃឃុំស្រង៉ែ[34]។ អត្ថប្រយោជន៍ពីការកែលម្អប្រព័ន្ធ រួមមានដូចខាងក្រោម:

- ទឹកធារាសាស្ត្របំពេញបន្ថែម
- អន្តរាគមន៍ពេលមានគ្រោះរាំងស្ងួត
- ផលិតកម្មដំណាំបន្ថែម (ដើមរដូវវស្សា)
- ផលស្រូវល្អ
- លទ្ធភាពធ្វើដំណើរតាមផ្លូវ និងផ្លូវតាមបណ្តោយខ្នងប្រឡាយ។

នៅរការក្រៅ ស្រែប្រាំងទំហំ ៣៧៥ ហិកតា ទទួលអត្ថប្រយោជន៍ពីការកែលម្អអាងស្តុកទឹក។ មុនពេលកែលម្អ កសិករក៏ធ្វើស្រែលើដីដដែលទាំងនេះផងដែរ ប៉ុន្តែពួកគាត់ជាធម្មតាបានជួបប្រទះនឹងការខ្វះទឹក

[33] សង្កាត់មួយក្នុងក្រុងដូនកែវ ខេត្តតាកែវ។

[34] ឃុំមួយក្នុងស្រុកទ្រាំង ខេត្តតាកែវ។

ធារាសាស្ត្រពីអាងស្តុកទឹក ដូច្នេះស្រែផ្តល់ផលបានតិចជាង។ ក្រោយពេលកែលម្អ ស្រែប្រាំងទាំង៣៧៥ ហិកតា ទទួលទឹកបានគ្រប់គ្រាន់។ ជាលទ្ធផល កសិករអាចប៉ាន់ប្រមាណផលិតកម្ម និងទិន្នផលកសិកម្ម របស់ពួកគាត់បាន។ ផលត្រូវបានគេរាយការណ៍ថាបានកើនឡើងពី ២,៨តោនក្នុងមួយហិកតា ដល់ប្រហែល ៣,៨តោនក្នុងមួយហិកតា ជាមធ្យម ដែលបង្ហាញពីកំណើន ២៨%។ ប្រហែល ២០% នៃដីស្រែទាំងនេះ ទទួលទឹកតាមរយៈម៉ាស៊ីនបូមទឹក ខណៈដែលដីស្រែផ្សេងទៀតទទួលបានទឹកដោយ លំហូរតាមទំនាញផែនដីចូលដល់ស្រែតែម្តង។

កសិករនៅភូមិព្រៃរុន និងព្រៃឈើទាលក្នុងឃុំស្រង៉ែទទួលអត្ថប្រយោជន៍ពីការកែលម្អប្រព័ន្ធ ដូចខាងក្រោម ។ អាងស្តុកទឹកផ្តល់ទឹកធារាសាស្ត្រដល់ដីស្រែប្រហែល ១០០ ហិកតា បន្ថែមលើទឹកភ្លៀង និងជាអន្តរាគមន៍ពេលមានគ្រោះរាំងស្ងួតក្នុងរដូវវស្សា ប្រៀបធៀបទៅនឹងប្រហែល ៦០ ហិកតា មុនពេលស្តារនីតិសម្បទា។ ទឹកស្រោចស្រពក៏អនុញ្ញាតផងដែរឲ្យមានការដាំដុះដំណាំបន្ថែមនៅដើមរដូវវស្សា លើដីស្រែ ៧០ ហិកតា ពីខែ មេសា ដល់ខែ កក្កដា។ ចំពោះផលស្រូវវិញ ប្រជាជនមិនបានកត់សម្គាល់ឃើញពីភាពខុសគ្នាច្រើននោះទេ ដោយសារការស្តារនីតិសម្បទាមិនបាននាំមកនូវភាពខុសគ្នាច្រើនឡើយ ទាក់ទិននឹងការទទួលបានទឹកស្រោចស្រព ពោលគឺវាគ្រាន់តែងាយស្រួលជាងមុនក្នុងការទាញយកទឹកពីអាងស្តុកទឹកប៉ុណ្ណោះ។ ផលនៃស្រែវស្សា និងស្រែដើមរដូវវស្សាត្រូវបានរាយការណ៍ថាស្រដៀងគ្នា ដែលមានចំនួនប្រហែល ៣,៥ តោនក្នុងមួយហិកតាជាមធ្យម។

គណៈកម្មាធិការគ្រប់គ្រងទឹកបានមានប្រសាសន៍ថា តាមពិតទៅ ផ្ទៃដីដាំដុះសម្រាប់ស្រែដើមរដូវវស្សា បានថយចុះពីប្រហែល១៣០ ហិកតា មុនពេលកែលម្អប្រព័ន្ធ ដល់ប្រហែល៧០ ហិកតា ដែលបានថយចុះប្រហែល ៤៥%។ ប៉ុន្តែ មានការពន្យល់ថាការធ្លាក់ចុះគឺមិនមែនដោយសារការកែលម្អប្រព័ន្ធទេ ប៉ុន្តែគឺដោយសារការយកថ្លៃប្រើប្រាស់ទឹក និង ផលប៉ះពាល់នៃសត្វល្អិតចង្រៃ។ កាលពីពេលមុន ទឹកស្រោចស្រពត្រូវបានបូម ដោយមានការជួយឧបត្ថម្ភហិរញ្ញវត្ថុពីក្រុមការងារគណៈបក្សប្រជាជនកម្ពុជា ហើយពុំមានការយកថ្លៃពីកសិករទេ។ ហេតុដូច្នេះ កសិករជាច្រើនធ្វើស្រែដើមរដូវវស្សា និងដណ្តើមទឹកគ្នា។ បច្ចុប្បន្ន ពេលដែលថ្លៃទឹកត្រូវបានយក កសិករខ្លះបានឈប់ការផលិត។ កសិករផ្សេងទៀត បានឈប់ដោយសារដីស្រែពួកគាត់ត្រូវរងផលប៉ះពាល់ខ្លាំងពីសត្វល្អិតចង្រៃ ជាពិសេសសត្វកណ្តុរ។ ឧទាហរណ៍ លោកស្រី គង់ ផុន កសិករមួយរូបនៅភូមិព្រៃឈើទាល បានទទួលផលតែ ២០០ គីឡូក្រាម ប៉ុណ្ណោះក្នុងឆ្នាំនេះ ប្រៀបធៀបទៅនឹង ១.១០០ គីឡូក្រាម កាលពីឆ្នាំមុនលើដីស្រែទំហំ ០,៣៥ ហិកតារបស់គាត់។

**ការថែទាំ:** ក្រោយពេលស្តារនីតិសម្បទាក្នុងឆ្នាំ២០០៩ គណៈកម្មាធិការគ្រប់គ្រងមួយ ដែលមិនមែនជាFWUC ត្រូវបានបង្កើតឡើងនៅខាងឃុំស្រង៉ែ ដើម្បីត្រួតពិនិត្យកិច្ចប្រតិបត្តិការ និងការគ្រប់គ្រងការចែកចាយទឹកនៅក្នុងចំណោមកសិករនៅក្នុងប្រព័ន្ធ។ គណៈកម្មាធិការនេះ មានសមាជិក ៣ រូប។ ថ្លៃទឹកត្រូវបានយកក្នុងតម្លៃ ៣០០.០០០ រៀល (៧៥ ដុល្លារអាមេរិក) ក្នុងមួយហិកតា សម្រាប់ការធ្វើស្រែនៅដើមរដូវវស្សា ខណៈដែលអន្តរាគមន៍ពេលមានគ្រោះរាំងស្ងួតសម្រាប់ការធ្វើស្រែវស្សា ប្រសិនបើមាន ត្រូវបានជួយដោយក្រុមការងារគណៈបក្សប្រជាជនកម្ពុជា។ ប្រាក់ចំណូលដែលប្រមូលបាន ត្រូវបានប្រើភាគច្រើនសម្រាប់បង់ប្រាក់ខែជូនសមាជិកគណៈកម្មាធិការគ្រប់គ្រង ប្រេងឥន្ធនៈ ការថែទាំម៉ាស៊ីនបូមទឹក និងទំនប់ ព្រមទាំងបំពង់រំដោះទឹកខ្លះនៅផ្នែកខាងក្រោមខ្សែទឹកនៃប្រព័ន្ធ។

នៅខាងផ្នែកសង្កាត់ការក្រៅ ក្រុមមួយដែលមានសមាជិកប្រាំពីរនាក់ក៏ត្រូវបានបង្កើតឡើងផងដែរ ក្នុងនាមជាគណៈកម្មាធិការមួយ ដើម្បីដំណើរការការផ្គត់ផ្គង់ទឹកពីអាងស្តុកទឹកទៅឲ្យស្រែ ខណៈដែលកសិករទទួលផលបង់ថ្លៃទឹកជាស្រូវ ដែលមានតម្លៃប្រហែល ៤០-៥០ គីឡូក្រាម ក្នុងមួយហិកតា។ ថ្លៃនេះគឺសម្រាប់បង់ថ្លៃពលកម្មរបស់ពួកគាត់ក្នុងការត្រួតពិនិត្យទឹកស្រោចស្រព ពោលគឺមិនមែនសម្រាប់ការថែទាំអាងស្តុកទឹកទេ។

ចំណុចទាំងអស់នេះបង្ហាញថា ពុំមានយន្តការនៅកម្រិតមូលដ្ឋានដើម្បីទទួលខុសត្រូវលើការថែទាំប្រព័ន្ធនោះទេ។ ទោះបីជាគណៈកម្មាធិការគ្រប់គ្រងក្នុងទម្រង់ខ្លះត្រូវបានបង្កើតឡើងក៏ដោយ ក៏គណៈកម្មាធិការទាំងនេះមិនមែនសំដៅដល់ការថែទាំប្រព័ន្ធនៅផ្នែកខាងលើខ្សែទឹក ដូចជាប្រឡាយមេ ទំនប់នៃអាងស្តុកទឹក និងទ្វារទឹកនោះឡើយ។

**ជោគជ័យ និង គុណវិបត្តិ**: តាមទស្សនៈរបស់ប្រជាជន និងអាជ្ញាធរមូលដ្ឋាន ជោគជ័យនៃការកែលម្អប្រព័ន្ធត្រូវបានរៀបរាប់លើផ្នែកមួយចំនួនដូចជា ១) វាស្តុកទឹកបានច្រើនជាង ដើម្បីធានាការផ្គត់ផ្គង់ទឹកបានគ្រប់គ្រាន់សម្រាប់ស្រែ ដែលធ្លាប់ជួបប្រទះនឹងកង្វះទឹកជាញឹកញាប់ ២) វាមានលក្ខណៈងាយស្រួលជាងក្នុងការយកទឹកស្រោចស្រពតាមរយៈម៉ាស៊ីនបូមទឹក និង ៣) វាផ្តល់ផ្លូវធ្វើដំណើរជូនកសិករឲ្យធ្វើដំណើរលើទំនប់នៃអាងស្តុកទឹក និងផ្លូវតាមបណ្តោយខ្នងប្រឡាយមេ។ អ្វីដែលត្រូវបានចាត់ទុកថាជាចំណុចខ្វះខាត គឺថាកិច្ចប្រឹងប្រែងស្តារនីតិសម្បទាមិនបានចងក្រងកសិករឲ្យក្លាយទៅជាFWUC មួយ។

**សេចក្តីសន្និដ្ឋាន**: ការកែលម្អប្រព័ន្ធមិនបាននាំឲ្យមានការពង្រីកទំហំស្រោចស្រពនៃប្រព័ន្ធធារាសាស្ត្រ ប៉ុន្តែបានជួយដោះស្រាយកង្វះទឹកនៅក្នុងប្រព័ន្ធ និងបានរួមចំណែកដល់ការកែលម្អទិន្នផលខ្លះ។

## ប្រព័ន្ធទី ១២: ប្រព័ន្ធធារាសាស្ត្របន្ទាយធ្លាយ [ខេត្តតាកែវ]

**ទស្សនៈរួម**: ការសាងសង់ប្រព័ន្ធធារាសាស្ត្របានចាប់ផ្តើមក្នុងឆ្នាំ ១៩៩៦។ នាពេលនោះប្រព័ន្ធគឺជាប្រព័ន្ធសាងសង់ថ្មីមួយដោយមានជំនួយពីសហភាពអឺរ៉ុប តាមរយៈគម្រោង PRASAC។ ប្រព័ន្ធរួមមានប្រព័ន្ធប្រឡាយមេប្រវែងប្រហែល ៥៦ គីឡូម៉ែត្រ[35] ដែលគ្របដណ្តប់លើឃុំចំនួន ៤ ក្នុងស្រុកកោះអណ្តែត។ ឃុំទាំងនេះ រួមមានឃុំក្រពុំឈូក ឃុំព្រៃខ្លា ឃុំរមេញ និង ឃុំព្រៃយុទ្ធកា។ ការចុះសិក្សាផ្ទាល់បានរកឃើញថាទឹកមាននៅក្នុងប្រឡាយទាំងអស់នៃប្រព័ន្ធក្នុងរដូវប្រាំង ហើយពុំមានទ្វារទឹក ឬសំណង់ស្ទាក់ទឹក ត្រូវបានសាងសង់ដើម្បីគ្រប់គ្រងទឹកនោះទេ ដោយសារប្រឡាយគឺជ្រៅល្មមដើម្បីអនុញ្ញាតឲ្យមានលំហូរតាមទំនាញផែនដីពីទន្លេបាសាក់។

**អត្ថប្រយោជន៍**: ការស្តារនីតិសម្បទាបាននាំមកនូវអត្ថប្រយោជន៍ដូចខាងក្រោម:

- ទឹកធារាសាស្ត្របំពេញបន្ថែម
- ការផ្លាស់ប្តូរដំណាំតាមរដូវ

[35] ប្រវែងនេះមិនរាប់បញ្ចូលប្រឡាយរងដែលផ្គត់ផ្គង់ទឹកស្រោចស្រពទៅឲ្យស្រែតាមរយៈម៉ាស៊ីនបូមទឹក។

- ផលិតកម្មដំណាំបន្ថែមនៅដើមរដូវវស្សា
- ផលស្រូវល្អ
- ការធ្វើដំនើរតាមផ្លូវទឹក និងផ្លូវតាមខ្នងប្រឡាយ
- កំណើនមច្ឆាជាតិ។

ប្រព័ន្ធប្រឡាយទឹកប្រវែងប្រហែល៥៦គីឡូម៉ែត្រ ត្រូវបានកសាងដោយគម្រោង PRASAC។ ដីស្រែបច្ចុប្បន្នសុទ្ធតែត្រូវបានជន់លិចដោយទឹកជំនន់ពីទន្លេបាសាក់ក្នុងរដូវវស្សា។ មុនពេលសាងសង់ប្រព័ន្ធនេះ កសិករបានធ្វើស្រែប្រដេញទឹកលើផ្ទៃដីប្រហែល ៤.០០០ ហិកតាដោយទទួលផលជាមធ្យមប្រហែល២,៥ តោនក្នុងមួយហិកតា។ ចាប់តាំងពីឆ្នាំ១៩៩៧មក ប្រព័ន្ធប្រឡាយទឹកបាននាំមកនូវការផ្លាស់ប្តូរច្រើននៅក្នុងការធ្វើស្រែនៅក្នុងឃុំទាំងបួន។ កសិករបានឈប់ធ្វើស្រែប្រដេញទឹកទៀតហើយ។ ពួកគាត់បានប្តូរទៅធ្វើស្រែប្រាំងវិញ នៅពេលទឹកជំនន់ចាប់ផ្តើមស្រកនៅក្នុងខែ វិច្ឆិកា។ ការធ្វើស្រែគ្របដណ្តប់លើស្រែប្រហែល ៩.៥០០ ហិកតា ជាមួយផលជាមធ្យមប្រហែល ៤ តោនក្នុងមួយហិកតា ដែលបង្ហាញពីការពង្រីកដីថ្មីទំហំ ៤.៥០០ ហិកតា និងកំណើនផល ៦០% (ឬ ១,៥ តោនក្នុងមួយហិកតា) លើអតីតដីស្រែប្រដេញទឹក។ FWUC បានពន្យល់ថែមទៀតថា នៅពេលធ្វើស្រែប្រដេញទឹក កសិករងាយនឹងទទួលរងគ្រោះពីទឹកជំនន់ ពោលគឺឆ្នាំខ្លះ ស្រូវត្រូវបានបំផ្លាញដោយទឹកជំនន់ធំដែលជាហេតុធ្វើឲ្យគេប្រមូលទិន្នផលបានតិច។ ក្រៅពីអត្ថប្រយោជន៍ទាំងអស់នេះ គេបានប៉ាន់ស្មានថាដីស្រែប្រហែល ៤.៧០០ ហិកតា ដែលស្មើនឹងប្រហែល ៥០% នៃដីស្រែនៅក្នុងប្រព័ន្ធ មានលក្ខណៈអំណោយផលសម្រាប់ផលិតកម្មដំណាំលើកទីពីរ ដូច្នេះកសិករដាំដំណាំបន្ថែមភ្លាមក្រោយពេលប្រមូលផលនៃដំណាំលើកទីមួយ។ ដំណាំលើកទីពីរផ្តល់ផលតិចជាងបន្តិច ដែលជាមធ្យមគឺ ៣,៥ តោនក្នុងមួយហិកតា។

ដោយបានកសាងសមិទ្ធផលទាំងនេះ គម្រោងមួយនៃទីភ្នាក់ងារអូស្ត្រាលីដើម្បីអភិវឌ្ឍន៍អន្តរជាតិ (AusAid) ពោលគឺគម្រោង CAVAC សំដៅកសាងប្រឡាយថ្មីមួយប្រវែង ២៦ គីឡូម៉ែត្រ ដើម្បីកែលម្អ និងពង្រីកទំហំស្រោចស្រពនៃប្រព័ន្ធធារាសាស្ត្រលើផ្ទៃដីគ្រោងស្រោចស្រពប្រមាណជា ៧.០០០ ហិកតា តាមសេចក្តីរាយការណ៍ដោយមន្ទីរធនធានទឹក និងឧតុនិយមខេត្ត។ គិតមកដល់ត្រឹមពេលនៃការស្ទង់មតិនេះ ប្រឡាយប្រវែងជាង ១០ គីឡូម៉ែត្រក៏ ត្រូវបានស្តារនីតិសម្បទានិងសាងសង់ ប៉ុន្តែផ្ទៃដីគ្រោងស្រោចស្រពតែមួយផ្នែកប៉ុណ្ណោះបានទទួលអត្ថប្រយោជន៍ពីទឹកធារាសាស្ត្រក្នុងរដូវកន្លងមក ខណៈដែលផ្ទៃដីត្រូវស្រោចស្រពនៅសល់នឹងទទួលអត្ថប្រយោជន៍នៅក្នុងរដូវដាំដុះខាងមុខ។ ខុសពីគម្រោងPRASAC កិច្ចប្រឹងប្រែងដែលបានធ្វើដោយគម្រោង CAVAC មិនត្រឹមតែផ្តល់ទឹកធារាសាស្ត្រដល់ស្រែប្រាំងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងពង្រីកទឹកស្រោចស្រពដល់ស្រែវស្សាទៀតផង។ បទសម្ភាសន៍ជាមួយអាជ្ញាធរមូលដ្ឋាន បង្ហាញថាប្រឡាយរបស់គម្រោង CAVAC នឹងមិនត្រឹមតែផ្គត់ផ្គង់ទឹកគ្រប់គ្រាន់សម្រាប់ផ្ទៃដីគ្រោងស្រោចស្រពរបស់ប្រឡាយដែលធ្លាប់តែពឹងលើទឹកភ្លៀងទាំងស្រុងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអនុញ្ញាតឲ្យកសិករនៅក្នុងប្រព័ន្ធអាចដាំដំណាំពីរដងក្នុងមួយឆ្នាំលើផ្ទៃដីស្រែវស្សាទៀតផង។ អាជ្ញាធរឃុំបានអះអាងថា “ទឹកគឺបរិបូរណ៍ និងពុំចាំបាច់មានទ្វារទឹកឬសំណង់ស្ទាក់ទឹកនៅតាមបណ្តោយប្រឡាយទេ ដោយសារទឹកពីទន្លេមកមានកម្ពស់ខ្ពស់គ្រប់គ្រាន់សម្រាប់ហូរចូលទៅក្នុងប្រព័ន្ធ”។ លក្ខណៈអំណោយផលនៃសណ្ឋានដីបានជួយបន្ធូរបន្ថយថ្លៃចំណាយលើគម្រោងធារាសាស្ត្រ ហើយដែលគម្រោងនេះបានផ្តល់អត្ថប្រយោជន៍ជាច្រើនដល់កសិករ។

**ការថែទាំ:** ប្រព័ន្ធធារាសាស្ត្របន្ទាយឆ្លាយត្រូវបានគ្រប់គ្រងដោយFWUCមួយ ដែលមានសមាជិក ៥ នាក់[36] និងតំណាង ៥ នាក់ផ្សេងទៀតដើម្បីជួយការសម្របសម្រួលនៅថ្នាក់ឃុំ។ FWUC កំពុងទទួលខុសត្រូវលើប្រឡាយមេទាំង ៥៧ គីឡូម៉ែត្រ ខណៈដែលការផ្តល់ទឹកធារាសាស្ត្រទៅកាន់ដីស្រែ ត្រូវបានផ្ទេរទៅអោយអ្នកម៉ៅការបន្ត។ អ្នកម៉ៅការបន្តនីមួយៗកំពុងដំណើរការម៉ាស៊ីនបូមទឹក ដើម្បីបូមទឹកពីប្រឡាយមេដាក់បញ្ចូលក្នុងស្រែ។ ពួកគេសាងសង់ និងថែទាំប្រឡាយរងនៅក្នុងផ្នែកម៉ៅការរបស់ខ្លួន ហើយប្រមូលថ្លៃទឹកពីកសិករ និងបង់ថ្លៃទឹកជូន FWUC។ អ្នកម៉ៅការបន្តបង់ថ្លៃទឹកជូន FWUC ជាស្រូវ ១៤០ គីឡូក្រាម ក្នុងមួយហិកតា ខណៈដែលកសិករត្រូវគេយកថ្លៃជាប្រេងឥន្ធនៈ ៧៥ លីត្រ និង ស្រូវ ៤០៥ គីឡូក្រាម ក្នុងមួយហិកតា។ បើគិតជាប្រាក់ កសិករបង់ប្រហែល ៦៣៩.០០០ រៀល (ឬ ១៥៦ ដុល្លារអាមេរិក) ក្នុងមួយហិកតា[37] សម្រាប់ថ្លៃទឹក។

យោងតាមFWUC អ្នកម៉ៅការបន្តបង់ថ្លៃទឹកលើផ្ទៃដីប្រហែល ៩០០ ហិកតាសម្រាប់ឆ្នាំ ២០១០។ ចំណុចនេះមានន័យថា FWUC បានប្រមូលថ្លៃបានត្រឹមតែពីប្រហែល ១០% នៃផ្ទៃដីដាំដុះប៉ុណ្ណោះ។ ប្រសិនបើគេបានបង់ថ្លៃទឹកពេញលើដីទាំង ៩០០ ហិកតានេះ ប្រាក់ចំណូលសរុបគប្បីមានចំនួនប្រហែល ៩៤ លានរៀល[38]។ ប៉ុន្តែ គណៈកម្មាធិការ FWUC បានរាយការណ៍ថាប្រាក់ចំណូលជាក់ស្តែងពីការប្រមូលថ្លៃទឹកសម្រាប់ ឆ្នាំ ២០១០ គឺបានតែ ៤៩ លានរៀលប៉ុណ្ណោះ ដែលគឺជាចំនួនប្រហែល ៥០% នៃចំនួនដែលគួរប្រមូលបាន។ ប្រការនេះបង្ហាញថាមានភាពមិនប្រក្រតីច្រើន និងការអនុវត្តទន់ខ្សោយនៅក្នុងការប្រមូលថ្លៃទឹក។

**សេចក្តីសន្និដ្ឋាន:** ប្រព័ន្ធផ្តល់អត្ថប្រយោជន៍ដ៏ធំធេងចំពោះកសិករ។ ការមានទឹកធារាសាស្ត្របានលើកទឹកចិត្តឲ្យកសិករប្តូរពីការធ្វើស្រែប្រដេញទឹកលើផ្ទៃដីប្រហែល ៤.០០០ ហិកតា ទៅជាការធ្វើស្រែប្រាំងវិញជាមួយផលប្រសើរជាងប្រហែល ៦០%។ ម្យ៉ាងទៀត កសិករអាចពង្រីកការធ្វើស្រែរបស់ខ្លួនលើដីស្រែ ៥.៥០០ ហិកតាបន្ថែមទៀត និង ដាំដំណាំលើកទីពីរលើផ្ទៃដីដាំដំណាំលើកទីមួយប្រហែល ៥០% (៤.៧០០ ហិកតា)។ ដោយសារស្ថានភាពអំណោយផលនៃសណ្ឋានដី និងការមានទឹកពីទន្លេបាសាក់ ការពង្រីកប្រព័ន្ធប្រឡាយទឹកដោយគម្រោងCAVAC នឹងពង្រីកទឹកស្រោចស្រពបន្ថែមទៀតជាអត្ថប្រយោជន៍ដល់ស្រែវស្សា។

---

[36] ដែលរួមមានប្រធាន ១រូប អនុប្រធាន ២ រូប គណនេយ្យករ ១ រូប និង បេឡា ១ រូប។

[37] ការគណនាសន្មតថាថ្លៃប្រេងឥន្ធនៈមានតម្លៃ ៤.៣០០ ក្នុងមួយលីត្រ និង ស្រូវមានតម្លៃ ៨០០ រៀលក្នុងមួយគីឡូក្រាម។

[38] FWUC បានយកថ្លៃទឹកជាស្រូវ១៤០គីឡូក្រាម ក្នុងមួយហិកតា ហើយស្រូវត្រូវបានសន្មតថាមានតម្លៃ ៧៥០រៀល ក្នុងមួយគីឡូក្រាម។

# ពាក្យបច្ចេកទេស

| ភាសាខ្មែរ | ភាសាអង់គ្លេស |
|---|---|
| ការផ្សព្វផ្សាយបច្ចេកទេសកសិកម្ម | Agricultural extension |
| សេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្ម | Agricultural extension service |
| សាវតារ | Background |
| តួលេខចំណុចចាប់ផ្តើម តួលេខជាមូលដ្ឋាន | Baseline |
| គណៈកម្មាធិការ | Board |
| ចំណាយមូលធន | Capital expenditure |
| ដែនទទួលទឹកភ្លៀង (អាងស្រូបទឹក) | Catchment |
| បញ្ហាប្រឈម | Challenge |
| ផ្ទៃដីគ្រោងស្រោចស្រព | Command area |
| ទំនាស់ផលប្រយោជន៍ | Conflict of interest |
| ការវិភាគថ្លៃចំណាយ និងផលប្រយោជន៍ | Cost- benefit analysis |
| បញ្ហាអន្តរវិស័យ | Cross-cutting issues |
| ការបញ្ចូលទិន្នន័យ | Data processing |
| មូលដ្ឋានទិន្នន័យ | Database |
| មូលនិធិបន្ធូរបន្ថយបំណុល | Debt relief fund |
| ដៃគូអភិវឌ្ឍន៍ | Development partner |
| សំណង់ស្ទាក់ទឹក | Diversion structure |
| ប្រព័ន្ធរំដោះទឹក | Drainage system |
| ថាមវន្ត (ការផ្លាស់ប្តូរ) | Dynamic |
| សហគមន៍កសិករប្រើប្រាស់ទឹក | Farmer Water User Community (FWUC) |
| ការសិក្សាពីលទ្ធភាពជោគជ័យ | Feasibility study |
| ការចុះប្រមូលទិន្នន័យផ្ទាល់ | Fieldwork |
| ហិរញ្ញប្បទាន | Finance |
| ក្របខ័ណ្ឌ | Framework |
| កិច្ចដំណើរការ | Functioning |
| ម្ចាស់មូលនិធិ ស្ថាប័នផ្តល់មូលនិធិ | Funder |
| លំហូរតាមទំនាញផែនដី លំហូរតាមសណ្ឋានដី | Gravity flow |
| ក្បាលហុងទឹក | Headwork |
| ការប្រឈម | Incidence |
| ផ្ទៃដីស្រោចស្រព | Irrigated area |

| ភាសារខ្មែរ | ភាសារអង់គ្លេស |
|---|---|
| ទំហំស្រោចស្រពនៃប្រព័ន្ធធារាសាស្ត្រ | Irrigation coverage |
| ក្រុមការងារបច្ចេកទេសចំរុះ | Joint TWGs |
| កសិករខ្នាតធំ | Large-scale farmer |
| កំណើនខ្ពស់ កំណើនលោតផ្លោះ | Leapfrog increase |
| កម្រិតជីវភាព | Living standard |
| ប្រឡាយមេរំដោះទឹក | Main drain |
| ប្រព័ន្ធធារាសាស្ត្រប៉ែកពាយព្យ | Northwest irrigation |
| របាយការណ៍វាយតម្លៃពាក់កណ្តាលអាណត្តិនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ | NSDP midterm review |
| ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម | NSDP- update |
| ធារាសាស្ត្រក្នុងស្រែ ធារាសាស្ត្រតាមស្រែ | On-farm irrigation |
| ស្តារនីតិសម្បទា ស្តារឡើងវិញ | Rehabilitate |
| អាងស្តុកទឹក | Reservoir |
| ផលចំណេញ | Return |
| ប្រព័ន្ធ | Scheme |
| ប្រឡាយរងទី២ | Secondary canal |
| សំណង់ទំនើប | Sophisticated design |
| ការស្ទង់មតិ | Survey |
| ប្រឡាយរងទី៣ | Tertiary canal |
| សណ្ឋានដី | Topography |
| ផ្លូវលើខ្នងប្រឡាយ | Towpath |
| បរិមាណទឹក | Water capacity |
| មាគ៌ាទៅមុខ | Way forward |
| ទ្វារទឹក | Weir |

**វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា**

ការិយាល័យ: ផ្ទះលេខ ៩-១១ ផ្លូវលេខ ៤៧៦ ទួលទំពូង ១
ប្រអប់សំបុត្រលេខ ២២៩៥ ភ្នំពេញ-៣
ទូរស័ព្ទលេខ: ០២៣ ២១៤ ៤២៩
ទូរសារលេខ: ០២៣ ៩៩៤ ០៦៣
អ៊ីមែល: ngoforum@ngoforum.org.kh
គេហទំព័រ: www.ngoforum.org.kh